# ព្រះ
# ត្រៃបិដកចារលី
## និង
## សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ទីឃនិកាយ បឋមភាគ
## សីលក្ខន្ធវគ្គ
# ១៤

ព្រហ្មជាលសូត្រ សាមញ្ញផលសូត្រ
អម្ពដ្ឋសូត្រ និង សោណទណ្ឌសូត្រ

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
៣.ស ២៥០២

ឯកសារគម្ពីរព្រះត្រៃបិដកស្កានេះ
ត្រូវទាបថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកដប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជាទបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ។ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ។

កែសម្រួលតាមកុំព្យូទ័រ តម្រូវឲ្យបកវណ៌អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណាខ្ញុំបាទ ស្រុង-ចាន់ណា ។

www.5000-years.org

# ព្រះ
# វិន័យបិដក
## ភាគ
## សេចក្តីប្រៀបធៀបភាសាខ្មែរ
# សុត្តន្តបិដក
# ទីឃនិកាយ បឋមភាគ
# សីលក្ខន្ធវគ្គ
# ១៨

ព្រហ្មជាលសូត្រ សាមញ្ញផលសូត្រ

អម្ពដ្ឋសូត្រ ឧទ្ទ សោណទណ្ឌសូត្រ



ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០២

# ស្រៈ
# Voyelles.

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឣ | ឧ | ឩ | ឯ | ឱ |
| ឡាប Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | ไอ |
| ឡាវ Laotien | ະ | າ | ິ | ີ | ຸ | ູ | ເ | ໄ |
| សង្ហា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ိ | ီ | ု | ူ | ေ | ဩ |

# ស:ទិសរ្យ

## Signes et accents.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ |
| ឡាតាំង Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ |
| ឡាវ Laotien | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ |
| សិង្ហ: Cinghalais | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ |
| ភូមា Birman | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ | ◌ |

ព្យញ្ជនៈ

# Consonnes.

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | | | | | |
| ទ្រួយ Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | | | | | |
| លាវ Laotien | | | | | |
| សិង្ហ Cinghalais | | | | | |
| ភូមា Birman | | | | | |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | | | | | |
| ឡាតាំង Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | | | | | |
| ឡាវ Laotien | | | | | |
| សិង្ហ Cinghalais | | | | | |
| ភូមា Birman | | | | | |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | | | |  | |
| ទ្រៃប Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | | | |  |  |
| លាវ Laotien | | | | | |
| សិង្ហ Cinghalais | | | | | |
| ភ្លួង Birman | | | |  | |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | | | | | |
| ទ្រៃ Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois |  | | | |  |
| លាវ Laotien | | | | |  |
| សេង្ហា Cinghalais | | |  | | |
| ភូមា Birman | | | | | |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ປ | ຜ | ພ | ภ | ມ |
| សិង្ហ Cinghalais | ප | ඵ | බ | භ | ම |
| ភូម Birman | ပ | ဖ | ဗ | ဘ | မ |

| | |
|---|---|
| ខ្មែរ CAMBODGIEN | ឃ្ យ ្រ ល ្ ទ ្ ស ្ ហ ្ ឡ ° ॥ |
| ទ្រួប Romain | *y r l v s h ḷ ṃ ·/.* |
| សៀម Siamois | ย ร ล ว ส ห ฬ ° ॥ |
| ឡាវ Laotien | ຢ ຣ ລ ວ ສ ຫ ฬ ° ॥ |
| សិង្ហ Cinghalais | ය ර ල ව ස හ ළ ° ॥ |
| ភូមា Birman | ယ ရ လ ဝ သ ဟ ဠ ° ॥ |

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## បឋមោ ភាគោ

---

## សីលក្ខន្ធវគ្គោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### ព្រហ្មជាលសុត្តំ បឋមំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ សុប្បិយោបិ ខោ បរិព្ពាជកោ អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ សទ្ធឹ អន្តេវាសិនា ព្រហ្មទត្តេន មាណវេន ។ តត្រ សុទំ សុប្បិយោ បរិព្ពាជកោ អនេកបរិយាយេន

# សុត្តន្តបិដក ទីឃនិកាយ

## បឋមភាគ

## សីលក្ខន្ធវគ្គ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## ព្រហ្មជាលសូត្រ ទី ១

(១) (*សូត្រនេះ*(១)) *ខ្ញុំបានស្តាប់មកយ៉ាងនេះ*(២) ។ *សម័យមួយ ព្រះមានព្រះភាគ ទ្រង់ព្រះដំណើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃក្រុងភគ្គនឹងចន្លោះនៃនាឡន្ទគ្រាម ជាមួយនឹងភិក្ខុសង្ឃប្រើន ចំនួន៥០០អ្នក ។ ចំណែកខាងសុប្បិយបរិព្វាជក ក៏បានដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃក្រុងភគ្គនឹងចន្លោះនៃនាឡន្ទគ្រាម ជាមួយនឹងព្រហ្មទត្តមាណពដែលជាកូនសិស្សដែរ ។ បានពួកថា ក្នុងផ្លូវឆ្ងាយនោះ សុប្បិយបរិព្វាជក*

---

๑ សព្ទដែលប្រែថា សូត្រនេះ គោ: មិនមានក្នុងបាលីទេ តែអដ្ឋកថាចារ្យពន្យល់ដាក់ឲ្យដាក់បញ្ចូលមកប្រែ ដើម្បីសម្រួលសេចក្តីឲ្យងាយស្តាប់ យើងក៏បានយកសព្ទនេះមកដាក់ខាងដើមសូត្រទាំង ៤ ដែលមានក្នុងសៀវភៅសុត្តន្តបិដកបឋមភាគនេះ ដល់ទៅសៀវភៅខាងមុខ ។ ទៀត មិនបាច់ដាក់សព្ទនុ៎ះបញ្ចូលមកប្រែទៀតឡើយ ពីព្រោះតែប៉ុនបាលីប៉ុណ្ណោះ ។ ๒ ដាក់ឈ្មោះព្រះអានន្ទ ព្រោះព្រះសូត្រក្នុងសុត្តន្តបិដកទាំងមូលនេះ សុទ្ធតែជាសូត្រដែលព្រះអានន្ទគ្រែបានស្តាប់មក ដូចមានបាលីប្រកាសខ្លួនរបស់លោកក្នុងខាងដើមនៃសូត្រទាំងនោះថា ឯវម្មេ សុតំ ។ ដូច្នេះ ។

ពុទ្ធេ អាឡ្ហំ កាសតំ ធម្មេ អាឡ្ហំ កាសតំ សង្ឃេ អាឡ្ហំ កាសតំ ។ សុប្បិយេ បន បរិព្ពាជកេ អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធេ វណ្ណំ កាសតំ ធម្មេ វណ្ណំ កាសតំ សង្ឃេ វណ្ណំ កាសតំ ។ តំ កុតេត្ថ សុទំ អាចរិយន្តេវាសី អញ្ញមញ្ញេ ខ្ជុបដិបន្នា កកវត្តិ បដិដ្ឋាតោ បដិដ្ឋាតោ អនុពន្ធា[1] ហោន្តិ តំ ភិក្ខុសង្ឃំ ។ អថ ខោ ភគវា អម្ពលដ្ឋិកាយំ រាជាគារកេ វិហរន្តោ សំ ខុបកញ្ចិ[2] សន្ធិ តំ ភិក្ខុសង្ឃេ ។ សុប្បិយោបិ ខោ បរិព្ពាជកោ អម្ពលដ្ឋិកាយំ រាជាគារកេ វិហរន្តោ សំ ខុបកញ្ចិ[3] សន្ធិ អន្តេវាសិកេ ព្រហ្មទត្តេ មាណវេ ។ តត្របិ សុទំ សុប្បិយោ បរិព្ពាជកោ អនេកបរិយាយេន ពុទ្ធេ អាឡ្ហំ កាសតំ ធម្មេ អាឡ្ហំ កាសតំ សង្ឃេ អាឡ្ហំ កាសតំ ។ សុប្បិយេ បន បរិព្ពាជកេ អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធេ វណ្ណំ កាសតំ ធម្មេ វណ្ណំ កាសតំ សង្ឃេ វណ្ណំ កាសតំ ។

---

๑ ម អនុពន្ធា ។ ๒-๓ ម បគណ្ឋិតបិ ឃាហិ ។

ពោលតំនៀលព្រះពុទ្ធ ពោលតំនៀលព្រះធម៌ ពោលតំនៀលព្រះសង្ឃ ដោយអនេកបរិយាយ ។ ឯព្រហ្មទត្តមាណពដែលជាកូនសិស្ស របស់សុប្បិយបរិព្វាជក ក៏ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ។ ព្រោះហេតុយ៉ាងនេះ បានជាបរិព្វាជកពាំងពីរនាក់ គឺអាចារ្យនឹងកូនសិស្សនោះ ពោលតាក្យជាសឹកសត្រូវទៅវកគ្នានឹងគ្នាដោយត្រង់ (ឥតមានបញ្ចៀសវាសវាង) ហើយដើរវាប់តាមក្រោយ ។ ព្រះមានព្រះភាគនឹងភិក្ខុសង្ឃទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅគង់នៅក្នុងពាជដំណាក់ ក្នុងសួនឈ្មោះអម្ពលដ្ឋិកា នៅអស់មួយពាក្រឹ ជាមួយនឹងភិក្ខុសង្ឃ ។ ឯសុប្បិយបរិព្វាជក ក៏បានចូលទៅនៅក្នុងពាជដំណាក់ ក្នុងសួនឈ្មោះអម្ពលដ្ឋិកា នៅអស់មួយពាក្រឹជាមួយនឹងព្រហ្មទត្ត-មាណពដែលជាកូនសិស្សដែរ ។ ក្នុងរឿងនោះ បានត្មៃថា សុប្បិយបរិព្វាជក ពោលតំនៀលព្រះពុទ្ធ ពោលតំនៀលព្រះធម៌ ពោលតំនៀលព្រះសង្ឃ ដោយអនេកបរិយាយ ។ ឯព្រហ្មទត្តមាណពជាកូនសិស្ស របស់សុប្បិយបរិព្វាជក ក៏ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ។

ឥតិហ តេ ខុ ភោ អាចរិយបាចរិយា អាសភញ្ច ខុទ្ទកំ-
បច្ឆិមកញ្ច កត្វា ឥមានិ ទ្វាសដ្ឋិ ទិដ្ឋិគតានិ ទីបេន្តិ
តិដ្ឋន្តិ ហេវ ខោ សម្ពហុលានំ តិក្ខត្តុំ រត្តិយា
បច្ចូសសមយំ បច្ចុដ្ឋិតានំ មណ្ឌលមាឡេ សន្និសិន្នានំ
សន្និបតិតានំ អយំ សន្ថិយធម្មោ[1] ឧទបាទិ អច្ឆរិយំ
អាវុសោ អព្ភុតំ[2] អាវុសោ យាវញ្ចិទំ តេន ភគវតា
ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សត្តានំ
នានានធិមុត្តិកតា សុបដិវិទិតា[3] អយំ ហិ សុប្បិយោ
បរិព្ពាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ
ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ
សុប្បិយស្ស បន បរិព្ពាជកស្ស អន្តេវាសី ព្រហ្មទត្តោ
មាណវោ អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសតិ
ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ឥតិហ
ឥមេ ខុ ភោ[4] អាចរិយបាចរិយា អាសភញ្ច ខុទ្ទកំ-
បច្ឆិមកញ្ច កត្វា ឥមានិ ទ្វាសដ្ឋិ ទិដ្ឋិគតានិ ទីបេន្តិ
តិដ្ឋន្តិ ហេវ ខោ

---

๑ សន្ថិយធម្មោតិបិ បាឋោ ។ ๒ ខ. អព្ភុតំ ។ ๓ សុប្បដិវិទិតាតិបិ បាឋោ វិភង្គេ
ឃុត្តគវោ ។ ๔ ឥតិហ តេ ឥមេ ខុភោតិបិ បាឋោ ។ ខ. ម. ឥតិហ អេ ។

ព្រោះហេតុយ៉ាងនេះ ឋានជាបរិព្វាជកទាំង ២ រូប គឺអាចារ្យនឹងកូនសិស្ស
នោះ ពោលពាក្យជាសឹកសត្រូវ ទៅរកគ្នានឹងគ្នាដោយត្រង់ ដើរជាប់តាម
ក្រោយ ។ ព្រះមានព្រះភាគនឹងកិកុសង្ឃ ។ គ្រានោះឯង កិកុទាងឡាយ
ច្រើនរូបក្រោកឡើង ក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយប្រជុំគ្នា
កន្លែងសម្រាប់សម្រាកកាយ ឋានផ្តើមពាក្យស្ងើចនេះឡើងថា ម្នាល
អាវុសោទាំងឡាយ អស្ចារ្យណាស់តើហ្ន៎ ម្នាលអាវុសោទាំងឡាយ ហេតុ
នេះមិនធ្លាប់កើត បែរជាកើតឡើងឋាន ព្រះមានព្រះភាគ អង្គនោះ ជា
អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាប ទ្រង់យើញច្បាស់ ទ្រង់ជ្រាបចំពោះនូវ
ការៈនៃសត្វទាំងឡាយ ដែលមានអធ្យាស្រ័យផ្សេង ។ គ្នាដោយពិតប្រា-
កដ ព្រោះថា សុប្បិយបរិព្វាជកនេះ ពោលតិះដៀលព្រះពុទ្ធ ពោលតិះ
ដៀលព្រះធម៌ ពោលតិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ ចំណែក
ខាងព្រហ្មទត្តមាណព ជាកូនសិស្ស របស់សុប្បិយបរិព្វាជក ពោលសរ-
សើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះ
សង្ឃ ដោយអនេកបរិយាយវិញ ព្រោះហេតុយ៉ាងនេះ ឋានជាបរិព្វា-
ជកទាំងពីរនាក់ គឺអាចារ្យនឹងកូនសិស្សនេះ ពោលពាក្យជាសឹកសត្រូវ
ទៅរកគ្នានឹងគ្នាដោយត្រង់ ដើរជាប់តាមក្រោយ ។ នៃព្រះមានព្រះភាគ

กิกฺกสญฺญกฺขนฺโต ฯ อยเญว กถา เตสํ กิกฺขนฺตานมฺปิ
สนฺติยเมฺปวิเนฺตฺวา ยาว มชฺฌนฺหิกาเลปิ เตนุปสงฺกมิ
ตุปสงฺกมิตฺวา ปฏิสนฺถารนิสีทิ ฯ อถสฺส เอตทโหสิ
กถาย สงฺฆสนฺถา สงฺฆปติตา กาตุ ยุตฺตา กิกฺขาย
กถาย สงฺฆสนฺถา สงฺฆปติตา กาตุ ยุตฺตาติ ฯ ภิกฺขเว
อนฺตรกถา วิปฺปกตาติ ฯ ภิกฺขเว เต กิกฺขู กถาย
นิเวเทสุ ฯ อถ โข ภควา เอตสฺมึ นิทาเน ธมฺมึ
กถึ กตฺวา ภิกฺขู อามนฺเตสิ ภิกฺขเวติ ฯ ภทนฺเตติ
เต ภิกฺขู ภควโต ปจฺจสฺโสสุนฺติ ฯ ภควา เอตทโวจ
ตีณิมานิ ภิกฺขเว อกุสลสฺส มูลานิ ตีณิ กุสลสฺส
มูลานิ กตมานิ ตีณิ โลภาโท อกุสลมูลานิ อโลภาโท
กุสลมูลานิ กตมานิ ตีณิ ทุจฺจริตานิ กตมานิ ตีณิ
กายทุจฺจริตานิ วจีทุจฺจริตานิ มโนทุจฺจริตานิ กตมานิ
ตีณิ สุจริตานิ กตมานิ ตีณิ กายสุจริตานิ วจีสุจริตานิ
มโนสุจริตานิ กตมานิ ตีณิ ทานมยานิ ปุญฺญกิริยวตฺถูนิ
สีลมยานิ ปุญฺญกิริยวตฺถูนิ ภาวนามยานิ ปุญฺญกิริย
วตฺถูนิ ฯ ตตฺถ กตมานิ ตีณิ ทานมยานิ ปุญฺญกิริย
วตฺถูนิ ยา โข ปน ภิกฺขเว ทานสฺส ปฏิคฺคหณา
ปฏิคฺคหณสมฺปทา อิทมฺปิ ปุญฺญกิริยวตฺถุ ทานมยานิ
ปุญฺญกิริยวตฺถูนิ ฯ ตตฺถ กตมานิ ตีณิ สีลมยานิ
ปุญฺญกิริยวตฺถูนิ ยา โข ปน ภิกฺขเว สีลสฺส สมาทาน
สมาทานสมฺปทา อิทมฺปิ ปุญฺญกิริยวตฺถุ สีลมยานิ
ปุญฺญกิริยวตฺถูนิ ฯ ตตฺถ กตมานิ ตีณิ ภาวนามยานิ
ปุญฺญกิริยวตฺถูนิ ยา โข ปน ภิกฺขเว ภาวนาย

នឹងកិក្ខុសង្ឃទៅ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវ
ពាក្យស្ងើចនេះរបស់កិក្ខុតាំងឡាយនោះ ហើយទ្រង់យាងចូលទៅកាន់ពេង
សម្រាប់សម្រាកកាយ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈ
ដែលគេតែងតាំងថ្វាយ ។ លុះព្រះមានព្រះភាគគង់ហើយ ក៏ទ្រង់
ត្រាស់ហៅកិក្ខុតាំងឡាយមកថា ម្នាលកិក្ខុតាំងឡាយ អ្នកតាំងឡាយមក
អង្គុយប្រជុំគ្នាកន្លងនេះ និយាយពីរឿងអ្វីដូចម្តេច ចុះពាក្យជាបន្ទោរ(១)
ដូចម្តេច ដែលអ្នកតាំងឡាយនិយាយមិនទាន់ចប់ ។ កាលព្រះមានព្រះ
ភាគទ្រង់សួរយ៉ាងនេះហើយ កិក្ខុតាំងនោះក៏ក្រាបបង្គំទូលសេចក្តីនុ៎ះ
ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំព្រះអង្គតាំង
ឡាយក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយប្រជុំគ្នាកន្លងពេង
សម្រាប់សម្រាកកាយនេះ បានផ្តើមពាក្យស្ងើចនេះឡើងថា ម្នាល
អាវុសោតាំងឡាយ អស្ចារ្យណាស់តើហ្ន៎ ម្នាលអាវុសោតាំងឡាយ
ហេតុនេះ មិនធ្លាប់កើត ក៏បែរជាកើតឡើងបាន ព្រះមានព្រះភាគអង្គនោះ
ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបឃើញច្បាស់ ទ្រង់ជ្រាបច្បាស់លាស់
នូវការៈនៃសត្វតាំងឡាយ ដែលមានអធ្យាស្រ័យផ្សេង ។ គ្នា ដោយពិត
ប្រាកដ ព្រោះថាសុប្បិយបរិព្វាជកនេះ ពោលតិះដៀលព្រះពុទ្ធ ពោល
តិះដៀលព្រះធម៌ ពោលតិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ

---

១ អដ្ឋកថា ថា ពាក្យដាច់បន្ទោរអំពីគុណធម៌ មានកម្មដ្ឋានមនសិការនឹងបាលីនឹងអដ្ឋកថា
ជាដើម ។

សង្ឃស្ស អាឡ្ហំ ភាសតិ សុប្បិយស្ស បន បរិព្ពាជ-
កស្ស អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិ-
យាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ
សង្ឃស្ស វណ្ណំ ភាសតិ តតិយា តតិយេ ឧភោ អាចរិយន្តេ-
វាសី អញ្ញមញ្ញស្ស ឧជុវិបច្ចនីកភាវា ភគវន្តំ បិដ្ឋិតោ
បិដ្ឋិតោ អនុពន្ធា ហោន្តិ តិក្ខត្តុំ សង្ឃញ្ចាតិ អយំ ខោ ជោ
តន្តេ អន្តេ ភគវា វិប្បភតា អថ ភគវា អនុប្បត្តោតិ ។
មមំ វា តិក្ខត្តុំ បរេ អាឡ្ហំ ភាសេយ្យុំ ធម្មស្ស វា
អាឡ្ហំ ភាសេយ្យុំ សង្ឃស្ស វា អាឡ្ហំ ភាសេយ្យុំ
តត្រ តុម្ហេហិ ន អាឃាតោ ន អបច្ចយោ ន ចេតេ-
សោ អនត្តមនតា ។ មមំ វា តិក្ខត្តុំ បរេ
អាឡ្ហំ ភាសេយ្យុំ ធម្មស្ស វា អាឡ្ហំ ភាសេយ្យុំ សង្ឃ-
ស្ស វា អាឡ្ហំ ភាសេយ្យុំ តត្រ ចេ តុម្ហេ អស្សុ
ករុណា វា អនត្តមនតា វា តុម្ហេសេវស្ស[1] តេន អន្ត-
រាយោ ។ មមំ វា តិក្ខត្តុំ បរេ អាឡ្ហំ ភាសេយ្យុំ

---

๑ ធ. ម. តុម្ហំ យេវស្ស ។

ឯព្រហ្មទត្តមាណពដែលជាកូនសិស្ស របស់សុប្បិយបរិព្វាជក កំពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ព្រោះហេតុយ៉ាងនេះ ឃានជាបរិព្វាជកទាំង ២ នាក់ គឺអាចារ្យនឹងកូនសិស្សនោះ ពោលពាក្យជាសឹកសត្រូវទៅវិញទៅមកគ្មានទីឆ្គងដោយត្រង់ ដើរជាប់តាមក្រោយ ៗ នៃព្រះមានព្រះភាគនឹងភិក្ខុសង្ឃទៅ បង្អិតព្រះអង្គដ៏ចំរើន ពាក្យជាចន្លោះនេះឯង ដែលខ្ញុំព្រះអង្គទាំងឡាយ និយាយមិនទាន់ចប់នៅឡើយ ទទួលព្រះមានព្រះភាគស្តេចមកដល់ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលតិះដៀលតថាគតក្តី ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃក្តី អ្នកទាំងឡាយមិនគួរធ្វើគំនុំ មិនគួរធ្វើសេចក្តីមិនត្រេកអរ មិនគួរធ្វើសេចក្តីអាក់អន់ចិត្ត ចំពោះពួកសត្វទាំងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលតិះដៀលតថាគតក្តី ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃក្តី បើអ្នកទាំងឡាយក្រោធ ឬអាក់អន់ចិត្តចំពោះពួកសត្វទាំងនោះហើយ បុទ្គលជាសេចក្តីអន្តរាយ (នៃគុណទាំងឡាយមានបឋមជ្ឈានជាដើម) នឹងកើតមានប្រាកដដល់អ្នកទាំងឡាយ ដោយសេចក្តីក្រោធនឹងសេចក្តីអាក់អន់ចិត្តនោះ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃពោលតិះដៀលតថាគតក្តី

ឆម្មុស្ស ក អវណ្ណំ ភាសេយ្យុំ សង្ឃស្ស ក អវណ្ណំ ភាសេយ្យុំ តត្រ ចេ តុម្ហេ អស្សុ កុបិតា ក អនត្ត-មនា ក អបិនុ តុម្ហេ បរេសំ សុភាសិតំ ក ទុព្ភាសិតំ ក អាជានេយ្យាថាតំ ។ តោ ហេតំ ភន្តេ ។ មមំ ក តិក្ខត្តុ បរេ អវណ្ណំ ភាសេយ្យុំ ឆម្មុស្ស ក អវណ្ណំ ភាសេយ្យុំ សង្ឃស្ស ក អវណ្ណំ ភាសេយ្យុំ តត្រ តុម្ហេបិ អក្ខមំ អក្ខមតោ ន្តំ ភវេថតញ្ចិ ។តំ បេតំ(១) អក្ខមំ ។តំ បេតំ អតច្ចំ នត្ថិ បេតំ អម្ហេសុ ន ច បនេតំ អម្ហេសុ សំវិជ្ជតីតំ ។ មមំ ក តិក្ខត្តុ បរេ វណ្ណំ ភាសេយ្យុំ ឆម្មុស្ស ក វណ្ណំ ភាសេយ្យុំ សង្ឃស្ស ក វណ្ណំ ភាសេយ្យុំ តត្រ តុម្ហេបិ ន អានន្ទោ ន សោម-នស្សំ ន ចេតសោ ខុញ្ចិលាវិតត្តំ ភវិស្សតីយំ ។ មមំ ក តិក្ខត្តុ បរេ វណ្ណំ ភាសេយ្យុំ ឆម្មុស្ស ក វណ្ណំ ភាសេ-យ្យុំ សង្ឃស្ស ក វណ្ណំ ភាសេយ្យុំ តត្រ ចេ តុម្ហេ តិក្ខត្តុ អស្សុ អានន្ទិនោ សុមនា ខុញ្ចិលាវិតត្តា

---

(១) ឥតិបិ ឯតំ ។

ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃក្តី បើអ្នកទាំងឡាយ
ក្រោធ ឬអាក់អន់ចិត្តចំពោះពួកសត្វទាំងនោះហើយ អ្នកទាំងឡាយនឹង
បានដឹងច្បាស់នូវសេចក្តីនៃពាក្យពីរោះឬពាក្យអាក្រក់ របស់ពួកសត្វដទៃ
ដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំ
មិនអាចដឹងច្បាស់ នូវសេចក្តីនៃពាក្យនោះទេ ។ ព្រះមានព្រះភាគ
ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលតិះ
ដៀលតថាគតក្តី ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃ
ក្តី អ្នកទាំងឡាយគប្បីឃាត់ពាក្យមិនពិត ដោយពាក្យមិនពិត ចំពោះ
ពួកសត្វទាំងនោះថា ពាក្យនេះមិនពិត ដោយហេតុនេះ ពាក្យនេះមិន
ប្រាកដដោយហេតុនេះ ហេតុនេះគ្មានក្នុងពួកយើង មួយវិញទៀត
ពាក្យនេះរកមិនបានក្នុងពួកយើងទេ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួក
សត្វដទៃ ពោលសរសើរគុណតថាគតក្តី ពោលសរសើរគុណព្រះធម៌ក្តី
ពោលសរសើរគុណព្រះសង្ឃក្តី អ្នកទាំងឡាយមិនគួរធ្វើសេចក្តីរីករាយ
មិនគួរធ្វើសោមនស្ស មិនគួរធ្វើសេចក្តីត្រេកចិត្ត ចំពោះពួកសត្វទាំង
នោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលសរសើរ
គុណតថាគតក្តី ពោលសរសើរគុណព្រះធម៌ក្តី ពោលសរសើរគុណព្រះ
សង្ឃក្តី ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមានចិត្តរីករាយ ត្រេកអរ

តុម្ហាកោវស្ស តេន អត្តភាយោ ។ មមំ ភ តំក្ខណេ បរេ វស្សំ ភាសេយ្យុំ ឧម្មុស្ស ភ វស្សំ ភាសេយ្យុំ សម្ប-ស្ស ភ វស្សំ ភាសេយ្យុំ តត្រ តុម្ហេបិ ភូតំ ភូតតោ បដិជានិតព្ពំ ឥតិបេតំ ភូតំ ឥតិបេតំ តច្ចំ អត្ថិបេតំ អម្ហេសុ សំវិជ្ជតិ ច បនេតំ អម្ហេសុតិ ។

(២) អប្បមត្តកំ ខោ បនេតំ តំក្ខណេ ខុរមត្តកំ សីលមត្តកំ យេន បុថុជ្ជនោ តថាគតស្ស វស្សំ វទ-ញ្ញូនោ វទេយ្យ ។ តតមញ្ញេតំ(๑) តំក្ខណេ អប្បមត្តកំ ខុរមត្តកំ សីលមត្តកំ យេន បុថុជ្ជនោ តថាគតស្ស វស្សំ វទញ្ញូនោ វទេយ្យ ។

---

๑ ឧ. ម. តតមញ្ញំ ។

ព្រើលចិត្ត ចំពោះពួកសត្វទាំងនោះហើយ សេចក្តីអន្តរាយ (នៃគុណទាំង
ឮ្លាយមានបឋមជ្ឈានជាដើម) នឹងកើតមានប្រាកដ ដល់អ្នកទាំងឮ្លាយ
ព្រោះសេចក្តីត្រេកអរនោះឯង ។ ម្នាលភិក្ខុទាំងឮ្លាយ ទោះបីពួកសត្វ
ដទៃ ពោលសរសើរគុណតថាគតក្តី ពោលសរសើរគុណព្រះធម៌ក្តី
ពោលសរសើរគុណព្រះសង្ឃក្តី អ្នកទាំងឮ្លាយត្រូវប្តេជ្ញាពាក្យពិតតាម
ពាក្យពិត ចំពោះពួកសត្វទាំងនោះថា ពាក្យនេះពិតដោយហេតុនេះមែន
ពាក្យនេះប្រាកដដោយហេតុនេះមែន ពាក្យនេះតែងមាន ក្នុងពួកយើងមែន
មួយវិញទៀត ពាក្យនេះ រមែងរកបាន ក្នុងពួកយើងមែន ។

(២) ម្នាលភិក្ខុទាំងឮ្លាយ បុថុជ្ជន កាលបើពោលសរសើរគុណ
របស់តថាគត តែងសរសើរដោយគុណជាតណា គុណជាតនុ៎ះមានប្រ-
មាណតិច មានប្រមាណស្តួចស្តើងបានត្រឹមតែសីលប៉ុណ្ណោះ ។ ម្នាល
ភិក្ខុទាំងឮ្លាយ បុថុជ្ជន កាលបើពោលសរសើរគុណរបស់តថាគត ដោយ
គុណជាតណា គុណជាតនុ៎ះមានប្រមាណតិច មានប្រមាណស្តួចស្តើង
បានត្រឹមតែសីលប៉ុណ្ណោះ តើដូចម្តេច ។

(๓) ចាណាតំចាតំ បហាយ ចាណាតំចាតា បដិវិរតោ សមណោ គោតមោ ឯហិតនុឯណ្ហោ ឯហិតុ-សត្តោ លជ្ជី ឧយោបន្នោ សព្វបាណភូតហិតានុកម្បី វិហរតីតិ ។ ឥតិ ភ ហិ តិក្ខត្តេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ អទិន្នាទានំ បហាយ អទិន្នា-ទានា បដិវិរតោ សមណោ គោតមោ ទិន្នាទាយី ទិន្នបា-ដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតីតិ ។ ឥតិ ភ បហិ តិក្ខត្តេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ អព្រហ្មចរិយំ បហាយ ព្រហ្មចារី សមណោ គោតមោ អារាចារី វិរតោ មេថុនា គាមធម្មា តិ ។ ឥតិ ភ បហិ តិក្ខត្តេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(๔) មុសាវាទំ បហាយ មុសាវាទា បដិវិរតោ សម-ណោ គោតមោ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ

(๓) (បុថុជ្ជន តែងពោលសរសើរថា) ព្រះសមណគោតម លះបង់បាណាតិបាតហើយ វៀរស្រឡះចាកបាណាតិបាតហើយ មានដំបង ដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ដល់នូវសេចក្តីអាណិតអាសូរ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ ដល់សព្វសត្វ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណគោតម លះបង់ នូវអទិន្នាទានហើយ វៀរស្រឡះចាកអទិន្នាទានហើយ ព្រះអង្គកាន់យក តែរបស់ដែលគេឲ្យ ទ្រាំថ្នាតែរបស់ដែលគេឲ្យ មានអត្តភាពជាអ្នកមិន លួច មានសភាពដ៏ស្អាត ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោល សរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណ-គោតម លះបង់អព្រហ្មចរិយៈហើយ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ព្រះអង្គវៀសវាង (អំពីអព្រហ្មចរិយៈ) វៀរចាកមេថុនធម្ម ជាធម៌របស់អ្នក ស្រុកហើយ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរ គុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(๔) (បុថុជ្ជន តែងពោលសរសើរថា) ព្រះសមណគោតម លះ បង់មុសាវាទហើយ វៀរស្រឡះចាកមុសាវាទហើយ ព្រះអង្គពោលតែ ពាក្យពិត តរកាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរអកផង់ជឿបាន មិនពោល

អវិសំវាទកោ លោកស្សាតំ ។ ๔តំ វា មហិ តិក្ខត្តុំ
បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។
បិសុណាំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ
សមណោ គោតមោ ๔តោ សុត្វា ន អមុត្រ អក្ខាតា
๔មេសំ ភេទាយ អមុត្រ វា សុត្វា ន ๔មេសំ អក្ខាតា
អមូសំ ភេទាយ ។ ๔តំ កិត្តាវតំ វា សង្ឃាតា សហិតា
វា អនុប្បទាតា សមគ្គករោ សមគ្គរតោ សមគ្គនន្ទី
សមគ្គករណឺ វាចំ ភាសិតាតំ ។ ๔តំ វា មហិ តិក្ខត្តុំ
បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ ផរុសំ
វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ សមណោ
គោតមោ យា សា វាចា នេលា កណ្ណសុខា បេមនីយា
ហាទយង្គមា ពោរី ពហុជនកន្តា ពហុជនមនាបា
តថារូបឺ វាចំ ភាសិតាតំ ។ ๔តំ វា មហិ តិក្ខត្តុំ
បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

បំភ្លឺត់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរ
គុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណគោតម ព្រះ
អង្គលះបង់បិសុណាវាចាហើយ វៀរស្រឡះចាកបិសុណាវាចាហើយ ព្រះ
អង្គឮពាក្យក្នុងសំណាក់នៃពួកជនឯណោះហើយ មិននាំយកទៅប្រាប់ដល់
ពួកជនឯណោះ ដើម្បីបំបែកពួកជននេះឡើយ ឮពាក្យក្នុងសំណាក់នៃ
ពួកជនឯណោះហើយ មិននាំយកមកប្រាប់ដល់ពួកជននេះ ដើម្បីបំបែក
ពួកជនឯណោះឡើយ ។ ព្រះអង្គជាអ្នកផ្សះផ្សាទូវពួកជន ដែលបែកគ្នា
ហើយផង ជាអ្នកបន្ទែមកំឡាំងឲ្យដល់ពួកជន ដែលព្រមព្រៀងគ្នាហើយ
ផង ព្រះអង្គមានសេចក្តីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រម
ព្រៀង តែងពោលក្នុងការព្រមព្រៀង ទ្រង់ពោលវាចាដែលធ្វើឲ្យព្រមព្រៀង
គ្នា ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថា-
គត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណគោតម ទ្រង់លះបង់នូវផរុស-
វាចាហើយ វៀរស្រឡះចាកផរុសវាចាហើយ ក៏វាចាណាដែលជាសំដីឥត
មានទោស ជាសុខដល់ត្រចៀក គួរឲ្យអ្នកផងស្រឡាញ់ពេញហឫទ័យ
ជាសំដីរបស់អ្នកសប្បុរស ជាទីត្រេកអរនៃជនច្រើននាក់ ពេញចិត្តនៃ
ជនច្រើននាក់ ទ្រង់ពោលតែវាចាបែបនោះឯង ។ ម្នាលភិក្ខុទាំងឡាយ
បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

สมฺมปฺปธานานิ បធានទាំងបួន បមาយ សมฺปปฺปธานานิ បធានទាំងបួន ចតฺตาริ បដិវិរតោ សมณោ គោតមោ កាលភឹ ភូតភឹ អត្ថភឹ ធម្មភឹ វិនយភឹ ឯតមត្តំ ភាឃំ ភាសតិ តាលេន សាមញ្ញេនំ បរិយន្តវតឹ អត្តសញ្ញាតន្តិ ។ ឥតិ ភ ឥមំ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(៥) តីឧតាមភូតតាមសមារម្ភា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ ភ ឥមំ ភិក្ខវេ ។ បេ ។

(៦) ឯកភត្តិកោ សមណោ គោតមោ រត្តូបរតោ វិរតោ វិកាលភោជនា ។ ឧច្ចាសយនមហាសយនា បដិវិរតោ សមណោ គោតមោ ។ ជាតរូបរជតបដិគ្គហណា បដិវិរតោ សមណោ គោ-

ថា ព្រះសមណគោតម ទ្រង់លះបង់នូវសម្ផប្បលាបៈហើយ វៀរស្រឡះចាកសម្ផប្បលាបៈហើយ ព្រះអង្គពោលពាក្យក្នុងកាលគួរ ពោលតែពាក្យពិតប្រាកដ ពោលតែពាក្យដែលជាអត្ថ ពោលតែពាក្យដែលជាធម៌ ពោលតែពាក្យដែលជាវិន័យ ពោលតែពាក្យមានទុកាសជាទីដំកល់ទុកក្នុងហឫទ័យ ប្រកបដោយគ្រឿងអាងមានគ្រឿងតំណាត់ ប្រកបដោយប្រយោជន៍ ដោយកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ ឬថ្មីផ្លូន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(៥) ថា ព្រះសមណគោតម វៀរស្រឡះចាកការឆ្លៀតីជគាមនិងភូតគាម(១) ឲ្យវិនាសហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូច្នេះក៏មាន ។បេ។

(៦) ថា ព្រះសមណគោតម ព្រះអង្គបរិភោគកត្តតែ ១ ពេល វៀរលែងបរិភោគក្នុងពេលត្រី វៀរលែងបរិភោគក្នុងកាលខុស ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាមើលនូវរបាំ ទឹងការស្តាប់នូវចម្រៀង ទឹងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទ្រទ្រង់ ប្រដាប់ស្អិតស្អាងពាងកាយ ដោយផ្កាកម្រង

---

๑ រុក្ខដែលមានពូជដុះឡើងបាន តែមិនដុះដាប់ទឹងផែនដី មានគ្រាប់ឈើជាដើម ហៅថា ពីជគាម , ឈើស្មៅជាដើម ដែលដុះដាប់ទឹងផែនដី ហៅថា ភូតគាម ។

តមោ ។ ឧច្ចាសយនមហាសយនា បដិវិរតោ សម.
ណោ គោតមោ ។ ជាតរូបរជតប្បដិក្ខេបា បដិវិរតោ
សមណោ គោតមោ ។

(៧) អាមកធញ្ញប្បដិក្ខេបា បដិវិរតោ សម.
ណោ គោតមោ ។ អាមកមំសប្បដិក្ខេបា បដិវិរ.
តោ សមណោ គោតមោ ។ ឥត្ថីកុមារិកប្បដិក្ខេបា
បដិវិរតោ សមណោ គោតមោ ។ ទាសីទាសប្បដិក្ខេ.
ណា បដិវិរតោ សមណោ គោតមោ ។ អជេឡកប្ប.
ដិក្ខេបា បដិវិរតោ សមណោ គោតមោ ។ កុក្កុដ.
សូករប្បដិក្ខេបា បដិវិរតោ សមណោ គោតមោ ។
ហត្ថិគវស្សវឡវប្បដិក្ខេបា បដិវិរតោ សមណោ គោ.
តមោ ។ ខេត្តវត្ថុប្បដិក្ខេបា បដិវិរតោ សមណោ
គោតមោ ។

(៨) ទូតេយ្យបហិណគមនានុយោគា បដិវិរតោ ស.
មណោ គោតមោ ។ កយវិក្កយា បដិវិរតោ សមណោ
គោតមោ ។ តុលាកូដកំសកូដមានកូដា បដិវិ.

នឹងគ្រឿងក្រអូបនឹងគ្រឿងលាបផ្សេង ។ ។ ព្រះសមណគោតម វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ នឹងទីដេកទីអង្គុយដ៏ប្រសើរ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលមាសនឹងប្រាក់ ។

(៧) ថា ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលធញ្ញជាតផៅ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលសាច់ផៅ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលស្រីនឹងក្មេងស្រី ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលខ្ញុំស្រីនឹងខ្ញុំប្រុស ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលពពែនឹងចៀម ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលមាន់នឹងជ្រូក ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលដំរី គោ សេះ ឈ្មោលញី ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលវៀរនឹងចំការ ។

(៨) ព្រះសមណគោតម វៀរស្រឡះចាកកិរិយាប្រកបនូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្តាំដល់គ្រហស្ថ នឹងទៅដោយគេបញ្ជូន អំពីផ្ទះ១ ទៅផ្ទះ១ ។ ព្រះសមណគោតម វៀរស្រឡះចាកការទិញនឹងការលក់ ។ ព្រះសមណគោតម វៀរស្រឡះចាកការធ្វើបាកឬបន្ទុំដោយជញ្ជីង នឹង

តោ សមណោ គោតមោ ។ ឧស្សោជនវញ្ជនដ្ឋានានុយោគា បដិវិរតោ សមណោ គោតមោ ។ ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ឥមេ ឯកច្ចេ ខុទ្ទកេ សីលេ តថាគតស្ស វណ្ណាវាទមាគោ វាចេយ្យ ។

ធញ្ញកដោយកាដន៍មាស ធញ្ញកដោយរង្វាស់រង្វាល់(១) ។ ព្រះសមណគោតម រៀរស្រឡះចាកកិរិយាប្រកបនូវអំពើរៀ គឺការបង្គុំសំពាន់ បញ្ឆោតបោកប្រាស បន្ទំដោយរបស់ចូម ។ ព្រះសមណគោតម រៀរស្រឡះចាកកិរិយាកាត់ (នូវអរៈយរៈមានដៃជារដើម) នឹងការសម្លាប់ចងធ្វើមនុស្សឲ្យរង្គើងផ្លូវ ប្លន់អ្នកស្រុក កំហែងយកទ្រព្យ ។ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

ចប់ ភូឡសីល ។

---

១ ការធញ្ញកឬបន្ទំដោយដង្ហើងមាន ៤ យ៉ាង គឺបន្ទំដោយរូប ១ បន្ទំដោយអរយរៈ ១ បន្ទំដោយការកាន់យក ១ បន្ទំដោយការបិទបាំង ១ ។ អធិប្បាយ បុគ្គលធ្វើដង្ហើងពីរមានរូបប៉ុនគ្នា ធ្វើចគ្នាតែធ្ងន់ស្រាលដាំងគ្នា រំលោទិញប្រើដង្ហើងធ្ងន់ រំលោលក់ប្រើដង្ហើងស្រាល ហៅថា បន្ទំដោយរូបគឺរូបជាដង្ហើង ។ រំលោទិញ ថ្នឹងរបស់យកដៃសង្កត់ដង្ហើងពីខាងក្រោយ រំលោលក់យកដៃសង្កត់ដង្ហើងពីខាងលុខហៅថា បន្ទំដោយអរយរៈគឺដៃ ។ រំលោទិញ ថ្នឹងរបស់កាន់ខ្សែដង្ហើងខាងគល់ដង រំលោលក់ កាន់ខ្សែខាងកុងដង ហៅថា បន្ទំដោយការកាន់យក ។ ធ្វើដងដង្ហើងឲ្យមានប្រហោងខាងក្នុង ហើយត្រកក់ទេចដៃកក្នុងប្រហោងនោះ រំលោទិញ ធ្វើឲ្យដៃកត់មកខាងក្រោយ រំលោលក់ ធ្វើឲ្យដៃកត់មកខាងមុខ ហៅថា បន្ទំដោយការបិទបាំង ។ ធ្វើភាជន៍ដោយមាសសុទ្ធតែ ១ ហើយធ្វើភាជន៍ក្រឡៃដាំច្រើន ឲ្យមានពណ៌ប្រហែលគ្នាហើយលក់យកថ្លៃស្មើគ្នានឹងមាស ហៅថា បន្ទំដោយមាស ។ រំលោទិញ ព្រើរង្វាល់ធំ រំលោលក់ព្រើរង្វាល់តូច ហៅថា បន្ទំដោយរង្វាល់ ។ រំលោបានសំណូក វាស់ដីស្រែចម្ការធំឲ្យទៅដាំតូច រំលោមិនបានសំណូកវាស់ដីតូចឲ្យទៅដាំធំ ដើម្បីឲ្យចំរើនពន្ធ ឬសួយហៅថាបន្ទំដោយរង្វាស់ ។

ព្រហ្មជាលសុត្តេ មជ្ឈិមសីលំ ពីជគាមភូតគាមសមារម្ភាទិ

(៩) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សន្និធេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ពីជគាមភូតគាមសមារម្ភំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ មូលពីជំ ខន្ធពីជំ ផលុពីជំ អគ្គពីជំ ពីជពីជមេវ បញ្ចមំ ឥតិ វា ។ ឥតិ ឯវរូបា ពីជគាមភូតគាមសមារម្ភា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ តត្ថរ បុដ្ឋដ្ឋោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១០) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សន្និធេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ សន្និធិការបរិភោគំ[1] អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ អន្នសន្និធិ[2] បានសន្និធិ វត្ថសន្និធិ យានសន្និធិ សយនសន្និធិ វិលេបនសន្និធិ គន្ធសន្និធិ អាមិសសន្និធិ ឥតិ វា ។ ឥតិ ឯវរូបា សន្និធិការកបរិភោគា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ តត្ថរ បុដ្ឋដ្ឋោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

---

๑ សន្និធិការបរិភោគន្តិបិ ជាហ ។ ๒ អន្នសន្និធិន្តិបិ អន្នសន្និធីតិបិ ទិស្សតិ ។

ព្រហ្មជាលសូត្រ បឋមសីល ការធ្វើពីជគាមនឹងភូតគាមឲ្យវិនាសជាដើម

(๙) ដូចជាសមណព្រាហ្មណ៍ពាំងឆ្ងាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ពាំងនោះ តែងប្រកបរឿយ ៗ នូវកិរិយាធ្វើពីជគាមនឹងភូតគាមឲ្យវិនាស ។ ពីជគាមនឹងភូតគាមនោះ តើដូចម្តេចខ្លះ ។ គឺ ពូជគឺមើម ប្លុកស ๑ ពូជគឺដើម ๑ ពូជគឺថ្នាំង ๑ ពូជគឺបុង ឫត្រួយ ๑ ពូជគឺគ្រាប់ ๑ ជាគំរប់ ๕ ។ ព្រះសមណៈគោតម ទ្រង់វៀរស្រឡះចាកកិរិយាធ្វើពីជគាមនឹងភូតគាមឲ្យវិនាស មានសភាពដូច្នេះ ។ ម្នាលភិក្ខុពាំងឆ្ងាយ បុថុជ្ជនកាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(๑๐) ដូចជាសមណព្រាហ្មណ៍ពាំងឆ្ងាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ពាំងនោះ តែងប្រកបរឿយ ៗ នូវការបរិភោគវត្ថុ ដែលសន្សំទុក មានសភាពយ៉ាងនេះ ។ ការសន្សំទុកនោះ តើដូចម្តេចខ្លះ ។ គឺ ការសន្សំគ្រឿងស៊ីខ្លះ សន្សំទឹកផឹកខ្លះ សន្សំសំពត់ខ្លះ សន្សំយានខ្លះ សន្សំទីដេកខ្លះ សន្សំគ្រឿងលាបខ្លះ សន្សំគ្រឿងក្រអូបខ្លះ សន្សំអាមិសៈខ្លះ ។ ព្រះសមណគោតមទ្រង់វៀរស្រឡះចាកការបរិភោគវត្ថុដែលសន្សំទុក មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុពាំងឆ្ងាយ បុថុជ្ជនកាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ។

(១១) យថា ឯ បនេតេ ភោន្តោ សមណព្រាហ្មណា សន្ទានេយ្យានិ ភោជនានិ កុញ្ជិត្វា តេ ឯវរូបំ វិស្សកម្មនិស្សិតំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ ឆត្តំ ឯតំ ភទន្តំ បេក្ខំ អក្ខាតំ ចាលាសុរំ វេតាឡិ កុម្ភ-ថូណំ សោកធរកំ(១) ចណ្ឌាលំ វំសំ ជោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិសយុទ្ធំ ឧសភយុទ្ធំ អជយុទ្ធំ មេណ្ឌា-យុទ្ធំ កុក្កុដយុទ្ធំ វដ្តកយុទ្ធំ ឌណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និព្ពុទ្ធំ ឧយ្យោធិកំ ពលកណ្ឌំ សេនាព្យូហំ អនីកទស្សនំ ឥតិ ឯ ។ ឥតិ ឯវរូបា វិស្សកម្មនិស្សិតា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ ឯ ហិ តត្ថវ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

---

១ សោភនន្តង្គីរកន្តិបិ សោភណាគរកន្តិបិ សោភណាករណន្តិបិ សោភណាកន្តិបិ ជាតិវន្តំ ។

(១១) ដូចជាសមណព្រាហ្មណ៍ពាំងឡាយ ដ៏ចំរើនពួកមួយ បរិ-
ភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ពាំងនោះ
តែងប្រកបរឿយ ។ នូវការស្តាប់នឹងការមើលនូវល្បែង ដែលជាសត្រូវដល់
កុសលធម៌ មានសភាពយ៉ាងនេះ ។ ឯល្បែងដែលជាសត្រូវដល់កុសលធម៌
នោះតើដូចម្តេចខ្លះ ។ គឺល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ
ចម្បាំងស្តេចភាតនឹងព្រះភមជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជ្រុង ៤
ខ្លះ រូបគំនូរខ្លះ ល្បែងដុំដែកខ្លះ ល្បែងរ៉ាវខ្លះ ល្បែងលាងធ្នើនខ្លះ ជំរី
ជល់គ្នាខ្លះ សេះប្រចាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់
គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុណ
ដំបងខ្លះ ប្រជាល់ខ្លះ ចំបាប់ខ្លះ ទីសម្រាប់ច្បាំងគ្នាខ្លះ ទីសម្រាប់រៀប
ពលខ្លះ លំនៅកងទ័ពខ្លះ ទីមើលសេនាប្រកបដោយអង្គ ៤ ខ្លះ(១) ។ ឯ
ព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាស្តាប់នឹងការមើលល្បែង
ដែលជាសត្រូវដល់កុសលធម៌ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំង
ឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោល
ដូច្នេះក៏មាន ។

---

១ សេនាដំរី ១ សេនាសេះ ១ សេនារទេះ ១ សេនាថ្មើរជើង ១ ។

ព្រហ្មជាលសុត្តេ បដ្ឋិមសីលំ ដូតប្បមាទដ្ឋានុយោគោ

(๑๒) យថា ឯ បនេកេ តោទ្ធា សមណ-

ព្រាហ្មណា សន្ធាទេយ្យានំ តោជនានំ ភុញ្ជិត្វា តេ

ឯវរូបំ ដូតប្បមាទដ្ឋានានុយោគមនុយុត្តា វិហរន្តិ ។

សេយ្យថីទំ ។ អដ្ឋបទំ ទសបទំ អាកាសំ បរិហារបថំ

សន្តិកំ ខលិកំ(๑) ឃដិកំ សលាកហត្ថំ អក្ខំ បង្គចីរំ

វង្កកំ មោក្ខចិកំ ចិង្គុលិកំ(๒) បត្តាឡ្ហកំ រថកំ ធនុកំ

អក្ខលិកំ មនេសិកំ(๓) យថាវជ្ជំ ឥតិ ឯ ។ ឥតិ

ឯវរូបា ដូតប្បមាទដ្ឋានានុយោគា បដិវិរតោ សមណោ

គោតមោតិ ។ ឥតិ ឯ បិ ភិក្ខវេ ឥមេ ភុជ្ជដ្ឋោ តថាគ-

តស្ស វណ្ណំ វទមានោ វទេយ្យ ។

---

๑ ពលិកំ ។ ๒ បិង្គុលកំ ។ ๓ មានេសិកំ ។

ព្រហ្មជាលសូត្រ បដ្ឋមបិលា ការប្រកបល្បែងជាស្ថានជាទីតាំងនៃសេចក្តីប្រមាទ

(១៦) ដូចដាសមណព្រាហ្មណ៍តាំងខ្លាយ ដ៏ចំរើនពួកមួយ បរិ-
ភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍តាំងនោះ
តែងប្រកបរឿយ ។ នូវល្បែងប៉ាស្ថា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រ-
មាទ ។ ល្បែងប៉ាស្ថានោះ តើដូចម្តេចខ្លះ ។ គឺប៉ាស្ថាមានក្រឡា ៨ ខ្លះ
ប៉ាស្ថាមានក្រឡា ១០ ខ្លះ ប៉ាស្ថាដែលលេងឡដ៏អាកាសខ្លះ ល្បែងរាងផ្លូវ
ដែលគួរវាងខ្លះ ល្បែងផ្លាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងប៉ាស្ថា
ក្នុងទីលានសម្រាប់លេងខ្លះ ល្បែងហឹង ប្តូកូនគោលខ្លះ ល្បែងរលាស់
ទឹកលាក់ឲ្យគាយរូបខ្លះ ល្បែងអង្គញ់ខ្លះ ល្បែងប៊ីស្វឹកខ្លះ ល្បែងនង្គ័ល
តូចខ្លះ ល្បែងដាំដូងខ្លះ ល្បែងកង្ហារខ្លះ ល្បែងរលាស់ដីខ្សាច់ (ប៉ាយឡុក
ប៉ាយឡ)ខ្លះ ល្បែងរថតូចខ្លះ ល្បែងធ្នូតូចខ្លះ ល្បែងសរសេរអក្សរខ្សាច់
ឲ្យគាយខ្លះ ល្បែងទាយចិត្ត (ស្តេចចង់)ខ្លះ ល្បែងកំប្លែងគ្រាប់គេខ្លះ ។
ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាប្រកបរឿយ ។ នូវល្បែង
ប៉ាស្ថា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ មានសភាពដូច្នេះឯង ។
ម្នាលភិក្ខុតាំងខ្លាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត
តែងពោលដូច្នេះក៏មាន ។

[๑๓] យថា ឯ បនេតេ ភោន្តោ សមណព្រាហ្មណា សន្ទិដ្ឋេធិកេ កោដ្ឋាសេ ញាណំ បដិលភន្តិ តេ ឯវរូបំ ខុទ្ទាសយេ ឧត្តមាសយេ អនុយុត្តា វិហរន្តិ។ សេយ្យថីទំ។ អាសវានំ បរិក្ខយំ ញាណាយ ចិត្តាយ បដិបាដិយា បដិលាភាយ អនុត្តរាយ វិមុត្តិយា ខុទ្ទានុខុទ្ទកេ[๑] ឯតានុត្តរេ កិត្តិសទ្ទំ[๒] ញាណាយ ភូតំ[๓] ហត្ថត្ថំ អស្សត្ថំ

---

๑. ខុទ្ទានុខុទ្ទកេ ។ ๒. កិត្តិសទ្ទំ ។ ๓ ភូតំ ។

(១៣) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យ ដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវឧច្ចាសយនមហាសយន: (ទីដេកទីអង្គុយដ៏ខ្ពស់ទំនឹងទីដេកទីអង្គុយដ៏ប្រសើរ) មានសភាពយ៉ាងនេះ ៗ ឧច្ចាសយនមហាសយន:នោះតើដូចម្តេចខ្លះ ៗ គឺ អាសន:ដែលខ្ពស់ហួសប្រមាណខ្លះ គ្រែដែលមានដើមវិចិត្រដោយរូបសត្វសីហាខ្លះ ព្រំដែលមានពេមវែងជាងបួនធាប់ខ្លះ កម្រាលដែលគេធ្វើដោយពេមវិចិត្រ ដោយរូបសត្វសីហាខ្លះ កម្រាលមានពណ៌សដែលគេធ្វើដោយពេមសត្វខ្លះ កម្រាលដែលធ្វើដោយពេមសត្វមានផ្កាដេរដាសខ្លះ កម្រាលដែលញាត់ដោយសំឡីជាប្រក្រតីខ្លះ កម្រាលដែលធ្វើដោយពេមសត្វ វិចិត្រដោយរូបសត្វសីហា (មានសីហ:នឹងខ្លាំងជាដើម)ខ្លះ កម្រាលដែលធ្វើដោយពេមសត្វមានពេមប្រាណឡើងតែម្ខាងខ្លះ កម្រាលដែលធ្វើដោយពេមសត្វ មានពេមប្រាណឡើងទាំងសងខាងខ្លះ កម្រាលដែលធ្វើដោយឱនខ្យែរសេមាស នឹងសូត្រចាក់ស្រែះដោយរតនៈ មានមាសជាដើមខ្លះ កម្រាលដែលធ្វើដោយសរសៃសូត្រ ចាក់ស្រែះដោយរតន:ខ្លះ កម្រាលដែលធ្វើដោយពេមសត្វល្មមចុះពួកស្រីរបាំ ១៦ នាក់ឈរកំបាំងខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងដំរីខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងសេះខ្លះ កម្រាលសម្រាប់ក្រាលលើ

វេទន្តរំ(១) អដ្ឋិនមញ្ញេណំ តាទិលក្ខណប្បត្តមញ្ញេណំ ស-
ព្ពញ្ញុតញ្ញាណំ ឥតោ លោហិតក្ខិបណាទិំ ឥតិ ឯ ។ ឥតិ ឱ-
ប្បិយា ឥច្ឆាសយនមហាសយនា បដិវិរតោ សមណោ
គោតមោតិ ។ ឥតិ ឯ ហិ តិក្ខត្តុំ បុព្ពុដ្ឋានោ តថា-
គតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១៤) យថា ឯ បនេតេ តោណ្ឌោ សមណព្រាហ្ម-
ណា សន្តោនេយ្យកិំ តោដ្ឋកិំ កុញ្ជិត្តា តេ ឱវាទបំ
មណ្ឌនវិភូសនដ្ឋានានុយោគំ អនុយុត្តា វិហរន្តិ ។ សេយ្យ-
ថីទំ ។ ឧច្ចាទនំ បរិមទ្ទនំ ន្ហាបនំ សម្ពាហនំ អាទាសំ
អញ្ជនំ មាលា វិលេបនំ មុខចុណ្ណកំ មុខាលេបំ(២)
ហត្ថពន្ធំ សិខាពន្ធំ ទណ្ឌំ ជាលិកំ អសិំ ឆត្តំ ឧប្ប-

---

១ ។ បាឌិយេក្កវណ្ណំ រស្សវណ្ណំ វេឡុវណ្ណោ ។ ២ ។ ម. មុខាលេបនំ ។

ព្រហ្មជាលសូត្រ មជ្ឈិមសីល ការប្រកបនូវវត្ថុជាទីតាំងនៃការស្ពឹងស្អង់រាងកាយ

លើរថខ្លះ គម្រាលដែលគេធ្វើដោយស្បែកខ្លាខ្លះ គម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្មោសខ្លះ ទីដេកដែលមានពិតានក្រហមពីខាងលើខ្លះ ខ្នើយមានពណ៌ក្រហមទាំងពីរខាង គឺខ្នើយកន្ទុយនំ ខ្នើយដើងព្រមទាំងពិតានមានពណ៌ក្រហមខ្លះ ។ ឯព្រះសមណគោតម ទ្រង់រៀរស្រឡះចាកឧច្ចាសយនមហាសយនៈ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ប៉ុប៉ុណ្ណេះ កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(១៤) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះតែងប្រកបរឿយៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកាយ មានសភាពយ៉ាងនេះ ។ វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកាយនោះតើដូចម្តេច ។ គឺការដុសខាត់បំបាត់កូនអាក្រក់[1]ខ្លះ ការប្រឹបាច់រឹត[2]ខ្លះ ការផ្តេតទឹកខ្លះ ការគក់ច្របាច់[3]ខ្លះ កញ្ចក់ខ្លះ វត្ថុសម្រាប់លាបគ្រឿងប្រដាប់ខ្លះ ផ្កាកម្រងខ្លះ គ្រឿងលាបខ្លះ គ្រឿងលំអិតសម្រាប់ប្រស់មុខខ្លះ វត្ថុសម្រាប់លាបមុខខ្លះ គ្រឿងប្រដាប់ដៃខ្លះ ចំណងផ្នែសក់ខ្លះ ដំបងខ្លះ បំពង់ថ្នាំខ្លះ ដាវខ្លះ ព្រះខាន់ខ្លះ ឆត្រខ្លះ ស្បែកដើង

---

๑ អដ្ឋកថាថា ជុំសខាតឬប្រសំព្រំដោយវត្ថុ មានគ្រឿងក្រអូបនឹងលំអិតជាដើម ដើម្បីបន្ទោបង់នូវក្លិនអាក្រក់ក្នុងសរីរៈ ។ ๒ ឆ្នូចយ៉ាងខាវកដែលមានបុណ្យ គេយកមកផ្តើកលើភ្លៅលាបប្រេងហើយប្រឹបាច់រឹត ដើម្បីធ្វើទ្រង់ទ្រាយនៃអវយវៈមានដៃដើងជាដើម ឲ្យសមរម្យល្អ ។ ๓ ការរៀបដៃដើងដោយវត្ថុមានអនុទ្ធងជាដើម ធ្វើឲ្យដៃដើងចំរើនអំបាំមួន ដូចជាអ្នកចំបាប់ ។ តែក្នុងមង្គលត្ថទីបនីថា ការជក់ទាញដៃដើងជាដើម ដើម្បីបន្ទោបង់នូវភោគពុកសៀត ។

ចំត្រុថាមានំ ខុណ្ហាសំ មណាំ ភាលវ័ដនំ ជិនាតានិ វត្តានិ
ន័យនសានិ ៧តិ ភ ។ ៧តិ ឝវ្ហូថា មណ្ឌនវិភូសនដ្ឋា.
ជានុយោគា បដិវ៉ាតោ សមណោ គោតមោតិ ។ ៧តិ
ភ ហិ តិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ
វទេយ្យ ។

(๑๙) យថា ភ យនេកេ គោដ្ឋោ សមណព្រាហ្ម-
ណា សន្ទាទេយ្យាន គោជនានិ កុញ្ជិត្វា តេ ឝវ្ហូបំ
តិរច្ឆានកថំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ ភជកថំ
ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ
អន្នកថំ ចានកថំ វត្ថកថំ សយនកថំ មាលាកថំ
គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ
នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ ឝូរកថំ

ដ៏វិចិត្រខ្លះ មកុដឬក្បាំងមុខខ្លះ (ស្បៃតសក់) តែវមណីខ្លះ ផ្ទៃតធ្លីពីពេម
កន្ទុយសត្វខ្លះ សំពត់សខ្លះ សំពត់មានជាយវែងខ្លះ។ ឯព្រះសណមគោតម
ទ្រង់វៀរស្រឡះចាកការប្រកបរឿយ ៗ នូវតជាតិតាំងនៃការប្រជាប់ស្អិត
ស្អាងកាយ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឬថ្នូរដូន
កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(១៥) ដូចជាសុមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគ
កោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែង
ប្រកបរឿយ ៗ នូវតិរច្ឆានកថា (ពាក្យនិយាយទទឹងផ្លូវសួគ៌ នឹងផ្លូវព្រះ
និព្វាន) មានសភាពយ៉ាងនេះ ។ តិរច្ឆានកថានោះតើដូចម្តេច ។ គឺ និ-
យាយអំពីស្តេចខ្លះ និយាយអំពីចោរខ្លះ និយាយអំពីអាមាត្រធំខ្លះ និ-
យាយអំពីសេនាទាហានខ្លះ និយាយអំពីភ័យខ្លះ និយាយអំពីចម្បាំងខ្លះ
និយាយអំពីបាយមួមចំណីខ្លះ និយាយអំពីទឹកផឹកខ្លះ និយាយអំពីសំពត់ខ្លះ
និយាយអំពីទីដេកខ្លះ និយាយអំពីផ្កាកម្រងខ្លះ និយាយអំពីគ្រឿងក្រអូប
ខ្លះ និយាយអំពីញាតិខ្លះ និយាយអំពីយានខ្លះ និយាយអំពីស្រុកខ្លះ
និយាយអំពីនិគមខ្លះ និយាយអំពីនគរខ្លះ និយាយអំពីជនបទខ្លះ និយាយ
អំពីស្ត្រីខ្លះ និយាយអំពីបុរសខ្លះ និយាយអំពីយោធាដែលក្លៀវក្លា[1]ខ្លះ

---

១ ក្នុងវិនីយថា សុរាកថំ និយាយអំពីសុរា ផ្ទុច្នេះវិញ ។

វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ ឆានត្តកថំ
លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិ កវាកវកថំ ឥតិ
ហ ។ ឥតិ ឯវរូបាយ តិរច្ឆានកថាយ បដិវិរតោ
សមណោ គោតមោតិ ។ ឥតិ ហ ហិ តត្ថេវ បុថុជ្ជនោ
តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(๑๖) យថា ហ បនេតេ ភោន្តោ សមណព្រាហ្មណា
សន្ទិដ្ឋេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបិំ វិត្តូហិកក-
កថំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ ន ត្វំ ឥមំ
ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ ។

និយាយអំពីច្រកផ្លូវខ្លះ និយាយអំពីកំពង់ទឹកខ្លះ និយាយអំពីញាតិដែលចែកឋានទៅកាន់បរលោកហើយខ្លះ និយាយអំពីពាក្យដែលឥតប្រយោជន៍មានសភាពផ្សេង ។ ខ្លះ និយាយអំពីលោក[1]ខ្លះ និយាយអំពីរឿងដីតសម្ដុត្រ[2]ខ្លះ និយាយអំពីសេចក្ដីចំរើននឹងមិនចំរើន[3]ខ្លះ ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកតិរច្ឆានកថា មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

[ ๑๖ ] ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ។ នូវពាក្យប្រណាំងប្រជែង មានសភាពយ៉ាងនេះ ។ ពាក្យប្រណាំងប្រជែងនោះ តើដូចម្ដេច ។ គឺនិយាយថា អ្នកមិនមែនចេះដឹងធម៌និងវិន័យនេះទេ ខ្ញុំទើបចានចេះដឹងធម៌និងវិន័យនេះ ។

---

๑ អដ្ឋកថា ថា និយាយប្រារព្ធអំពីលោកថា លោកនេះអ្នកណាតាក់តែង អ្នកឯណោះតាក់តែង មួយទៀតភ្លែកស ។ ពិតមែន ព្រោះឆ្គឹងវាស កុករនាសក្រហម ។ ពិតមែន ព្រោះឈាមវាក្រហម ដូច្នេះដាដើម ។ ๒ និយាយថា សម្ដុត្រហេតុអ្វីបានហៅថាសាគរ បានដាហៅដូច្នោះ ព្រោះសាគរទៅតោបានដីត ដាដើម ។ ๓ មើលនយលក្ខណៈសិក្ខាបទទី ๓ នៃវគ្គនវង្គ ក្នុងមហាវិភង្គ ចតុត្ថភាគ ។

กตี ธมฺมา ปหีนายาติ อาทินาสฺส ปหาตพฺพปฏิปกฺขา
ทสฺสิตา อหเมว ปหาตพฺพปฏิปกฺขา ฯ สหิตนฺติ เมตฺ
อสหิตนฺติ ฯ ปุเร วจนียา ปจฺฉา อาคจฺฉนฺติ ฯ ปจฺฉา
วจนียา ปุเร อาคจฺฉนฺติ ฯ อนิจฺจนฺติ วิปริณามนฺติ ฯ
อาเรปิโต เต ภาโร ฯ นิกฺขิตฺโต ทสฺสิ ฯ ย
ภิยฺยมฺหากาย นิตฺถิหิกาย ปฏิปนฺนา สเจ ปโหสีติ ฯ
ตสฺส ฌายิตาย วิตกฺกิตกถาย ปฏิปนฺนา สมณา
โคตมาติ ฯ ตสฺส ปหิ กิตฺตาวเต ปุถุชฺชโน ตถาค.
ตสฺส วณฺณา วทมาโน วเทยฺย ฯ

(๑๗) ยถา ปเนเต เภาคฺคา สมณพฺราหฺม-
ณา สงฺขาเยกฺขา เภชฺชนิกา กุญฺชิตฺวา เต ฌายิปิ
ตฺวาเยวปหิณกมนาทุเยกิ อนุยุตฺตา วิหรนฺติ ฯ

អ្នកនឹងបាននឿយ ថា ចេះដឹងធម៌វិន័យនេះដូចម្តេចបាន អ្នកជាអ្នកប្រតិ-
បត្តិខុស ខ្ញុំទើបជាអ្នកប្រតិបត្តិត្រឹមត្រូវ ។ ពាក្យរបស់ខ្ញុំទើបប្រកបដោយ
ប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ ។ សំដីដែល
គេត្រូវនិយាយមុន អ្នកយកមកនិយាយក្រោយវិញ ។ សំដីដែលគេត្រូវ
និយាយក្រោយ អ្នកយកមកនិយាយមុនវិញ ។ ពាក្យផ្គុំយអ្នកប្រព្រឹត្តមក
ជាយូរអង្វែងហើយ(១) ។ ទោសកង់សំដីរបស់អ្នក ខ្ញុំបានលើកឡើង
ហើយ ។ អ្នកជាមនុស្ស ត្រូវខំសង្កត់សង្កិនបានហើយ ។ អ្នកចូរទៅសិក្សា
ដើម្បីដោះស្រាយនូវទោសកង់សំដី ឬបើអ្នកអាច ចូរអ្នកដោះស្រាយឲ្យរួច
ទោសចុះ ។ ឯព្រះសមណគោតម ទ្រង់រៀបស្រឡះហើយ ចាកពាក្យ
ពោលប្រណាំងប្រជែង មានសភាពដូច្នេះឯង ។ ម្នាលគិភូ ខាំងឡាយ
ឬ ឬផ្សេង កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(១៧) ដូចជាសមណព្រាហ្មណ៍ខាំងឡាយ ដ៏ចំរើនពួកមួយ បរិ-
ភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ខាំងនោះ
រមែងប្រកបរឿយ ។ នូវទុតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្តាំនៃគ្រហស្ថ
ឬទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពយ៉ាងនេះ ។

---

๑ អដ្ឋកថាថា ពាក្យណាដែលសូត៌ល្អដោយអ្នកប្រព្រឹត្តមកជាយូរអង្វែង ពាក្យនោះខុស
ទាស់ផ្ទុយនឹងពាក្យយើងតែ១ម៉ាត់ អ្នកមិនដឹងឡើយ ។

សេយ្យថីទំ ។ រញ្ញំ ភគវមហាមត្តានំ ខត្តិយានំ ព្រាហ្ម-
ណានំ គហបតិកានំ កុមារកានំ ឥធ កច្ច អមុត្រ កច្ច
ឥទំ ហរ អមុត្រ ឥទំ អាហរាតិ ។ ឥតិ ឯវរូបា ទូតេយ្យ-
បហិណគមនានុយោគា បដិវិរតោ សមណោ គោតម-
មោតិ ។ ឥតិ ឯ ហិ កិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ
វទមានោ វទេយ្យ ។

(๑๘) យថា ឯ បនេកេ គោត្តោ សមណព្រាហ្មណា
សទ្ធានេយ្យានំ គោត្តានំ កុញ្ជិត្វា តេ កុហកា ច
ហោន្តិ លបកា ច នេមិត្តិកា ច និប្បេសិកា ច
លាភេន ច លាភំ និជ្ជិគីសិតារោ ។ ឥតិ ឯវរូបា
កុហនលបនា បដិវិរតោ សមណោ គោតមោតិ ។
ឥតិ ឯ ហិ កិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ
វទមានោ វទេយ្យ ។

ព្រហ្មជាលសូត្រ មជ្ឈិមសីល ការពោលកុហក ឆិងការពោលរាក់ទាក់ជាដើម

ទូតកម្មនោះតើដូចម្តេចខ្លះ ។ គឺទៅដោយពាក្យប្រើរបស់ពួកស្តេច ពួកអាមាត្រធំនៃស្តេច ពួកក្សត្រិយ៍ ពួកព្រាហ្មណ៍ ពួកគហបតិឬពួកកុមារថា លោកចូរទៅកន្លែងនេះ លោកចូរទៅកន្លែងណោះ លោកចូរនាំយករបស់នេះទៅ លោកចូរនាំយករបស់នេះ ពីទីណោះមក ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះហើយចាកការប្រកបនូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្តាំនៃគ្រហស្ថ ឬទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(១៨) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះជាអ្នកកុហក គឺញុំាងគេឲ្យកាន់ច្រឡំ (ឲ្យជ្រុះថ្លាដោយការប្រើប្រាស់បច្ច័យជាដើម) ខ្លះ ជាអ្នកពោលពាក្យរាក់ទាក់ (នឹងគ្រហស្ថ) ខ្លះ ជាអ្នកធ្វើនិមិត្ត គឺពោលបញ្ជៀតបញ្ជៀនខ្លះ ជាអ្នកជេរប្រទេចខ្លះ ជាអ្នកស្វែងរកលាភដោយលាភខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះហើយចាកការកុហក នឹងពាក្យរាក់ទាក់ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ។

ចប់ មជ្ឈិមសីល ។

(๑๙) យថា ឯ មេនេកេ ភោន្តោ សមណព្រាហ្ម-
ណា សន្ធានេយ្យានំ ភោជនានំ ភុញ្ជិត្វា តេ ឱរុទ្ធាយ
តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ(๑) កប្បេន្តិ ។ សេយ្យថី-
ទំ ។ អង្គំ និមិត្តំ ឧប្បាទំ សុបិនំ លក្ខណំ មូសិកច្ឆិន្ន-
អគ្គិហោមំ ទព្វិហោមំ ថុសហោមំ កណហោមំ តណ្ឌុ-
លហោមំ សប្បិហោមំ តេលហោមំ មុខហោមំ លោ-
ហិតហោមំ អង្គវិជ្ជា វត្ថុវិជ្ជា ខត្តវិជ្ជា សិវវិជ្ជា ភូតវិជ្ជា
ភូរិវិជ្ជា អហិវិជ្ជា វិសវិជ្ជា វិច្ឆិកវិជ្ជា មូសិកវិជ្ជា

๑ ជីវិតន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

(๑๙) ដូចជាសមណព្រាហ្មណ៍ពាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគកោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ពាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ គឺការទាយអវយវៈខ្លះ ទាយនិមិត្ត (ហេតុ) ខ្លះ ទាយឧត្បាត គឺធ្លាក់ចុះនៃហេតុធំ ។ មានរន្ទះបាញ់ជាដើមខ្លះ ទាយយល់សប្តិខ្លះ ទាយលក្ខណៈខ្លះ ទាយកែតមានសំពត់ជាដើម ដែលកណ្តុរកាត់ខ្លះ និយាយអំពីការបូជាដោយភ្លើងខ្លះ និយាយអំពីការបូជាដោយវែក[1]ខ្លះ និយាយអំពីការបូជាដោយអង្គាមខ្លះ និយាយអំពីការបូជាដោយកុណ្ឌកខ្លះ និយាយអំពីការបូជាដោយអង្គវខ្លះ និយាយអំពីការបូជាដោយទឹកដោះកខ្លះ និយាយអំពីការបូជាដោយប្រេងខ្លះ និយាយអំពីការបូជាដោយមាត់[2]ខ្លះ និយាយអំពីការបូជាដោយឈាមខ្លះ វិជ្ជាសម្រាប់ទាយអវយវៈខ្លះ វិជ្ជាសម្រាប់ទាយទីភូមិឋាន (ថាឲ្យទុក្ខឲ្យសុខ) ខ្លះ វិជ្ជាសម្រាប់ទាយទីស្រែចម្ការខ្លះ វិជ្ជាស្គាល់ព្រៃខ្មោច[3]ខ្លះ វិជ្ជាចាប់ខ្មោចខ្លះ វិជ្ជាសម្រាប់ការពារក្បែរភូមិផ្ទះខ្លះ វិជ្ជាស្តោះពស[4]ខ្លះ វិជ្ជារក្សាពិសខ្លះ វិជ្ជាស្តោះខ្មួយទិបខ្លះ វិជ្ជាស្តោះតណ្ហាខាំខ្លះ វិជ្ជាសម្រាប់ទាយ

---

๑ ប្រែថា បង្វិលពពិលកំឆាន ។ ๒ អដ្ឋកថាថា យកអាត់ទាំងមូលមានគ្រាប់ស្រូវជាដើមយកទៅដាក់ក្នុងភ្លើង ឬ សូត្រប្រៀនប្រដៅដោយមាត់ ។ ๓ វិជ្ជាសម្រាប់អ្វើបច្រែងដែលជួលទៅក្នុងព្រៃស្មសានហើយចេញមកវិញ ។ ๔ វិជ្ជាមើលសក្ខដែលពស់ទាំងឡាយខាំ ។

សកុណវិជ្ជា ភាយសវិជ្ជា បក្កជ្ឈានំ សរបរិត្តាណំ មិគ-
ចក្កានំ ឥតិ ភ ។ ឥតិ វាវូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា
បដិវិរតោ សមណោ គោតមោតិ ។ ឥតិ ភ ហិ
តិក្ខត្តុំ បុដ្ឋដ្ឋោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(๒๐) យថា ភ បនេតេ គោដ្ឋា សមណព្រាហ្ម-
ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ វាវូបាយ
តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ សេយ្យថីទំ ។
មណិលក្ខណំ ទណ្ឌលក្ខណំ វត្ថលក្ខណំ សត្ថលក្ខ-
ណំ (๑) អសិលក្ខណំ ឧសុលក្ខណំ ធនុលក្ខណំ អាវុ-
ធលក្ខណំ ឥត្ថីលក្ខណំ បុរិសលក្ខណំ កុមារលក្ខ-
ណំ កុមារីលក្ខណំ ទាសលក្ខណំ ទាសីលក្ខ-
ណំ ហត្ថិលក្ខណំ អស្សលក្ខណំ មហិំសលក្ខណំ

---

๑ ឱ. សត្តលក្ខណន្តិ ឥទំ ន ទិស្សតិ ។

សម្រែកសត្វស្វាប[1]ខ្លះ វិជ្ជាសម្រាប់ទាយសម្រែកក្អែកខ្លះ វិជ្ជាសម្រាប់ទាយអាយុខ្លះ វិជ្ជាសម្រាប់ការពារសាខ្លះ វិជ្ជាសម្រាប់មើលនូវស្នាមដើមទ្រឹគគឺសត្វដើម ៤ ទាំងអស់ខ្លះ ។ ឯព្រះសមណគោតម ទ្រង់រៀនស្រឡះហើយថាកម្ចាដីរ: ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ ម្នាលតិក្ខទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(๒๐) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគកោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាដីរ: ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ គឺ ការទាយលក្ខណ:តែវមណីខ្លះ ទាយលក្ខណ:ដំបងឫឈើច្រត់ខ្លះ ទាយលក្ខណ:សំពត់ខ្លះ ទាយលក្ខណ:សស្ត្រាខ្លះ ទាយលក្ខណ:ដាវខ្លះ ទាយលក្ខណ:សរខ្លះ ទាយលក្ខណ:ធ្នូខ្លះ ទាយលក្ខណ:អាវុធខ្លះ ទាយលក្ខណ:ស្ត្រីខ្លះ ទាយលក្ខណ:ប្រុសខ្លះ ទាយលក្ខណ:ក្មេងប្រុសខ្លះ ទាយលក្ខណ:ក្មេងស្រីខ្លះ ទាយលក្ខណ:ខ្ញុំប្រុសខ្លះ ទាយលក្ខណ:ខ្ញុំស្រីខ្លះ ទាយលក្ខណ:ដំរីខ្លះ ទាយលក្ខណ:សេះខ្លះ ទាយ

---

๑ វិជ្ជាសម្រាប់ទាយនូវសម្រែកនឹងគតិជាដើម របស់សត្វស្វាប ឬសត្វឥតស្វាបនឹងសត្វដើរ ๒ ដើរ ๔ ។

ខុសកលក្ខណំ តោលក្ខណំ អដលក្ខណំ មេឡា-
លក្ខណំ តុក្កុដលក្ខណំ វដ្ដកលក្ខណំ តោដាលក្ខ-
ណំ កណ្ហាតាលក្ខណំ តច្ឆបលក្ខណំ មិតលក្ខណំ
ឥតិ ឥ ។ ឥតិ ឱវរូហាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា
បដិវិរតោ សមណោ តោតមោតិ ។ ឥតិ ឥ មហា តិក្ខត្តុ
ប្បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(២៧) យថា ឥ បនេតេ តោដ្ដោ សមណព្រាហ្ម-
ណា សន្ធានេយ្យានិ តោដនានិ តុញ្ជិត្វា តេ ឱវរូហាយ
តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ សេយ្យ-
ថីទំ ។ រញ្ញំ និយ្យានំ អវិសហនំ ។ រញ្ញំ អនិយ្យានំ
អវិសហនំ ។ អភិក្ខណំ រញ្ញំ ឧបយានំ អវិសហនំ ។ ពាហិ-
រកនំ រញ្ញំ អបយានំ អវិសហនំ ។ ពាហិរកនំ រញ្ញំ ឧប-
យានំ អវិសហនំ ។ អភិក្ខណំ រញ្ញំ អបយានំ អវិសហនំ ។

លក្ខណៈក្របីខ្លះ ដាយលក្ខណៈគោឧសភខ្លះ ដាយលក្ខណៈគោខ្លះ ដាយលក្ខណៈពពែខ្លះ ដាយលក្ខណៈកែះខ្លះ ដាយលក្ខណៈមាន់ខ្លះ ដាយលក្ខណៈចាបឬក្រួចខ្លះ ដាយលក្ខណៈទន្សែ[1]ខ្លះ ដាយលក្ខណៈគ្រឿងប្រដាប់ឬកំពូលផ្នះ[2]ខ្លះ ដាយលក្ខណៈអណ្តើក[3]ខ្លះ ដាយលក្ខណៈម្រឹគខ្លះ ។ ឯព្រះសមណគោតម ទ្រង់រៀរស្បែរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឬថ្មដ្ឋន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(២១) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ គឺដាយការលើកទំពាថា ព្រះពជា គួរស្តេចចេញទៅ (ក្នុងវេលានោះ) ។ ព្រះពជា គួរស្តេចចូលមកវិញ (ក្នុងវេលានោះ) ។ ព្រះពជាខាងក្នុងនឹងរុកពនចូលទៅ ។ ព្រះពជាខាងក្រៅនឹងឮយចេញទៅ ។ ព្រះពជាខាងក្រៅនឹងរុកពនចូលមក ។ ព្រះពជាខាងក្នុងនឹងឮយចេញទៅ ។

---

១ អដ្ឋកថា ថា វិជ្ជាសំគាល់លក្ខណៈរបូងគំនូរនឹងគ្រឿងប្រដាប់ដាដើម ដែលគេធ្វើជារូបទន្សែង ។ ២ ប្រែថា ដាយលក្ខណៈនៃសត្វពួកមួយ ដែលហៅថាពណ្តើកក៏ដាន ។ ៣ វិជ្ជាសំគាល់លក្ខណៈរបូងគំនូរនឹងគ្រឿងប្រដាប់ដាដើម ដែលគេធ្វើជារូបអណ្តើក ។

អព្ភញ្ញកំ វញ្ចំ ជយោ ភវិស្សតិ ។ ពាហិរកំ វញ្ចំ បភជយោ ភវិស្សតិ ។ ពាហិរកំ វញ្ចំ ជយោ ភវិស្សតិ ។ អព្ភញ្ញកំ វញ្ចំ បភជយោ ភវិស្សតិ ។ ឥតិ ឥមស្ស ជយោ ភវិស្សតិ ឥមស្ស បភជយោ ភវិស្សតិ ឥតិ ក ។ ឥតិ ឱវជ្ជាយ តំវត្ថានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ ក បនិ តិក្ខត្តុំ បុដ្ឋដ្ឋោ តថាភតស្ស វណ្ណំ វទមានោ វទេយ្យ ។

(๒๒) យថា ក មញ្ញេកេ ភោន្តោ សមណព្រាហ្មណា សង្ខារនេយ្យានំ ភោជនានំ កុញ្ជិត្វា តេ ឱវជ្ជាយ តំវត្ថានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ សេយ្យថីទំ ។ ចន្ទក្កាហោ ភវិស្សតិ ។ សុរិយក្កាហោ ភវិស្សតិ ។ ឆក្កត្តក្កាហោ ភវិស្សតិ ។ ចន្ទិមសុរិយានំ បថភមំ ភវិស្សតិ ។ ចន្ទិមសុរិយានំ ឧប្បថភមំ ភវិស្សតិ ។ ឆក្កត្តានំ បថភមំ ភវិស្សតិ ។ ឆក្កត្តានំ ឧប្បថភមំ ភវិស្សតិ ។ ឧក្កាបាតោ ភវិស្សតិ ។ ទិសាឌាហោ ភវិស្សតិ ។ ភូមិចាលោ ភវិស្សតិ ។ នេវុដ្ឋុំ ភវិស្សតិ ។

ព្រះរាជាខាងកូនឹងមានជ័យជំនះ ។ ព្រះរាជាខាងក្រៅនឹងបរាជ័យ ។ ព្រះរាជាខាងក្រៅនឹងមានជ័យជំនះ ។ ព្រះរាជាខាងកូនឹងបរាជ័យ ។ ព្រះរាជាអង្គនេះនឹងមានជ័យជំនះ ឯព្រះរាជាអង្គនេះនឹងបរាជ័យ ។ ឯព្រះសមណគោតម ទ្រង់រៀបស្រេចព្រះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(๒๒) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ គឺការទាយថា (កូនស្រីឯណោះ) នឹងមានចន្ទ្រគ្រោះ ។ នឹងមានសូរ្យគ្រោះ ។ នឹងមាននក្ខត្រគ្រោះ គឺផ្កាយព្រះគ្រោះដើរមកចូលគ្នា ឬដើរលំងព្រះអាទិត្យព្រះចន្ទ្រ ឬផ្កាយណាមួយ ។ ព្រះចន្ទ្រព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា ។ ព្រះចន្ទ្រព្រះអាទិត្យនឹងដើរខុសផ្លូវគ្នា ។ ផ្កាយទាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា ។ ផ្កាយទាំងឡាយនឹងដើរខុសផ្លូវគ្នា ។ នឹងមានឧក្កាបាត(๑) ។ នឹងកើតមានកំដៅកូនទិស ។ នឹងមានកម្រើកផែនដី ។ នឹងមានផ្គរលាន់ (ឥតមានភ្លៀង) ។

---

๑ ឧក្កាបាតនោះ ប្រែថា ធ្លាក់នៃពន្លឺគប់ភ្លើង សេចក្តីថា កាលបើអាកាសមានខ្យល់ទង្គិចគ្នាខ្លាំងក៏កើតមានពន្លឺរស្មីដូចជាពន្លឺប្រទីបធ្លាក់ចុះបកអំពីអាកាស តាមលោកវោហារ ហៅថា ឧក្កាបាត ។ (លីឧត្តបញ្ជាសនាដីកា) ។ បុពណ ហៅថា កេតុជំដួល សំស្រាំតថា ឧក្កាបាត ។

ចន្ទិមសុរិយនក្ខត្តានំ ឧក្កមនំ ឱក្កមនំ សំកិលេសំ ភោ-
ជានំ ភវិស្សតិ ។ ឯវំវិធាភោ ចន្ទក្ខាហោ ភវិស្សតិ ។
ឯវំវិធាភោ សុរិយក្ខាហោ ភវិស្សតិ ។ ឯវំវិធាភោ
នក្ខត្តក្ខាហោ ភវិស្សតិ ។ ឯវំវិធាកំ ចន្ទិមសុរិយានំ
បថភមនំ ភវិស្សតិ ។ ឯវំវិធាកំ ចន្ទិមសុរិយានំ ឧប្បថ-
កមនំ ភវិស្សតិ ។ ឯវំវិធាកំ នក្ខត្តានំ បថភមនំ
ភវិស្សតិ ។ ឯវំវិធាកំ នក្ខត្តានំ ឧប្បថភមនំ ភវិស្សតិ ។
ឯវំវិធាភោ ឧក្កាបាតោ ភវិស្សតិ ។ ឯវំវិធាភោ ទិសា-
ឌាហោ ភវិស្សតិ ។ ឯវំវិធាភោ ភូមិចាលោ ភវិស្សតិ ។
ឯវំវិធាភោ ទេវទុន្ទភិ ភវិស្សតិ ។ ឯវំវិធាកំ ចន្ទិមសុ-
រិយនក្ខត្តានំ ឧក្កមនំ ឱក្កមនំ សំកិលេសំ ភោជានំ
ភវិស្សតិ ឥតិ ភ ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ
មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ ភ ហិ
តេ ភិក្ខវេ ឯកច្ចេ តថាគតស្ស វណ្ណំ វទមានោ វទេយ្យុ ។

ព្រះចន្ទ្រ ព្រះអាទិត្យ ផ្កាយនឹងរះឡើង ឬអស្តង្គតទៅវិញ នឹងសៅហ្មង ឬផ្លូវផង់ ។ ចន្ទ្រគ្រោះ នឹងបណ្តាលឲ្យឋានសុខទុក្ខយ៉ាងនេះ (ដល់សត្វលោក) ។ សុរ្យគ្រោះនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ នក្សត្រគ្រោះ នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ព្រះចន្ទ្រនឹងព្រះអាទិត្យ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ព្រះចន្ទ្រនឹងព្រះអាទិត្យ ដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ពួកផ្កាយ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ឧក្កាបាត នឹងបណ្តាលឲ្យមានទុក្ខសុខយ៉ាងនេះ ។ កំដៅក្តៅទិស នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ការកម្រើកផែនដី នឹងបណ្តាលឲ្យសុខទុក្ខយ៉ាងនេះ ។ ផ្គរលាន់ (ឥតមានភ្លៀង) នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ព្រះចន្ទ្រព្រះអាទិត្យនឹងផ្កាយរះឡើង ឬអស្តង្គតទៅវិញ សៅហ្មងឬផ្លូវផង់ នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ។ ឯព្រះសមណគោតម ទ្រង់រៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពដូចេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូចេះក៏មាន ។

(๒๓) យថា ឯ បនេតេ ភោន្តោ សមណព្រាហ្មណា សន្ទានេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ សេយ្យថីទំ ។ សុវត្ថិកា[๑] ភវិស្សតិ ។ ទុព្ភត្ថិកា ភវិស្សតិ ។ សុភិក្ខំ ភវិស្សតិ ។ ទុព្ភិក្ខំ ភវិស្សតិ ។ ខេមំ ភវិស្សតិ ។ ភយំ ភវិស្សតិ ។ រោគោ ភវិស្សតិ ។ អារោគ្យំ ភវិស្សតិ ។ មុទ្ទា គណនា សង្ខានំ កាវេយ្យំ លោកាយតំ ឥតិ ឯ ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីឯ បដិវិរតោ សមណោ គោតមោតិ ។ ឥតិ ឯ ឥមិ កិត្តាវតា បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(๒๔) យថា ឯ បនេតេ ភោន្តោ សមណព្រាហ្មណា សន្ទានេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ សេយ្យថីទំ ។

---

๑ ម. សុវត្ថិកា ។

ព្រហ្មជាលសូត្រ មហាសីល តិរច្ឆានវិជ្ជា

(២៣) ដូចជាសមណព្រាហ្មណ៍ ខ្លះ ឆ្លាយដ៏ចំរើនពួកមួយ បរិ. កោគកោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ខ្លះនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្តេច ។ គឺការទាយថា (ក្នុងឆ្នាំនេះ) ក្អៀងស្រូល ។ នឹងមានក្អៀងធ្ងាក់មិនស្រូល ។ នឹងមានជាយសម្បូណ៌ ។ នឹងមានជាយក្រ ។ នឹងមានសេចក្តីក្សេមក្សាន្ត ។ នឹងមានភ័យ ។ នឹងមានរោគ ។ នឹងមិនមានរោគ ។ ការរាប់ដោយដៃទេ ការរាប់ដោយវិធីនព្វន្ត ពាប់បូក[1] កាព្យឃ្លោង គម្ពីរលោកាយតៈ[2] ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឬថ្មីឆ្លង កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ។

(២៤) ដូចជាសមណព្រាហ្មណ៍ ខ្លះ ឆ្លាយ ដ៏ចំរើនពួកមួយ បរិ. កោគកោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ខ្លះនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ។ តិរច្ឆាន-

---

១ អដ្ឋកថា ថា ការរាប់នោះ បើស្មាត់ជំនាញបុគ្គលណា បុគ្គលនោះកាលបើឃើញដើមឈើក៏អាចនឹងដឹងថា ឈើនេះមានស្នឹកប៉ុណ្ណេះប៉ុណ្ណោះបាន ។ ២ គម្ពីរនិយាយថា លោកនេះអ្នកណាសាង អ្នកឯណោះសាង បានជាហៅថា ក្អែកស ព្រោះធ្លាប់វាស បានជាហៅថា កុកក្រហម ព្រោះឈាមវាក្រហម ដូច្នេះជាដើម ។

ธิ ฯ อาภาหานิ วิภาหานิ สมฺผสฺสานิ วิผสฺสานิ สญฺโญคานิ วิโย-

คานิ สุขทุกฺขานิ อทุกฺขมสุขานิ วิญฺญาณฏฺฐิติโย ฉ อายตนานิ

ธิปตฺตานิ มหาสมุทฺทานิ สิเนรุปพฺพตราชานิ กณฺหสุกฺกปกฺขา

อาทิจฺจจนฺทิมสา นกฺขตฺตานิ จตุมหาราชานิ ตาวตึสา ยามา

ตุสิตา นิมฺมานรตี ปรนิมฺมิตวสวตฺตี พฺรหฺมกายิกา มหา-

พฺรหฺมาโน ปริตฺตาภา อปฺปมาณาภา อาภสฺสรา ปริตฺตสุภา อปฺป-

มาณสุภา สุภกิณฺหา เวหปฺผลา อสญฺญิสตฺตา อวิหา อตปฺปา

สุทสฺสา สุทสฺสี อกนิฏฺฐา อากาสานญฺจายตนา วิญฺญาณญฺจา-

ยตนา อากิญฺจญฺญายตนา เนวสญฺญานาสญฺญายตนา ปฐวี-

กสิณานิ อาโปกสิณานิ เตโชกสิณานิ วาโยกสิณานิ นีลกสิณานิ

ปีตกสิณานิ โลหิตกสิณานิ โอทาตกสิณานิ อากาสกสิณานิ

อาโลกกสิณานิ ฯ

វិជ្ជានោះតើដូចម្តេច ។ គឺវិធីរៀបអាវហមង្គលខ្លះ[1] វិធីរៀបវាវហមង្គលខ្លះ[2] វិធីធ្វើឲ្យព្រមព្រៀងគ្នា (ស្នេហ៍) ខ្លះ វិធីធ្វើឲ្យព្រោតប្រាសគ្នា (បង់ចំណែង) ខ្លះ វិធីប្រមូលទ្រព្យខ្លះ វិធីប្រកបជំនួញខ្លះ វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរីខ្លះ វិធីធ្វើឲ្យស្អប់គ្នាខ្លះ វិធីធ្វើគគីដែលបំបែនទំនៀនិងសាសមិនឲ្យរៀនសាខ្លះ វិធីបង់អណ្តាតឲ្យរំងៀដោយមន្តខ្លះ វិធីបង់បង្កាឲ្យរំងៀខ្លះ វិធីសូត្រឲ្យរៀនដើម្បីផ្លាស់ប្តូរដៃខ្លះ វិធីសូត្រឲ្យរៀនដើម្បីមិនឲ្យឮសំឡេងដោយត្រចៀកខ្លះ[3] ប្រស្នាកញ្ចក់ គឺមន្តខាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ ហើយសួរប្រស្នាខ្លះ ប្រស្នាកុមារី គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃកុមារីហើយសួរប្រស្នាខ្លះ ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃទាសី ហើយសួរប្រស្នាខ្លះ វិធីបម្រើព្រះអាទិត្យខ្លះ វិធីបម្រើមហាព្រហ្មខ្លះ វិធីបញ្ចេញក្តីងងឹតអំពីមាត់ដោយមន្តខ្លះ វិធីហៅសិរីឲ្យមកបឋិតក្នុងសរីរៈខ្លះ ។ ឯព្រះសមណគោតម ទ្រង់រៀរស្រឡះចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឬថ្កុំជ្ឈនកាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

---

១ អដ្ឋកថា ថា មានចិត្តាខាងប្រុសនាំយកនាងទាវិកាអំពីត្រកូលដំទៃមករៀបការឯផ្ទះរបស់ខ្លួន ហៅថាអាវាហមង្គល ។ ២ មានចិត្តាខាងស្រីរៀបចំបញ្ជូនកូនស្រីខ្លួនឲ្យទៅកាន់ត្រកូលប្តី ហៅថាវិវាហមង្គល ។ មានន័យផ្សេងទៀតថា បើស្រីមកការឯផ្ទះប្រុស ហៅថា អាវាហៈ បើប្រុសទៅការឯផ្ទះស្រី ហៅថា វិវាហៈ ។ ៣ ពុទ្ធសាសនាត្រូវបៀនកោះក្នុងសាលាក្តី បង់និយាយពាក្យណាក៏និយាយពាក្យកោះហៅ អ្នកគួរក្តីអ្វីងស្តាប់មិនឮ ក៏មិនអាចនឹងនិយាយឆ្លើយឆ្លងបានទេ។

(๒๙) យថា ឯ បនេកេ ភោន្តោ សមណព្រាហ្ម-
ណា សង្ខារនេយ្យានំ ភោជនានំ កុញ្ជិត្វា តេ ឯវមាហ យ
តំវណ្ណនវិធ្ងាយ មិច្ឆាជីវេន ជីវិតំ កប្បេន្តិ ។ សេយ្យ-
ថីទំ ។ សន្ធិកម្មំ បណិធិកម្មំ ភូតិកម្មំ(๑) ភូរិកម្មំ
វស្សកម្មំ ភេសជ្ជកម្មំ វត្ថុកម្មំ វត្ថុបរិការណំ អាចមនំ
នហាបនំ ជូហនំ វមនំ វិរេចនំ ឧទ្ធវិរេចនំ អធោវិរេចនំ
សីសវិរេចនំ កណ្ណតេលំ នេត្តប្បានំ នត្ថុកម្មំ អញ្ជនំ
បច្ចញ្ជនំ សាលាកិយំ សល្លកត្តិយំ ឆារកតន្តំ ជា
មូលភេសជ្ជានំ អនុប្បទានំ ឥសីនំ បដិមោក្ខា ឥតិ
ឯ ។ ឥតិ ឯវមាទិ តំវណ្ណនវិធ្ងាយ មិច្ឆាជីវា បដិវិរតោ
សមណោ គោតមោតិ ។ ឥតិ ឯ ហិ តត្ថវ បុថុជ្ជនោ

---

๑ ឧ. ភូតិកម្មន្តិ ឥទំ នត្ថិ ។

ព្រហ្មជាលសូត្រ មហាសីល តិរច្ឆានវិជ្ជា

(២៥) ដូចជាសមណព្រាហ្មណ៍ពាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ពាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះ តើដូចម្តេច ។ គឺការបន់ស្រន់ខ្លះ លាបំណន់ខ្លះ ធ្វើមន្តសម្រាប់ការពារបិសាចខ្លះ ធ្វើមន្តសម្រាប់ការពារផ្ទះខ្លះ ធ្វើខ្លួយឲ្យដូចជាប្រុសខ្លះ ធ្វើប្រុសឲ្យដូចជាខ្លួយ(១) គឺក្រៀវខ្លះ ធ្វើពិធីសង់ផ្ទះលើទីដីដែលមិនទាំបាច់បានធ្វើខ្លះ ធ្វើពលិកម្មនៅទីដីសង់ផ្ទះខ្លះ ជំរះមុខឲ្យស្អាតដោយទឹកឲ្យគេខ្លះ ស្រោចទឹកបង្កក់ប្រសិទ្ធិឲ្យគេខ្លះ បូជាភ្លើងឲ្យគេខ្លះ ផ្សំថ្នាំសម្រាប់ឲ្យក្អួតខ្លះ ផ្សំថ្នាំបញ្ចុះខ្លះ ផ្សំថ្នាំកំចាត់បង់នូវទោសខាងលើខ្លះ ផ្សំថ្នាំកំចាត់បង់នូវទោសខាងក្រោមខ្លះ ផ្សំថ្នាំកំចាត់បង់នូវទោសកងក្បាលខ្លះ សូប្រេងសម្រាប់បន្តក់ត្រចៀកខ្លះ សូប្រេងសម្រាប់ស្នំក្នែកខ្លះ ផ្សំថ្នាំសម្រាប់ហិតខ្លះ ផ្សំថ្នាំសម្រាប់លាបបន្ទាត់ខ្លះ ផ្សំថ្នាំត្រជាក់សម្រាប់លាបស្រលាបខ្លះ ធ្វើវេជ្ជកម្មកក្រៃក្នែកខ្លះ ធ្វើកម្មវបស់ពេទ្យខ្លះ ធ្វើពេទ្យកុមារកុនក្មេងខ្លះ ដាក់ថ្នាំក្រោយឲ្យដួយកំឡាំងថ្នាំមុនខ្លះ លាងថ្នាំដើមចេញ(២)ខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូចេះឯង ។ មាលកិក្ខុពាំងឡាយ ប្រុថជ្ជន

---

១ អដ្ឋកថា ថា ធ្វើផ្លុំភ្លោះដើម្បីមិនឲ្យស្រីស្រឡាញ់ក្លួលចិត្ត មិនមែនធ្វើឲ្យភេទក្លាយទេ ។
២ អដ្ឋកថា ថា កាលបើមានជំងឺ ជាក់ថ្នាំមានថ្នាំផ្សំជាដើមក្នុងជំងឺនោះ កាលបើជំងឺស្រួលសមគួរហើយ ក៏នាំយកថ្នាំនោះចេញ ។

ตถาคตสฺส วณฺโณ วิญฺญาเปตพฺโพ ปากโฏ กาตพฺโพ ฯ ตตฺถ กตโม ตถาคตสฺส วณฺโณ วิญฺญาเปตพฺโพ ปากโฏ กาตพฺโพ ฯ อิธ ภิกฺขเว ตถาคโต โลเก อุปฺปชฺชติ อรหํ สมฺมาสมฺพุทฺโธ วิชฺชาจรณสมฺปนฺโน สุคโต โลกวิทู อนุตฺตโร ปุริสทมฺมสารถิ สตฺถา เทวมนุสฺสานํ พุทฺโธ ภควา ฯ โส อิมินา สีลกฺขนฺธเนว อาคเตน อิมินา สีลกฺขนฺธเนว อุปคเตน อิมินา สีลกฺขนฺธเนว สมนฺนาคเตน อตีตานาคตปจฺจุปฺปนฺนานมฺปิ สาวกานํ สีลานิ ปญฺญาเปติ ฯ

มหาสีลํ นิฏฺฐิตํ ฯ

វិបរិណាមធម្មោ ។ យញ្ហ ខោ ๙ธิ ปុច្ឆតិ ចិត្តន្ទិ ฝ
មនោតិ ฝ វិញ្ញាណន្ទិ ฝ អយំ អត្តា និច្ចោ ធុវោ
សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្ស-
តីតិ ។ ๙ธิ តិក្ខវេ ចតុត្ថំ ឋានំ យំ អាគម្ម យំ អារព្ភ
ฝកេ សមណព្រាហ្មណា ฝកច្ចសស្សតិកា ฝកច្ចអ-
សស្សតិកា ฝកច្ចំ សស្សតំ ฝកច្ចំ អសស្សតំ អត្តា-
នញ្ហ លោកញ្ហ បញ្ញបេន្តិ ។ ๙មេហិ ខោ តេ តិក្ខវេ
សមណព្រាហ្មណា ฝកច្ចសស្សតិកា ฝកច្ចអសស្ស-
តិកា ฝកច្ចំ សស្សតំ ฝកច្ចំ អសស្សតំ អត្តានញ្ហ
លោកញ្ហ បញ្ញបេន្តិ ចតូហិ វត្ថូហិ ។ យេ ហិ កេចិ
តិក្ខវេ សមណា ฝ ព្រាហ្មណា ฝ ฝកច្ចសស្សតិកា
ฝកច្ចអសស្សតិកា ฝកច្ចំ សស្សតំ ฝកច្ចំ អសស្សតំ
អត្តានញ្ហ លោកញ្ហ បញ្ញបេន្តិ សព្ពេ តេ ๙មេហេវ
ចតូហិ វត្ថូហិ ฝតេសំ ฝ អញ្ញតរេន ឧត្តិ ឥតោ ពហិទ្ធា ។

๑ ខ. សយំ បដិភានំ ។

ដែលខ្ញុំស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្ញុំស្ទាបស្ទង់ដោយការពិចារណា ជាពាក្យកើតមានដោយប្រាជ្ញារបស់ខ្ញុំនយ៉ាងនេះថា ធម្មៈជាតណាដែលហៅថា ក្អែកខ្លះ ត្រចៀកខ្លះ ប្រមុះខ្លះ អណ្តាតខ្លះ កាយខ្លះ (ធម្មជាតនោះ) គឺខ្ញុំនេះឯង ជាសភាវៈមិនទៀងទាត់ មិនបិតថេរ តែងប្រែប្រួលជាធម្មតា ។ មួយវិញទៀត ធម្មជាតណាដែលគេហៅថា ចិត្តក្តី មនោក្តី វិញ្ញាណក្តី (ធម្មជាតនោះ) គឺខ្ញុំនេះឯង ជាសភាវៈទៀងទាត់ បិតថេរ មិនប្រែប្រួលជាធម្មតា នឹងបិតនៅស្មើដោយសស្សតិវត្តិ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ អាស្រ័យប្រារព្ធ ទើបបញ្ញត្តនូវខ្ញុំនឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិនោះ រមែងបញ្ញត្តនូវខ្ញុំនឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយហេតុ ៤ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាទីមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តនូវខ្ញុំនឹងលោកថាទៀងខ្លះ មិនទៀងខ្លះ សមណៈឬព្រាហ្មណ៍ទាំងអស់នោះ (រមែងបញ្ញត្ត) ដោយហេតុទាំង ៤ នេះឯង ឬក៏បណ្តាហេតុទាំង ៤ នោះដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីហេតុទាំង ៤ នេះឡើយ ។

តយិទំ កិក្ខវេ តថាគតោ បជានាតិ អយំ ឧដ្ឋជ្ជនា
ឣវិគហិតា ឣវិបរាមដ្ឋា ឣវិគតិកា ភវន្តិ(១) ឣវិអភិសម្ប-
រាយាតិ ។ តញ្ច តថាគតោ បជានាតិ តតោ ច
ឧត្តរិតរំ បជានាតិ តញ្ច បជានន្តំ ន បរាមសតិ ។
អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្ពុតិំ វិទិតា វេទនានំ
សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្ស-
រណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ កិក្ខវេ
តថាគតោ ។ អយមេ ខោ កិក្ខវេ ឧត្តមា តបុរិកា ធុទ្ធសា

---

១ ម. ភវិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវហេតុទាំង ៤ នោះថា ហេតុនៃទិដ្ឋិទាំងនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ រមែងមានគតិយ៉ាងនេះ មានការប្រព្រឹត្តិទៅក្នុងលោកខាងមុខយ៉ាងនេះ ។ ព្រះតថាគតដឹងច្បាស់នូវទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីលសមាធិនិងសព្វញ្ញុតញ្ញាណ) ដែលជាគុណជាតលើសលុបជាងនោះទៅទៀតផង កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ ។ មួយទៀត កាលបើព្រះតថាគត មិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅនៃបញ្ចក្ខន្ធដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសារបស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតផុតស្រឡះហើយ (ចាកកិលេស) ព្រោះមិនប្រកាន់ (នូវធម៌ណាមួយមានខន្ធជាដើម) ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយអាចនឹងសំដែងបាននូវធម៌ទាំងឡាយណា (មួយទៀត) ពួកជនកាលនិយាយសរសើរគុណរបស់ព្រះតថាគតតាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនេះឯង ជាធម៌ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយលំបាក

ឧទុម្ពរោ ជាតិ សន្តិ ខោ បនេតេ អតក្កាវចរា ធម្មបរិយាយ-
ទេវនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា
បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា
វទមានា វទេយ្យុំ ។

(៣៩) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា
អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចត្ថមិ
វត្ថមិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាភគ្គ
កិមារព្ភ អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ
ចត្ថមិ វត្ថមិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា
ព្រាហ្មណោ វា អាតប្បមន្ថាយ បធានមន្ថាយ អនុយោ-
គមន្ថាយ អប្បមាទមន្ថាយ សម្មាមនសិការមន្ថាយ
តថារូបំ ចេតោសមាធិ ផុសតិ យថា សមាហិតេ ចិត្តេ
អន្តសញ្ញី លោកស្មិំ វិហរតិ ។ សោ ឯវមាហ អន្តវា
អយំ លោកោ បរិវដុមោ ។ តំ កិស្ស ហេតុ ។ អហំ
ហិ អាតប្បមន្ថាយ បធានមន្ថាយ អនុយោគមន្ថាយ

ព្រហ្មជាលសូត្រ ការកំណត់នូវចំណែកនៃទន្ទឹងដើម ហេតុ ៤ យ៉ាង

ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។

(៣៥) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤ យ៉ាង ។ ចុះសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤ យ៉ាង(នោះ) តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការពិចារណាមដោយគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការពិចារណាមដោយទីតាំងមាំ អាស្រ័យនូវការពិចារណាមដោយគ្រឿងប្រកបរឿយៗ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃហើយបាននូវបេតោសមាធិ តាមបែបផែន(នៃចិត្តរបស់យោគី)កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ មានសេចក្តីសំគាល់ថា លោកមានទីបំផុត ។ បុគ្គលនោះក៏និយាយពាក្យយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្នូវដុំវិញ គឺមូលដុំវិញ។ ការនិយាយដូច្នោះ តើព្រោះហេតុអ្វី ។ ព្រោះហេតុថា អាត្មាអញអាស្រ័យនូវការពិចារណាមដោយគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការពិចារណាមដោយទីតាំងមាំ អាស្រ័យនូវការពិចារណាមដោយគ្រឿងប្រកបរឿយៗ អាស្រ័យនូវ

อปฺปมาทธมฺมาย สมฺมาทนสิการมฺมาย ตถารูปํ เจตาสมาธึ ผุสาติ ยถา สมาหิเต จิตฺเต อนฺตรา สญฺโ โลกสฺมึ วิหาริตาติ ฯ สมิตาปาปโก ฌานนฺติ ยถา อนฺตรา อยํ โลโก ปรโลกนฺติ ฯ สนฺโต ภิกฺขเว ปณีโต อาคมฺม ยถา อาวุโส สมณพฺราหฺมณา อตฺตานุกฺกสา อตฺตานุปฺ โลกสฺส ปญฺเปนฺติ ฯ

(๓๖) ตุตฺถาเย ธ เกาจิ สมณพฺราหฺมณา ตถาคตฺ ตถาวุโส อตฺตานุกฺกสา อตฺตานุปฺ โลกสฺส ปญฺเปนฺติ ฯ สน ภิกฺขเว เกจิ สมณา ปพฺราหฺมณา ปิ อาตปฺปมาทธมฺมาย ปธานธมฺมาย อนุโยคธมฺมาย อปฺปมาทธมฺมาย สมฺมาทนสิการมฺมาย ตถารูปํ เจตาสมาธึ ผุสติ ยถา สมาหิเต จิตฺเต อนฺตรา

សេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយ
បាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្ត
តាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមានទីបំផុត ។
លោកនេះមានទីបំផុត មានផ្នត់ជុំវិញយ៉ាងណា អាត្មាអញក៏ដឹងនូវលោក
នេះ (យ៉ាងនោះ) ព្រោះគុណវិសេសនេះឯង ។ ម្នាលភិក្ខុទាំងឡាយ
នេះជាហេតុទី ១ ដែល៎សមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយ
អន្តានន្តទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ
មិនមានទីបំផុតខ្លះ ។

(๓๖) ភិក្ខុទាំងឡាយ ហេតុទី ២ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន
ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមាន
ទីបំផុតខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ
បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការ
ព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងតាំងមាំ
អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ។ អាស្រ័យនូវសេចក្តីមិន
ប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោ-
សមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅ ខ្ជាប់ខ្ជួន

សញ្ញី លោកស្មឹ វិហរតិ ។ សោ ឯវមាហ អនន្តោ អយំ លោកោ អបរិយន្តោ យេ តេ សមណព្រាហ្មណា ឯវមាហំសុ អន្តវា អយំ លោកោ បរិវដុមោតិ ។ តេសំ មុសា ។ អនន្តោ អយំ លោកោ អបរិយន្តោ ។ តំ កិស្ស ហេតុ ។ អហំ ហិ អាតប្បមន្ទាយ បធានមន្ទាយ អនុយោគមន្ទាយ អប្បមាទមន្ទាយ សម្មាមនសិការមន្ទាយ តថារូបំ ចេតោសមាធិ ផុសាមិ យថា សមាហិតេ ចិត្តេ អនន្តសញ្ញី លោកស្មឹ វិហរាមិ ។ ឥមិនាមហំ ឯតំ ជានាមិ យថា អនន្តោ អយំ លោកោ អបរិយន្តោតិ ។ ឥធ កិក្ខវេ ខត្តិយោ ហានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។

ហើយ ក៏មានសេចក្តីសំគាល់ថា លោកមិនមានទីបំផុត ។ បុគ្គលនោះឯង ក៏និយាយយ៉ាងនេះថា លោកនេះមិនមានទីបំផុត ឥតមានកំណត់ ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្នែកជុំវិញដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះឯង ជាពាក្យមុសាទេ ។ ឯលោកនេះ ប្រាកដជាមិនមានទីបំផុត ឥតមានកំណត់ ។ ការដែលពោលដូច្នោះ តើព្រោះហេតុអ្វី ។ ព្រោះហេតុថា អាត្មាអញអាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ។ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមិនមានទីបំផុត ។ លោកនេះមិនមានទីបំផុត ឥតកំណត់យ៉ាងណា អាត្មាអញដឹងច្បាស់នូវលោកនេះ (យ៉ាងនោះ) ព្រោះគុណវិសេសនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។

[๓๗] តត្រាយេ ច តេ ភោន្តោ សមណព្រាហ្មណា កាមាគម្ម កាមារព្ភ អត្តានន្តិកា អត្តានុំ លោ-កស្ស បញ្ញបេន្តិ ។ ឥធ កត្ថវ៉ៃ ភិក្ខវេ ភិក្ខុ សមណោ វា ព្រាហ្មណោ វា អាតប្បមន្ទាយ បធានមន្ទាយ អនុយោ-គមន្ទាយ អប្បមាទមន្ទាយ សម្មាមនសិការមន្ទាយ តថារូបំ ចេតោសមាធិំ ផុសតិ យថា សមាហិតេ ចិត្តេ ទុទ្ទមតោ អត្តសញ្ញី លោកស្មឹ វិហរតិ តំវាយំ អនត្ត-សញ្ញី ។ សោ ឥមាហា អត្តា ច អយំ លោកោ អនន្តោ ច យេ តេ សមណព្រាហ្មណា ឥមាហាំសុ អត្តា អយំ លោកោ បរិវដ្តូមោតិ ។ តេសំ មុសា ។ យេបិ តេ សមណព្រាហ្មណា ឥមាហាំសុ អនន្តោ អយំ លោកោ អបរិយន្តោតិ ។ តេសំបិ មុសា ។ អត្តា ច អយំ លោកោ អនន្តោ ច ។ តំ កិស្ស ហេតុ ។

(๓๗) កុដ៏ហេតុទី ๓ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអត្ថានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ។ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិតាមបែបផែន(នៃចិត្តរបស់ព្រះយោគី)ការលើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមានទីបំផុត ក្នុងទិសខាងលើនឹងទិសខាងក្រោម មានសេចក្តីសំគាល់ថា លោកមិនមានទីបំផុត ក្នុងទិសទទឹង(ទិសទាំង ៨) ។ បុគ្គលនោះឯង ក៏ពោលយ៉ាងនេះថា លោកនេះមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវដុំវិញដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះជាពាក្យមុសាទេ ។ មួយទៀត ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមិនមានទីបំផុត ឥតមានកំណត់ទេ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះឯង ក៏ជាពាក្យមុសាដែរ ។ ឯលោកនេះប្រាកដជាមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។ ការនិយាយដូច្នោះ តើព្រោះហេតុអ្វី ។

អបរំ ហិ អាតប្បមច្ចាយ បធានមច្ចាយ អនុយោគ-
មច្ចាយ អប្បមាទមច្ចាយ សម្មាមនសិការមច្ចាយ តថា-
រូបំ ចេតោសមាធិំ ផុសាមិ យថា សមាហិតេ ចិត្តេ
ទុទ្ទមតោ អន្តសញ្ញី លោកស្មឹ វិហរាមិ តំវិយំ អនន្ត-
សញ្ញី ។ ឥមិនាមហំ ឯតំ ជានាមិ យថា អន្តវា ច
អយំ លោកោ អនន្តោ ចាតិ ។ ឥទំ កិត្តាវតា តតិយំ
ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា
អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។

(៣៨) ចតុត្ថេ ច ភោន្តោ សមណព្រាហ្មណា
កិមាគម្ម កិមារព្ភ អន្តានន្តិកា អន្តានន្តំ លោកស្ស
បញ្ញបេន្តិ ។ ឥធ កិត្តាវតា ឯកច្ចេ សមណា ច
ព្រាហ្មណា ច តក្កី ហោតិ វីមំសី ។ សោ តក្កប-

ព្រោះហេតុថា អាត្មាអញអាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិ-
លេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជា
គ្រឿងប្រកបរឿយ ។ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយក
ចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិតាមបែបផែន (នៃចិត្ត
វេស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា
លោកមានទីបំផុត ក្នុងទិសខាងលើនឹងទិសខាងក្រោម មានសេចក្តីសំ-
គាល់ថា លោកមិនមានទីបំផុតក្នុងទិសទទឹង ។ លោកនេះមានទីបំផុតខ្លះ
មិនមានទីបំផុតខ្លះយ៉ាងណា អាត្មាអញដឹងច្បាស់នូវលោកនេះ (យ៉ាង
នោះ) ព្រោះគុណវិសេសនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុ
ទី ៣ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ
អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ។

(៣៨) ក្នុងហេតុទី ๔ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នក
ប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ
តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក
មួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានសេចក្តីត្រិះរិះ
ពិចារណាជាប្រក្រតី ។ បុគ្គលនោះក៏និយាយពាក្យដែលខ្នុះស្រាវជ្រាវ

วิยาหตํ วิมีสานุจริตํ สยํ ปาฏิภาณํ ฝาหาย
เอกจฺเจ ลาเภ ลาภนฺตรายิกา ปาปกา อกุสลา ธมฺมา
ปหีนา โหนฺติ ฯ เตสมฺปหานา ฯ เอวมฺปิ เต สมณพฺราหฺ-
มณา ฝาหาหิสุ อนฺตรายิกา อยํ ลาเภ อปริยนฺตา ฯ
เตสมฺปหานา ฯ เอวมฺปิ เต สมณพฺราหฺมณา
ฝาหาหิสุ อนฺตรายิกา อยํ ลาเภ ปริยนฺตา ฯ
เตสมฺปหานา ฯ เอวมฺปิ เต สมณพฺราหฺมณา
ฝาหาหิสุ อนฺตรายิกา อยํ ลาเภ อนฺตมโส
ปาตฺตปริปูรมตฺตาปิ ฯ เตสมฺปหานา ฯ เอกจฺเจ ลาเภ
ปาตฺตปริปูรมตฺตา ฯ อิธ ภิกฺขเว จตุตฺถี ปาฏิภาณี
ยา อาคมฺม ยา อาคมฺม ฝาหา สมณพฺราหฺมณา อตฺตานญฺเจว
อตฺตานญฺจ โลกสฺส ปญฺญาเปนฺติ ฯ อิเม โข ภิกฺขเว
ภิกฺขู สมณพฺราหฺมณา อตฺตานญฺเจว อตฺตานญฺจ โล-
กสฺส ปญฺญาเปนฺติ จตูหิ วตฺถูหิ ฯ เย หิ เกจิ
ภิกฺขเว สมณา วา พฺราหฺมณา วา อตฺตานญฺเจว

ជានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាពាក្យដែលកើតមាន ដោយប្រាជ្ញារបស់ខ្លួនយ៉ាងនេះថា លោកនេះមានទីបំផុត ក៏មិនមែន មិនមានទីបំផុត ក៏មិនមែន ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវដុំវិញដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះ ជាពាក្យមុសាទេ ។ ម្យ៉ាងទៀត ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមិនមានទីបំផុត ឥតមានកំណត់ដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះ ក៏ជាពាក្យមុសាដែរ ។ មួយទៀត ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះសោត ក៏ជាពាក្យមុសាដែរ ។ ឯលោកនេះប្រាកដជាមានទីបំផុត ក៏មិនមែន មិនមានទីបំផុត ក៏មិនមែនដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ អាស្រ័យប្រារព្ធ ទើបបញ្ញត្តថាលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថាលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឯពួកសមណៈ ឬព្រាហ្មណ៍ឯណាមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ

អត្តានន្តំ លោកស្ស បញ្ញបេន្តំ សព្ពេ តេ ឥមេហេវ ចតុ-
ហិ វត្ថូហិ ឯតេសំ អញ្ញតរេន ឆន្តំ វតោ ពហិទ្ធា ។
តយិទំ កិក្ខវេ តថាគតោ បជានាតិ ឥមេ ទិដ្ឋិដ្ឋា-
ន ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ ឯវំអភិ-
សម្បរាយា តិ ។ តញ្ច តថាគតោ បជានាតិ តតោ
ច ឧត្តរិតរំ បជានាតិ តញ្ច បជានន្តំ ន បរាមសតិ ។
អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្ពុតិ វិទិតា វេទនា-
នំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច
និស្សរណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ
កិក្ខវេ តថាគតោ ។ ឥមេ ខោ តេ កិក្ខវេ ឆឡ្ឃ

បញ្ញត្តថាលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៤ យ៉ាងនេះឯង ឬក៏បណ្តាហេតុទាំង ៤ យ៉ាងនុ៎ះ ដោយហេតុណាមួយ មិនមានហេតុដទៃ ក្រៅពីហេតុ ៤ យ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិប្រការនោះថា ហេតុនៃទិដ្ឋិទាំងនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ដែលបុគ្គលប្រកាន់ខុសយ៉ាងនេះ រមែងមានគតិយ៉ាងនេះ មានការប្រព្រឹត្តិទៅក្នុងបរលោកយ៉ាងនេះ។ ព្រះតថាគតដឹងច្បាស់នូវទិដ្ឋិនោះផង ដឹងច្បាស់(នូវសីលសមាធិនិងសព្វញ្ញុតញ្ញាណ) ដែលជាគុណជាតលើសលុបជាងនោះទៅទៀតផង កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ ។ មួយទៀត កាលបើព្រះតថាគត មិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅនៃ (បពមាសក្តិលេស) ដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុ ដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសា របស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចេញនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតផុតស្រឡះហើយចាកកិលេស ព្រោះមិនប្រកាន់នូវធម៌ណាមួយមានខន្ធជាដើម ។ ម្នាលភិក្ខុទាំងឡាយ

ตตฺถ ตุณฺหิ ภาวาติ ตุณฺหีภาวา สนฺตา ปณีตา อตกฺกาวจรา นิปุณา ปณฺฑิตเวทนียา เย ตถาคตสฺส สยมภิญฺญา สจฺฉิกตฺวา ปเวเทนฺติ เยหิ ตถาคตสฺส ยถาภุจฺจํ วณฺณา สมฺม วทมานา วเทยฺยุ ฯ

(๓๙) สนฺติ ภิกฺขเว เอเก สมณพฺราหฺมณา อมราวิกฺเขปิกา ตตฺร ตตฺร ปญฺหํ ปุฏฺฐา สมานา ฯ ฯ อมราวิกฺเขปํ อาปชฺชนฺติ อมราวิกฺเขปํ ฯ ฯ ฯ เตน จ ภิกฺขเว สมณพฺราหฺมณา ตตฺถตฺถ ตตฺถตฺถ ปญฺหํ ปุฏฺฐา สมานา ฯ ฯ อมราวิกฺเขปํ อาปชฺชนฺติ อมราวิกฺเขปํ ฯ ฯ ฯ ส๘ ภิกฺขเว เอเกจฺเจ สมณา ฯ พฺราหฺมณา ฯ ส๙ ภิกฺขเว อกุสลนฺติ ยถาภูตํ ญาณาย ส๙ อกุสลนฺติ ยถาภูตํ ญาณาย ฯ

ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយ អាចនឹងសំដែងបាននូវធម៌ទាំងឡាយណា ពួកជនកាលនិយាយសរសើរគុណរបស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនេះឯង ជាធម៌ជ្រាលជ្រៅ ដែលបុគ្គលយើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ងប់ប្រមើលដោយសេចក្តីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។

(៣៩) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមកវាទៃ្ចបទិដ្ឋិ(១) កាលបើមានអ្នកណាមួយ សាកសួរប្រស្នាកុំឲ្យកុសលនឹងអកុសលនោះ ។ ក៏ដល់នូវការចោះរ៉ាចាចោះសំដីមិនឲ្យស្ងាប់ពាក្យ ដោយហេតុ ៤ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ជាអ្នកប្រកបដោយអមកវាទៃ្ចបទិដ្ឋិ កាលបើមានអ្នកណាមួយ សួរប្រស្នាកុំឲ្យកុសលនឹងអកុសលនោះ ។ ហើយ ក៏ដល់នូវការចោះរ៉ាចាចោះសំដី មិនឲ្យស្ងាប់ពាក្យដោយហេតុ ៤ ប្រការ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍មិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសល ។

---

១ អដ្ឋកថាថា ជាអ្នកប្រកាន់នូវការចោះសំដី មិនឲ្យស្ងាប់ពាក្យ ។ ន័យមួយទៀតថា អ្នកនិយាយចោះសំដីក្រឡឹងក្រឡុងមិនឲ្យគេចាប់ពាក្យបាន ដូចជាត្រីមួយប្រភេទឈ្មោះ ត្រីអមរ ដែលស្ទុះទៅស្ទុះមក ភ្លែតចុះភ្លែតឡើង មិនឲ្យគេចាប់ខ្លួនបាន ។

តស្ស ฯลฯ ហោតំ អហំ ខោ ឥទំ កុសលន្តិ យថាភូតំ ញប្បជានាមិ ឥទំ អកុសលន្តិ យថាភូតំ ញប្បជានាមិ អយញ្ច ខោ[1] បន ឥទំ កុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ អកុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ កុសលន្តិ វា ព្យាករេយ្យំ ឥទំ អកុសលន្តិ វា ព្យាករេយ្យំ តំ មមស្ស មុសា យំ មមស្ស មុសា សោ មមស្ស វិឃាតោ យោ មមស្ស វិឃាតោ សោ មមស្ស អន្តរាយោតំ ។ ឥតិ សោ មុសាវាទភយា មុសាវាទបរិជេគុច្ឆា នេវិទំ កុសលន្តិ ព្យាករោតំ ន បដិទំ អកុសលន្តិ ព្យាករោតំ តត្ថ តត្ថ បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតំ អមរវិក្ខេបំ វាចិដ្ឋិបំ មេ នោ ។ តថាតិបំ មេ នោ ។ អញ្ញាតិបំ មេ នោ ។

ញ

---

๑ ឱ. អហញ្ញេវ ខោ ។

បុគ្គលនោះតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ កាលបើអាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ នឹងអះអាងថា នេះជាកុសលក្តី នឹងអះអាងថា នេះជាអកុសលក្តី ពាក្យនៃអាត្មាអញនោះ នឹងជាបុសា ពាក្យនៃអាត្មាអញណា ជាបុសា ពាក្យនោះ នឹងជាសេចក្តីបង្អែរតបិត្តនៃអាត្មាអញ សេចក្តីបង្អែរតបិត្តណារបស់អាត្មាអញ សេចក្តីបង្អែរតបិត្តនោះ នឹងជាអន្តរាយនៃអាត្មាអញ ។ ព្រោះតែសេចក្តីត្រិះរិះយ៉ាងនេះ ឱនជាបុគ្គលនោះមិនអះអាងថា នេះជាកុសលមិនអះអាងថា នេះជាអកុសលទេឬទ្បើយ ព្រោះខ្លាចបុសាវាទ ព្រោះខ្ពើមបុសាវាទ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ។ ក៏ដល់នូវការចុះវាចាចោះសំដី មិនឲ្យស្ងាត់ពាក្យថា សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែន(១) ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះក៏មិនមែន(២) ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃក៏មិនមែន(៣) ។

---

๑ អដ្ឋកថា ថា ត្រង់ពាក្យដែលថា យ៉ាងនេះក៏មិនមែន ជាភាក្យឃាត់អាការសួរណា ។ ដែលមិនមានទីកំណត់ ។ ๒ ត្រង់អាក្យថា យ៉ាងនេះក៏មិនមែន ជាភាក្យឃាត់សស្សតវាទ ធំ ពាក្យពោលថា លោកទៀង ( បញ្ច: ๒๗, ๒๘, ๒๙, ๓๐ ) ។ ๓ ត្រង់ពាក្យថាយ៉ាងដទៃក៏មិនមែន ជាពាក្យឃាត់ឯកច្ចសស្សតវាទ និងឯកច្ចអសស្សតវាទ ធំពាក្យថា លោកទៀងខ្លះ មិនទៀងខ្លះ(បញ្ច: ๓๑, ๓๒, ๓๓, ๓๔ ) ។

โนเจตัง เม โน ๆ โน โนเจตัง เม โนเต ๆ สัง

กิญฺจาเร ปาปกัง ทุกฺกฏัง อาคชฺเช ยัง อาวุโส ฆาเต

สมณพฺราหฺมณา อมฺหากัญฺเจวิเมสัญฺจ สพฺเพสัง ปญฺหัง

ปุฏฺฐา สมานา ภควาโรเจปิ อาปชฺชติ อมฺหากัญฺเจวิเมสัญฺจ ๆ

(๒๐) ตุมฺเหยเย ๆ เหวญฺเจ สมณพฺราหฺมณา

กิมาคชฺช กิมาวุโส อมฺหากัญฺเจวิเมสัญฺจ สพฺเพสัง ปญฺหัง

ปุฏฺฐา สมานา ภควาโรเจปิ อาปชฺชติ อมฺหากัญฺเจวิเมสัญฺจ ๆ

๕๓ กิญฺจาเร ฆาเตหฺยา สมณา วา พฺราหฺมณา วา

สัง กุสลสฺส ยถาภูตัง ญาณัง นตฺถีติ สัง อกุสล-

สฺส ยถาภูตัง ญาณัง นตฺถีติ ๆ ตสฺส วาโท เหตัง

อหัง เจ สัง กุสลสฺส ยถาภูตัง ญาณัง นตฺถีติ

សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនកំពេ(១) ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនកំពេ កំមិនមែនដែរ(២) ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ តាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះ ។ កំដល់ទូវការប្តោះវាចាប្តោះសំដី មិនឲ្យស្ទាប់ពាក្យ ។ ។

(៤០) ក្នុងហេតុទី ២ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ តាលបើមានអ្នកណាមួយសាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះ ។ កំដល់ទូវការប្តោះវាចាប្តោះសំដី មិនឲ្យស្ទាប់ពាក្យ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ ។ បុគ្គលនោះតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា ការអ្វីមិនដឹងតាមពិតថា នេះជាកុសល

---

១ ត្រង់ពាក្យថា សូន្យកំមិនមែនជាពាក្យឃាត់ខ្លួនទេវាទ តំពាក្យថា សត្វស្លាប់ទៅសូន្យមិនកើតទៀត ។ ២ ត្រង់ពាក្យថា មិនសូន្យកំមិនមែន ជាពាក្យឃាត់តក្តីភាទ តំពាក្យថា សត្វស្លាប់ទៅ មិនមែនជាមាន មិនមែនជាគ្មាន ។

នំ អកុសលន្តិ យថាភូតំ ឧប្បដាជានាមិ អហាញ្ញេ
ខោ(1) បន នំ កុសលន្តិ យថាភូតំ អប្បដានន្តោ
នំ អកុសលន្តិ យថាភូតំ អប្បដានន្តោ នំ
កុសលន្តិ ភ ព្យាករេយ្យំ នំ អកុសលន្តិ ភ ព្យា-
ករេយ្យំ តន្ត មេ អស្ស ជន្តោ ភ ភតោ ភ ឆោសោ ភ
បដិយោ ភ យន្ត មេ អស្ស ជន្តោ ភ ភតោ ភ ឆោសោ
ភ បដិយោ ភ តំ មមស្ស ខុថាធានំ យំ មមស្ស ខុ-
ថាធានំ សោ មមស្ស វិឃាតោ យោ មមស្ស វិឃាតោ
សោ មមស្ស អន្តរាយោតំ ។ នំ សោ ខុថាធានភយា
ខុថាធានបរិជេគុច្ឆា នេវំ កុសលន្តិ ព្យាករោតំ
ន បនំ អកុសលន្តិ ព្យាករោតំ តន្ត តន្ត បញ្ហំ
បុដ្ឋោ សមាតោ ភថាវិក្ខេបំ អាបជ្ជតំ អមរាវិក្ខេបំ
ឯវន្តិបំ(2) មេ ឆោ ។ តថាតិបំ មេ ឆោ ។ អញ្ញាថាតំ-
បំ មេ ឆោ ។ ឆោតិបំ មេ ឆោ ។ ឆោ ឆោតិបំ មេ

---

1 ឱ. អហាញ្ញេវ ខោ ។ 2 ឱ. ឯវម្បិ ។

ព្រហ្មជាលសូត្រ ការកំណត់នូវបំណែកនៃខន្ធ៣ជាដើម ប្រកបដោយអមរាវិរក្ខេបទិដ្ឋិ

មិនដឹងតាមពិតថា នេះជាកុសល កាលបើអាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលយ៉ាងនេះហើយ ទើបអះអាងថា នេះជាកុសល ឬទើបអះអាងថា នេះជាអកុសល ឆន្ទៈក្តី រាគៈក្តី ទោសៈក្តី បដិឃៈ(១)ក្តី នៃអាត្មាអញទើបមានក្នុងរឿងព័ន្ធណា ឆន្ទៈក្តី រាគៈក្តី ទោសៈក្តី បដិឃៈក្តី នៃអាត្មាអញទើបមានក្នុងរឿងព័ន្ធនោះ ធម្មជាតមានឆន្ទៈជាដើមនោះ ជាឧបាទានរបស់អាត្មាអញ ធម៌ណាជាឧបាទាននៃអាត្មាអញ ធម៌នោះ ទើបជាសេចក្តីចង្អៀតចង្អល់ នៃអាត្មាអញ ធម៌ណាជាសេចក្តីចង្អៀតចង្អល់របស់អាត្មាអញ ធម៌នោះទើបជាអន្តរាយ នៃអាត្មាអញ ។ ព្រោះសេចក្តីត្រិះរិះដូច្នេះ ឋានជាបុគ្គលនោះ មិនអះអាងថា នេះជាកុសល មិនអះអាងថា នេះជាអកុសលឡើយ ព្រោះខ្លាចឧបាទាន ព្រោះខ្លឹមឧបាទាន កាលបើមានអ្នកណាមួយ សួរប្រស្នាក្នុងកុសលទើបអកុសលនោះ ។ ក៏ដល់នូវការចុះរាថាចុះសំដី មិនឲ្យស្ទាប់ពាក្យថា សេចក្តីយល់ឃើញនៃខ្ញុំថា យ៉ាងនេះ ក៏មិនមែន ។ សេចក្តីយល់ឃើញនៃខ្ញុំថាយ៉ាងនោះ ក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងដែរ ក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថាមិនមែនក៏ទេ ។ សេចក្តីយល់ឃើញរបស់ខ្ញុំ

---

១ អដ្ឋកថាថា សេចក្តីត្រេកអរមានកំឡាំងច្រើន ហៅ ឆន្ទៈ សេចក្តីត្រេកអរមានកំឡាំងក្លា ហៅ រាគៈ សេចក្តីក្រោធមានកំឡាំងច្រើន ហៅ ទោសៈ សេចក្តីក្រោធមានកំឡាំងក្លា ហៅ បដិឃៈ ។

ฌตฺตา ฯ สนฺติ ภิกฺขเว เอเกจฺเจ ปาปกา อกุสลา ธมฺมา
ยาหิ สมณพฺราหฺมณา อเนกวิหิตาหิ ตณฺหาวิจริตาหิ ตตฺถ ตตฺถ
ปญฺหาปุจฺฉา สมาธา ภวาภวเหตุ อาปชฺชิตฺวา อเนกวิหิตา ฯ

(๔๑) ตตฺถเย จ เกจิ สมณพฺราหฺมณา
กามาสฺวาทา กามารฺภา อเนกวิหิตา ตตฺถ ตตฺถ ปญฺหา
ปุจฺฉา สมาธา ภวาภวเหตุ อาปชฺชิตฺวา อเนกวิหิตา ฯ
สนฺติ ภิกฺขเว เอเกจฺเจ สมณา จ พฺราหฺมณา จ สนฺตี
กุสลนฺติ ยถาภูตํ อปฺปชานตา สนฺตี อกุสลนฺติ
ยถาภูตํ อปฺปชานตา ฯ ตสฺส ฆาตาย หิตาย สุขาย
สนฺตี กุสลนฺติ ยถาภูตํ อปฺปชานตา สนฺตี อกุส-
ลนฺติ ยถาภูตํ อปฺปชานตา อหาเนน เขมี[๑] ปน สนฺตี
กุสลนฺติ ยถาภูตํ ปชานนฺตา สนฺตี อกุสลนฺติ
ยถาภูตํ ปชานนฺตา สนฺตี กุสลนฺติ จ ฌาก-
เรยฺยุ สนฺตี อกุสลนฺติ จ ฌาเกเรยฺยุ สนฺตี หิ เขมี
สมณพฺราหฺมณา ปฏิสลฺลานา อิทมตฺถา กตปรปฺปจฺจยา
จ เต[๒] ภิกฺขเว ภูตา ตจฺฉา ตถา อวิตถา

๑ ฉ. อหาเนเนว เขมี ฯ ๒ ฉ. จ ฯ

ថា មិនមែនក៏ទេ ក៏មិនមែនដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុ
ទី ២ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ
អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនិង
អកុសលនោះៗហើយ ក៏ដល់នូវការប្រោះរាចាប្រោះសំដីមិនឲ្យស្ងាប់ពាក្យ។

(៤១) ក្នុងហេតុទី ៣ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើនជា
អ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា
ក្នុងកុសលនិងអកុសលនោះៗហើយ ក៏ដល់នូវការប្រោះរាចា ប្រោះសំដី
មិនឲ្យស្ងាប់ពាក្យ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំង
ឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មិនដឹងតាម
ពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ ។ បុគ្គលនោះ
រមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនដឹងតាមពិតថា នេះជា
កុសល មិនដឹងតាមពិតថានេះជាអកុសលឡើយ កាលបើអាត្មាអញមិនដឹង
តាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលដូច្នេះហើយ
ទើបអះអាងថា នេះជាកុសលក្តី ទើបអះអាងថា នេះជាអកុសលក្តី ក្រែង
មានសមណព្រាហ្មណ៍ទាំងឡាយជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិតដឹងច្បាស់
នូវវាទៈរបស់អ្នកដទៃ អាចទំលាយនូវទិដ្ឋិ របស់បុគ្គលដទៃបាន ដោយ
កំភ្លាំងប្រាជ្ញារបស់ខ្លួន មានសភាពដូចជាខ្មាន់ធ្នូជាអ្នកបាញ់ភេមគ្រាយ(១)

---

១ សព្វនេះ ប្រែថា មានសភាពដូចខ្មាន់ធ្នូ ជាអ្នកបាញ់ភេមចុងកន្ទុយសត្វ ដូច្នេះក៏បាន ។

ឯដ្ឋកតាឯ តេ មំ តត្ត សមនុយុញ្ជេយ្យុំ សមនុក្កា-
ហេយ្យុំ សមនុភាសេយ្យុំ យេ មំ តត្ត សមនុយុញ្ជេ-
យ្យុំ សមនុក្កាហេយ្យុំ សមនុភាសេយ្យុំ តេសាហំ
ន សម្បាយេយ្យំ(๑) យញ្ហាហំ(๒) ន សម្បាយេយ្យំ
សោ មមស្ស វិឃាតោ យោ មមស្ស វិឃាតោ សោ
មមស្ស អន្តរាយោតិ ។ ឥតិ សោ អនុយោគក-
យា អនុយោគបរិជគុប្បា នេវំធំ កុសលន្តិ ព្យាក-
រោតិ ន បនិទំ អកុសលន្តិ ព្យាករោតិ តត្ត តត្ត
បញ្ហំ បុដ្ឋោ សមានោ ឯថាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ
ឯវន្តិបិ មេ នោ ។ តថាតិបិ មេ នោ ។ អញ្ញថាតិបិ មេ
នោ ។ នោតិបិ មេ នោ ។ នោ នោតិបិ មេ នោតិ ។

---

๑ សម្បាហេយ្យំ សម្បាបេយ្យំ សម្បាយេយ្យំ សម្បាទេយ្យំ ។ ๒ ម. យេសាហំ ។

សមណព្រាហ្មណ៍ទាំងនោះ គប្បីសាកសួរ គប្បីដេញសួរ គប្បីសួរដេញដោល ចំពោះអាត្មាអញ ក្នុងកុសលនឹងអកុសលនោះ (បើ) សមណព្រាហ្មណ៍ណា គប្បីសាកសួរ គប្បីដេញសួរ គប្បីសួរដេញដោល ចំពោះអាត្មាអញ ក្នុងកុសលនឹងអកុសលនោះ អាត្មាអញបុគ្គលជានឹងមិនអាចដោះស្រាយ នូវប្រស្នារបស់ពួកសមណព្រាហ្មណ៍នោះបានទេ បើអាត្មាអញ មិនអាចនឹងដោះស្រាយ នូវប្រស្នាដោយហេតុណាហើយ ហេតុនោះនឹងជាសេចក្តីចង្អៀតចិត្ត នៃអាត្មាអញ ធម៌ណាជាសេចក្តីចង្អៀតចិត្តរបស់អាត្មាអញ ធម៌នោះនឹងជាអន្តរាយ នៃអាត្មាអញ។ ព្រោះសេចក្តីត្រិះរិះយ៉ាងនេះ បានជាបុគ្គលនោះ មិនអះអាងថា នេះជាកុសល មិនអះអាងថា នេះជាអកុសល ព្រោះខ្ជិចពាក្យសួរដេញដោល ព្រោះធុញថប់នឹងពាក្យសួរដេញដោល ការលើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ។ ហើយ ក៏ដល់នូវការចុះជាថា ចុះសំដី មិនឲ្យស្អាប់ពាក្យថា សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះ ក៏មិនមែន។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះ ក៏មិនមែន។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃ ក៏មិនមែន។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ក៏មិនមែនដែរ។

ឥទំ កត្វា វេ តតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា ឋបារាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។

(៤២) ឧត្តុត្តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា ឋបារាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។ ឥធ កត្វា វេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា មន្ទោ ហោតិ មោមូហោ ។ សោ មន្ទត្តា មោមូហត្តា តត្ថ តត្ថ បញ្ហំ បុដ្ឋោ សមានោ ឋបារាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ អត្ថំ បរោ លោកោតិ ឥតិ ចេ មំ បុច្ឆសិ អត្ថំ បរោ លោកោតិ ឥតិ ចេ មេ អស្ស អត្ថំ បរោ លោកោតិ ឥតិ តេ ន(១) ឮកវេយ្យំ ឯវន្តិបិ មេ នោ ។ តថាតិបិ មេ នោ ។

---

១ ម. ម. ពេ ន ។

ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះៗ ហើយ ក៏ដល់នូវការចោះវាចា ចោះសំដី មិនឲ្យស្ទាប់ពាក្យ ។

(៤២) ក្នុងហេតុទី ៤ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះៗ ហើយ ក៏ដល់នូវការចោះវាចា ចោះសំដី មិនឲ្យស្ទាប់ពាក្យ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាមនុស្សមានប្រាជ្ញាទន់ ជាមនុស្សល្ងង់ខ្លៅ ។ បុគ្គលនោះឯងហេតុតែមានប្រាជ្ញាទន់ ហេតុតែល្ងង់ខ្លៅ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះៗហើយ ក៏ដល់នូវការចោះវាចា ចោះសំដី មិនឲ្យស្ទាប់ពាក្យថា បើអ្នកសួរខ្ញុំថា លោកខាងមុខមានឬទេ បើសេចក្តីយល់ឃើញរបស់ខ្ញុំយ៉ាងនេះថា លោកខាងមុខមាន ខ្ញុំនឹងមិនអះអាងដល់អ្នកថា លោកខាងមុខមាន (ម្ល៉េចបាន) សេចក្តីយល់ឃើញរបស់ខ្ញុំថាយ៉ាងនេះក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះ ក៏មិនមែន ។

អញ្ញាតំបិ មេ នោ ។ នោតំបិ មេ នោ ។ នោ នោតំបិ
មេ នោ ។ ន តំ បភៃ លោកោ ។ បេ ។ អតំ ច ន តំ ច
បភៃ លោកោ ។ នេវតំ ន ន តំ បភៃ លោកោ ។ អតំ
សតា ឌិបចាតំកា ។ ន តំ សតា ឌិបចាតំកា ។ អតំ
ច ន តំ ច សតា ឌិបចាតំកា ។ នេវតំ ន ន តំ សតា
ឌិបចាតំកា ។ អតំ សុកតទុក្កដានំ កម្មានំ ផលំ
វិចាកោ ។ ន តំ សុកតទុក្កដានំ កម្មានំ ផលំ វិចា-
កោ ។ អតំ ច ន តំ ច សុកតទុក្កដានំ កម្មានំ ផលំ
វិចាកោ ។ នេវតំ ន ន តំ សុកតទុក្កដានំ កម្មានំ ផលំ
វិចាកោ ។ ហោតំ តថាគតោ បរម្មរណា ។ ន ហោតំ ត-
ថាគតោ បរម្មរណា ។ ហោតំ ច ន ច ហោតំ តថាគតោ
បរម្មរណា ។ នេវ ហោតំ ន ន ហោតំ តថាគតោ

សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងដូចនេះ ក៏មិនមែន ។ សេចក្តីយល់ឃើញ
របស់ខ្ញុំថា មិនមែនក៏ទេ ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ក៏មិន
មែនដែរ ។ បើអ្នកសួរខ្ញុំថា លោកខាងមុខមិនមានឬ ។បេ ។ លោកខាង
មុខមានខ្លះ មិនមានខ្លះឬ ។ លោកខាងមុខមានក៏មិនមែន មិនមានក៏មិន
មែនឬ ។ សត្វទាំងឡាយ ដែលមានកំណើតជាឧបបាតិកៈមានឬ ។ សត្វ
ទាំងឡាយ ដែលជាឧបបាតិកៈមិនមានឬ ។ សត្វទាំងឡាយ ដែលជាឧប-
បាតិកៈមានខ្លះ មិនមានខ្លះឬ ។ សត្វទាំងឡាយ ដែលជាឧបបាតិកៈមានក៏
មិនមែន មិនមានក៏មិនមែនឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វ
ធ្វើល្អនឹងអាក្រក់មានឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វ
ធ្វើល្អនឹងអាក្រក់មិនមានឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វ
ធ្វើល្អនឹងធ្វើអាក្រក់មានខ្លះ មិនមានខ្លះឬ ។ ផលវិបាករបស់កម្មទាំងឡាយ
ដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មានក៏មិនមែន មិនមានក៏មិនមែនឬ ។
សត្វលុះរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ កើតទៀតឬ ។ សត្វ
លុះរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតឬ ។ សត្វលុះ
រំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ កើតទៀតខ្លះ មិនកើតទៀតខ្លះឬ ។
សត្វលុះរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ កើតទៀត ក៏មិនមែន

ปรมฺมุขาตเ ฯตเ เจ มิ ปุคฺคเล ฯ เนว หิเตน น
หิเตน ตถาคเต ปรมฺมุขาตเ ฯตเ เจ เม อสฺส เนว
หิเตน น หิเตน ตถาคเต ปรมฺมุขาตเ ฯตเ เต
น(๑) ฌายกเยยฺย ฐวณฺณิมิ เม เอเต ฯ ตถาตมิ เม เอเต ฯ
อภาถาตมิ เม เอเต ฯ เอตมิ เม เอเต ฯ เอ เอตมิ
เม เอเตเต ฯ ฯนิ ภิกฺขเว ตถาคตสฺส หานิ ยิ อาคมฺม ยิ
อาวฺห ฯเค สมณพฺราหฺมณา อมภาวิกฺขิตกา ตจฺ
ตจฺ ปญฺหิ ปุฏฺา สมาน ภาถาวิกฺขิ อาปชฺชนฺติ อมภา-
วิกฺขิ ฯ ฯเมหิ เข เต ภิกฺขเว สมณพฺราหฺมณา
อมภาวิกฺขิตกา ตจฺ ตจฺ ปญฺหิ ปุฏฺา สมาน ภาถา-
วิกฺขิ อาปชฺชนฺติ อมภาวิกฺขิ ถจฺฉหิ วจฺฉหิ ฯ
เย หิ เกจิ ภิกฺขเว สมณา ภ พฺราหฺมณา ภ
อมภาวิกฺขิตกา ตจฺ ตจฺ ปญฺหิ ปุฏฺา สมาน

๑ เต ฉนฺทิ เต ฆาตินิ ฌาเย ฯ

មិនកើតទៀតក៏មិនមែនឬ ។ បើសេចក្តីយល់ឃើញរបស់ខ្ញុំនឹងមានដូច្នេះថា សត្វលុះរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ខ្ញុំនឹងមិនអះអាងដល់អ្នកថា សត្វលុះរំលាងខន្ធទៅ ខាងមុខអំពីសេចក្តីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន (ម្តេចបាន) សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះ ក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា ហ៊ាងនោះ ក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃ ក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនទេ ក៏មិនមែនដែរ ។ ម្នាលភិក្ខុ ទាំងឡាយនេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា ក្នុងកុសលនឹងអកុសលនោះ ។ ហើយ ក៏ដល់នូវការចុះរាថាចុះសំដីមិនឲ្យស្ងាប់ពាក្យ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះឯង ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា ក្នុងកុសលនឹងអកុសលនោះ ។ ក៏ដល់នូវការចុះរាថាចុះសំដីមិនឲ្យស្ងាប់ពាក្យ ដោយហេតុ ៤ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាទីមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា ក្នុងកុសលនឹងអកុសល

នោះៗហើយ ក៏ដល់នូវការចោះពាចោះសំដីមិនឲ្យស្ទាប់ពាក្យ សមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ រមែងដល់នូវការចោះពាចោះសំដី មិនឲ្យស្ទាប់ពាក្យ ដោយហេតុ ៤ យ៉ាងនេះឯង ឬក៏បណ្តាហេតុទាំង៤យ៉ាងនោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិតដោយធម៌ទាំងឡាយណា ។

(៤៣) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ គឺអ្នកបញ្ញត្តនូវខន្ធទាំងឡាយថា កើតឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ដែលជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តនូវខន្ធទាំងឡាយថា កើតឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ មានពួកទេវតាឈ្មោះថាអសញ្ញីសត្វ គឺសត្វមិនមានសញ្ញា ទេវតាទាំងនោះ លុះមានសញ្ញាកើតឡើងហើយ ក៏ច្យុតចាកពួកទេវតានោះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះមានប្រាកដដ្រៃដ៏សេចក្តីថា សត្វណាមួយច្យុតចាកពួកទេវតានោះ មកកាន់អត្តភាពជាមនុស្សនេះ កាលដែលមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏បេញ្ចាចាកផ្ទះចូលទៅកាន់ផ្ទះ លុះបេញ្ចាចាកផ្ទះចូលទៅកាន់ផ្ទះហើយ

ភថាវាក្កេបំ អាបជ្ជន្តិ អមរាវិក្ខេបំ សព្ពេ តេ ឥមេហេវ ចតូហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន ឧត្តិំ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៤៣) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា តក្កិមាតក្ក តក្កិមារុភ អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ ។ សន្តិ ភិក្ខវេ អសញ្ញីសត្តា[1] នាម ទេវា សញ្ញុប្បាទា ច បន តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិវដ្តតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគារិយំ បព្ពជតិ អគារស្មា អនគារិយំ បព្ពជិតោ

---

๑ ម. អសញ្ញសត្តា ។

សមាធោ អាតប្បមត្ថាយ បធានមត្ថាយ អនុយោគមត្ថា-
យ អប្បមាទមត្ថាយ សម្មាមនសិការមត្ថាយ តថារូបំ
ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ សញ្ញប្ប-
ទំ អនុស្សរតិ តតោ បរំ ជានុស្សរតិ ។ សោ ឯវមាហ
អដ្ឋសមុប្បន្នោ អត្តា ច លោកោ ច ។ តំ កិស្ស
ហេតុ ។ អហំ ហិ ឥមេ ជាហោសឹ សោម្ហិ ឯតរហិ
អហុត្វា សន្តតាយ បរិណាតោតិ ។ ឥធំ ភិក្ខវេ បឋមំ
ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា
អដ្ឋសមុប្បន្និកា អដ្ឋសមុប្បន្នំ អត្តានញ្ច លោ-
កញ្ច បញ្ញបេន្តិ ។

(៤៤) ទុតិយេ ច ភោន្តោ សមណព្រាហ្មណា
កេវលាគម្ម កេវលារព្ភ អដ្ឋសមុប្បន្និកា អដ្ឋសមុប្បន្នំ
អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចេ

អាស្រ័យនូវការព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាម ជាគ្រឿងប្រកបរឿយ ។ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបានទូរចេតោសមាធិ តាមបែបផែន(នៃចិត្តរបស់យោគី)កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏លើកបានកំណត់ត្រឹមកាលដែលខ្លួនមានសញ្ញាកើតឡើង មិនបានរលឹកហួសអំពីកំណត់នោះឡើយ ។ បុគ្គលនោះពោលយ៉ាងនេះថា ខ្លួនទើសលោកកើតឡើងដោយឥតហេតុ ។ ការពោលដូច្នោះតើព្រោះហេតុអ្វី ។ ព្រោះថា អាត្មាអញ កន្លងកាលពីមុន ក៏មិនបានកើតទេ កើតតែកន្លងកាលឥឡូវនេះ តទៅមុខទៀត ក៏មិនបានកើតដែរ ព្រោះបង្អោនចិត្តទៅ ដើម្បីជាអ្នកសូន្យរម្ងាប់ហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តនូវខ្លួនទើសលោកថា កើតឡើងដោយឥតហេតុ ។

(៤៤) កន្លងហេតុទី២ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តនូវខ្លួនទើសលោកថា កើតឡើងដោយឥតហេតុ ព្រោះអាស្រ័យអ្វី ប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល

សមណោ វា ព្រាហ្មណោ វា តក្កី ហោតិ វីមំសី ។ សោ តក្កបរិយាហតំ វីមំសានុចរិតំ សយំ ញាដំ ភាណំ វវមោ-
ហា អធិច្ចសមុប្បន្នោ អត្តា ច លោកោ ចាតិ ។ ឥធំ តិក្ខវេ ឯកច្ចស្ស ហោតិ យំ អាគម្ម យំ អារព្ភ ឯកេ
សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥមេហិ ខោ តេ
តិក្ខវេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ច-
សមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ ។
យេ បិ តេ តិក្ខវេ សមណា វា ព្រាហ្មណា វា
អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច
បញ្ញបេន្តិ សព្វេ តេ ឥមេហេវ ទ្វីហិ វត្ថូហិ ឯតេសំ
វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។បេ។ យេបិ
តថាគតស្ស យថាភូតំ វណ្ណំ សម្មា វទមានា
វទេយ្យុំ ។ ឥមេហិ ខោ តេ តិក្ខវេ សមណព្រាហ្មណា

ពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានសេចក្តីត្រិះរិះ
ពិចារណាជាប្រក្រតី ។ បុគ្គលនោះ ក៏និយាយពាក្យ ដែលខ្លួនស្រាវ
ជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា
ជាពាក្យកើតមានដោយបញ្ញា របស់ខ្លួនយ៉ាងនេះថា ខ្លួនទំនងលោកកើត
ឡើងដោយឥតហេតុ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២
ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ
អាស្រ័យ ក្រាបទូល ទើបបញ្ញត្តនូវខ្លួនទំនងលោកថា កើតឡើងដោយឥត
ហេតុ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រកប
ដោយអធិច្ចសមុប្បន្នទិដ្ឋិទាំងនោះ តែងបញ្ញត្តនូវខ្លួនទំនងលោកថា កើត
ឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង
ឡាយ សមណៈឬព្រាហ្មណ៍ឯណាមួយ ជាអ្នកប្រកបដោយអធិច្ចស.
មុប្បន្នទិដ្ឋិ បញ្ញត្តនូវខ្លួនទំនងលោកថា កើតឡើងដោយឥតហេតុ សមណ.
ព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ២ យ៉ាងនេះឯង
ឬក៏បណ្តាហេតុទាំងពីរនោះ ដោយហេតុណាមួយ មិនមានហេតុដទៃ
ក្រៅពីហេតុទាំង ២ យ៉ាងនេះឡើយ ។ បេ ។ ពួកជនកាលពោល
សរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយ
ណា ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះជាអ្នកប្រកប

បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋោ បុព្វន្តំ អារព្ភ អនេក-
វិហិតានិ អធិមុត្តិបធានានិ អភិវទន្តិ អដ្ឋារសហិ វត្ថូហិ ។
យេ ហិ កេចិ ភិក្ខវេ សមណា ច ព្រាហ្មណា ច
បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋោ បុព្វន្តំ អារព្ភ អនេក-
វិហិតានិ អធិមុត្តិបធានានិ អភិវទន្តិ សព្វេ តេ ឥមេហេវ
អដ្ឋារសហិ វត្ថូហិ ឯតេសំ ច អញ្ញតរេន នត្ថិ ឥតោ
ពហិទ្ធា ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ ឥមេ
ទិដ្ឋិដ្ឋានា ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ
ឯវំអភិសម្បរាយា តេ ។ តញ្ច តថាគតោ បជានាតិ
តតោ ច ឧត្តរិតរំ បជានាតិ តញ្ច បជានន្តំ ន បរាម-
សតិ ។ អបរាមសតោ ច ស្ស បច្ចត្តញ្ញេវ និព្ពុតិ វិទិតា

ដោយបុព្វន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវចំ-
ណែកនៃខន្ធខាងដើម ប្រារព្ធនូវចំណែកនៃខន្ធខាងដើម សំដែងនូវ
ចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុទាំង ១៨ នេះឯង ។ ម្នាល
ភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយ
បុព្វន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវចំណែកនៃខន្ធ
ខាងដើម ប្រារព្ធនូវចំណែកនៃខន្ធខាងដើម សំដែងនូវចំណែកនៃទិដ្ឋិ
ច្រើនប្រការ សមណព្រាហ្មណ៍ទាំងអស់នោះ រមែងសំដែងដោយហេតុ
ទាំង ១៨ នេះឯង ឬក៏បណ្តាហេតុទាំង ១៨ នុ៎ះ ដោយហេតុណាមួយ
មិនមានហេតុដទៃក្រៅពីហេតុទាំង ១៨ នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ
ព្រះតថាគតដឹងច្បាស់ នូវហេតុនៃទិដ្ឋិនោះដូច្នេះថា ហេតុនៃទិដ្ឋិទាំងឡាយ
នេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ រមែងមាន
គតិយ៉ាងនេះ មានការប្រព្រឹត្តិទៅ ក្នុងលោកខាងមុខយ៉ាងនេះ ។ ព្រះ
តថាគត ដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីលសមាធិនឹង
សព្វញ្ញុតញ្ញាណ) ដែលជាគុណជាត លើសលុបក្រៃលែងជាងនោះទៅ
ទៀតផង ។ កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រ-
កាន់ខុសឡើយ ។ មួយទៀត កាលបើព្រះតថាគតមិនបានប្រកាន់ខុស
ហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅ (នៃបញ្ចក្ខន្ធ)

វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីន-
វញ្ច នំសរណញ្ច យថាភូតំ ញត្វា ។ អនុបាទា វិមុត្តោ
តំក្ខណេ តថាគតោ ។ ឥមេ ខោ តេ តំក្ខណេ ជម្ពា
គម្ភក ឧច្ឆុសា ឧរុពោធា សត្តា បណីតា អតក្កាវចរ
និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ
អភិញ្ញា សច្ឆិកត្វា បវេទេតិ យេបិ តថាគតស្ស
យថាភុច្ចំ វណ្ណំ សម្ម វទមានា វេទេយ្យុំ ។

(៤៩) សច្ចំ តំក្ខណេ ភិក្ខវេ សមណព្រាហ្មណា អ-
បរន្តកប្បិកា អបរន្តានុទិដ្ឋោ អបរន្តំ អារព្ភ អនេក-
វិហិតានិ អធិមុត្តិបធានានិ អភិវទន្តិ ចតុព្ភិធ្យាសាយ
វត្តន្តិ ។ តេ ច ភោន្តោ សមណព្រាហ្មណា តំមាតម្ម

ដោយខ្លួនឯង តាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតទុក្ខ នៃវេទនាផង នូវសេចក្តីរសាត់ទៅ នៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសា របស់វេទនាផង នូវទោសរបស់វេទនាផង នូវគតិយោរលាស់ចេញនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុតាំងឡាយ ព្រះតថាគត ផុតស្រឡះហើយចាកតំណៃសព្រោះមិនប្រកាន់ (នូវធម៌ណាមួយ មានខន្ធជាដើម) ។ ម្នាលភិក្ខុតាំងឡាយ ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងហើយ អាចទំនឹងសំដែងបាននូវធម៌តាំងឡាយណា ពួកជនកាលពោលសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌តាំងឡាយណា ធម៌តាំងឡាយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌សូប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញ ទើបដឹងបាន ។

(៤៥) ម្នាលភិក្ខុតាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអបរន្តកប្បវាទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ។ នូវខន្ធជាចំណែកខាងមុខ (អនាគត) ប្រារព្ធខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែកនៃទិដ្ឋិប្រែនប្រការ ដោយហេតុ ៤៤ ។ ចុះពួកសមណព្រាហ្មណ៍

กตมาวฺหา อปรนฺตกปฺปิกา อปรนฺตานุทิฏฺโน อปรนฺต
อาวฺหา อเนกวิหิตาย อภิมุตฺตปทาย อกิวฑฺฒิ ตสฺ-
ฺสนฺตาเนวาย วตฺตนฺติ ฯ

(๔๖) สนฺติ เกจิ เวเก สมณพฺราหฺมณา ทุฏฺ-
ฐมายตนิกา สญฺญีวาทา ทุฏฺฐมายตนา สญฺญีมตฺตานิ(๑)
ปญฺญเปนฺติ สาธฺวสฺสมา วตฺตนฺติ ฯ เตปิ โข เอเต
สมณพฺราหฺมณา เตหิ เตหิ ทิฏฺฐมายตนิกา
สญฺญีวาทา ทุฏฺฐมายตนา สญฺญีมตฺตานิ ปญฺญเปนฺติ
สาธฺวสฺสมา วตฺตนฺติ ฯ ยถา หิ ตสฺส ปุริสสฺส ปุริ
สมาณา สญฺญีตานิ ปญฺญเปนฺติ ฯ เอวเมว ยถา หิ ตสฺส
ปุริสสฺส ปุริสมาณา สญฺญีตานิ ปญฺญเปนฺติ ฯ ยถา ปิ
เอวเมว ปิ อตฺตา โหตีติ ฯ เป ฯ เนวยถา นาปิ อตฺตา
โหตีติ ฯ อนฺตวา อตฺตา โหตีติ ฯ อนนฺตวา อตฺตา
โหตีติ ฯ อนฺตวา จ อนนฺตวา จ อตฺตา โหตีติ ฯ
เนวนฺตวา นานนฺตวา อตฺตา โหตีติ ฯ เอกตฺตสญฺญี อตฺตา

๑ ม. ทุฏฺฐมายตนิกา สญฺญีวาทา ทุฏฺฐมายตนา สญฺญี อตฺตานิ ฯ ฉ. สญฺญี อตฺตานิ ฯ

ដ៏ចំរើន ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រាថ្នាខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែក នៃទិដ្ឋិច្រើនប្រការ ដោយហេតុ ៤៤ តើព្រោះអាស្រ័យអ្វី ព្រោះប្រាថ្នាអ្វី ?

(៤៦) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយខន្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ(ប្រកាន់នូវខ្លួនថាគាលស្វាប់ទៅមានសញ្ញា) បញ្ញត្តនូវខ្លួនថា មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ១៦យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ជាអ្នកប្រកបដោយខន្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ១៦ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រាថ្នាអ្វី ? សមណព្រាហ្មណ៍ពួកនោះ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូប តែមិនមានរោគ គឺរឿង មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមិនមានរូប តាំងមិនមានរោគ មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះក៏មាន ។ បេ ។ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែនក៏មាន ។ ខ្លួនមានទីបំផុតក៏មាន ។ ខ្លួនមិនមានទីបំផុតក៏មាន ។ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះក៏មាន ។ ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែនក៏មាន ។ ខ្លួនមានសញ្ញ

ហោតំ ។ ឆាឧត្តសញ្ញី អត្តា ហោតំ ។ បរិត្តសញ្ញី អត្តា ហោតំ ។ អប្បមាណសញ្ញី អត្តា ហោតំ ។ ឯកន្តសុខី អត្តា ហោតំ ។ ឯកន្តទុក្ខី អត្តា ហោតំ ។ សុខទុក្ខី អត្តា ហោតំ ។ អទុក្ខមសុខី អត្តា ហោតំ អភេតោ បរំ មរណា សញ្ញីតំ ឧំ បញ្ញបេន្តំ ។ ឥមេហំ ខោ តេ តំក្ខវេ សមណព្រាហ្មណា ខុទ្ទមាយតនិកា សញ្ញីវាទា ខុទ្ទមាយតនា សញ្ញីមត្តានំ បញ្ញបេន្តំ សោឧច្ឆសមិ វត្តមិ ។ យេ ហិ កេចិ តំក្ខវេ សមណា វ ព្រាហ្មណា វ ខុទ្ទមាយតនិកា សញ្ញីវាទា ខុទ្ទមាយតនា សញ្ញីមត្តានំ បញ្ញបេន្តំ សព្វេ តេ ឥមេហេវ សោឧច្ឆសមិ វត្តមិ ឯតេសំ វ អញ្ញតរេន ឆន្តំ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៤៧) សន្តំ តំក្ខវេ ឯកេ សមណព្រាហ្មណា ខុទ្ទមាយតនិកា អសញ្ញីវាទា ខុទ្ទមាយតនា អសញ្ញីមត្តានំ បញ្ញបេន្តំ អដ្ឋមិ វត្តមិ ។ តេ ច ភោន្តោ

ព្រហ្មជាលសូត្រ ប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទ

ដូចគាត់មាន ។ ខ្លួនមានសញ្ញាផ្សេងគាត់មាន ។ ខ្លួនមានសញ្ញាយ៉ាងតិចក៏មាន ។ ខ្លួនមានសញ្ញានឹងប្រមាណមិនបានក៏មាន ។ ខ្លួនមានសេចក្តីសុខតែម្យ៉ាងក៏មាន ។ ខ្លួនមានទុក្ខតែម្យ៉ាងក៏មាន ។ ខ្លួនមានសុខនឹងទុក្ខច្រឡំគាត់មាន ។ ខ្លួនមិនមានទុក្ខមិនមានសុខទាំងមិនមានកេតមានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ១៦យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ សមណព្រាហ្មណ៍ទាំងអស់នោះ តែងបញ្ញត្តដោយហេតុ ១៦ យ៉ាងនេះឯង ឬក៏បណ្តាហេតុ ១៦ នោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគតតាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។

(៤៧) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមិនមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាង ។ ចុះពួកសមណៈ-

សមណព្រាហ្មណា តក្កិមាតម្ម តក្កិមាវត្ថុ ឧទ្ទមាយ-
តនិកា អសញ្ញីវាទា ឧទ្ទមាយតនា អសញ្ញិមត្តានំ
បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ រូបី អត្តា ហោតិ អរោគោ
បរំ មរណា អសញ្ញីតិ នំ បញ្ញបេន្តិ ។ អរូបី អត្តា ហោតិ
អរោគោ បរំ មរណា អសញ្ញីតិ នំ បញ្ញបេន្តិ ។ រូបី ច អរូបី
ច អត្តា ហោតិ ។បេ ។ នេវរូបី នារូបី អត្តា ហោតិ ។
អន្តវា អត្តា ហោតិ ។ អនន្តវា អត្តា ហោតិ ។
អន្តវា ច អនន្តវា ច អត្តា ហោតិ ។ នេវន្តវា នានន្តវា
អត្តា ហោតិ អរោគោ បរំ មរណា អសញ្ញីតិ នំ
បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្ម-
ណា ឧទ្ទមាយតនិកា អសញ្ញីវាទា ឧទ្ទមាយតនា
អសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ យេ ហិ
កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឧទ្ទមាយ-
តនិកា អសញ្ញីវាទា ឧទ្ទមាយតនា អសញ្ញិមត្តានំ
បញ្ញបេន្តិ សព្ពេ តេ ឥមេហេវ អដ្ឋហិ វត្ថូហិ ឯតេសំ

ព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកប្រកបដោយខន្តិមាយតនទិដ្ឋិ ជាអ-
ញ ញ្ញត្តប្បដិក្ខេបវាទ បញ្ញត្តនូវខន្ធថា មិនមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយ
ហេតុ ៨ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ សមណព្រាហ្មណ៍
ទាំងនោះ បញ្ញត្តនូវខន្ធនោះថា ខ្លួនមានរូប តែមិនមានរោគ មិនមាន
សញ្ញាខាងមុខអំពីសេចក្តីស្លាប់ ។ បញ្ញត្តនូវខន្ធនោះថា ខ្លួនមិនមានរូប
ទាំងមិនមានរោគ មិនមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ។ បញ្ញត្តនូវ
ខ្លួននោះថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះក៏មាន ។ បេ ។ ខ្លួនមានរូប
ក៏មិនមែន មិនមានរូបក៏មិនមែនក៏មាន ។ ខ្លួនមានទីបំផុតក៏មាន ។ ខ្លួន
មិនមានទីបំផុតក៏មាន ។ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះក៏មាន ។
ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន តែមិនមានរោគ មិន
មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណ-
ព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយខន្តិមាយតនទិដ្ឋិ ជាអសញ្ញីវាទ
បញ្ញត្តនូវខន្ធថា មិនមានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨
យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ
ជាអ្នកប្រកបដោយខន្តិមាយតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តនូវខន្ធថា មិន
មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ
រមែងបញ្ញត្តដោយហេតុ ៨ យ៉ាងនេះឯង ឬក៏បណ្តាហេតុ ៨ យ៉ាងនុ៎ះ

វា អញ្ញតរេន ឧត្តំ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(๒๘) សន្តំ ភិក្ខវេ វា តេ សមណព្រាហ្មណា ឧទ្ទមាឃតនិកា នេវសញ្ញានាសញ្ញាវាទា ឧទ្ទមាឃតនា នេវសញ្ញានាសញ្ញាមត្តានំ(๑) បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា តិមាគម្ម តិមារព្ភ ឧទ្ទមាឃតនិកា នេវសញ្ញានាសញ្ញាវាទា ឧទ្ទមាឃតនា នេវសញ្ញានាសញ្ញាមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ រូបី អត្តា ហោតិ អរោគោ បរំ មរណា នេវសញ្ញានាសញ្ញាមត្តានំ បញ្ញបេន្តិ ។ អរូបី អត្តា ហោតិ ។ បេ ។ រូបី ច អរូបី ច អត្តា ហោតិ ។ នេវរូបី នារូបី អត្តា ហោតិ ។ អន្តវា អត្តា ហោតិ ។ អនន្តវា អត្តា ហោតិ ។ អន្តវា ច អនន្តវា ច អត្តា ហោតិ ។

---

๑ ម. នេវសញ្ញានាសញ្ញាមត្តានំ ។ ម. នេវសញ្ញានាសញ្ញាមត្តានំ ។

ព្រហ្មជាលសូត្រ ប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ

ដោយហេតុណាមួយ មិនមានហេតុដទៃ ក្រៅពីនេះឡើយ ។ បេ ។ ពួកជនតាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឆ្ងាយណា ។

(៤៨) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន (មានសញ្ញាដូចជាគ្មានសញ្ញា គឺមានសញ្ញាដ៏ល្អិត) ខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាង ។ ប៉ុន្តែពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ សមណព្រាហ្មណ៍ពួកនោះ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូប តែមិនមានពេគ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមិនមានរូបក៏មាន ។ បេ ។ ខ្លួនមានរូបខ្លះ មិនមានរូបខ្លះក៏មាន ។ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែនក៏មាន ។ ខ្លួនមានទីបំផុតក៏មាន ។ ខ្លួនមិនមានទីបំផុតក៏មាន ។ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះក៏មាន ។

เนวฺหกา ฉาฉนฺทกา อตฺตา โหตเิ อเวเตา ปรมฺปรณา เนวสญฺญีนาสญฺญีนเิ ธ ปญฺญเปนฺติ ฯ ส เมหิ โข เต กิกฺขเว สมณพฺราหฺมณา ทุทฺทมายตนิกา เนวสญฺญีนาสญฺญีกา ทุทฺทมายตนา เนวสญฺญีนาสญฺญีมตฺตนิ ปญฺญเปนฺติ อชฺฌิ วตฺถุมิ ฯ ยเิ มหิ เกจิ กิกฺขเว สมณา ก พฺราหฺมณา ก ทุทฺทมายตนิกา เนวสญฺญีนาสญฺญีกา ทุทฺทมายตนา เนวสญฺญีนาสญฺญีมตฺตนิ ปญฺญเปนฺติ สเพฺว เต ส เมเหว อชฺฌิ วตฺถุมิ ฝเสนิ ก อญฺญตเรน นเตฺถ ส เต ตหิ ฯ เป ฯ ยเิ มหิ ตถาคตสฺส ยถากุกฺกุ วณฺณิ สมฺม วิชานาติ วเตเยฺย ฯ

(๒๙) สนฺเธ กิกฺขเว ฝเสเ สมณพฺราหฺมณา ทุเทฺทฐิกา สเต[๑] สตฺตสฺส ทุเทฺทสิ วินาสิ วิภวิ ปญฺญเปนฺติ สตฺตหิ วตฺถุมิ ฯ เต จ โขปนฺเน สมณพฺราหฺมณา ตถิมาคมฺม ตถิมาคฺย ทุเทฺทฐิกา สเต สตฺตสฺส ทุเทฺทสิ วินาสิ วิภวิ ปญฺญเปนฺติ สตฺตหิ

๑ ฉ สเตนิ ฌ วิญฺญตฺติ ฯ

ខ្ញុំមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន តែមិនមានរោគ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ។ ម្នាលកិកុតាំងឡាយ ពួកសមណព្រាហ្មណ៍តាំងនោះ ជាអ្នកប្រកបដោយទុដ្ឋមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ៨យ៉ាងនេះឯង ។ ម្នាលភិក្ខុតាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយទុដ្ឋមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ សមណៈឬព្រាហ្មណ៍តាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៨ យ៉ាងនេះឯង ឬក៏បណ្តាហេតុ ៨ យ៉ាងនុ៎ះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគតតាមសេចក្តីពិត ដោយធម៌តាំងឡាយណា ។

(๘๙) ម្នាលកិកុតាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាខ្ជុប្បទោសវាទ (អ្នកពោលថាជាចំសូន្យ) បញ្ញត្តនូវការជាចំសូន្យ នូវសេចក្តីវិនាសនូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយហេតុ៧យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះជាខ្ជុប្បទោសវាទ បញ្ញត្តនូវការជាចំសូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅដោយហេតុ៧

វត្តព្ពំ ។ ឥធ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ พุทฺโธ ภគวา ติ ។ โส อิมំ โลกំ สเทวกំ สมารกំ สพฺรหฺมกំ ปชំ สสมณพฺราหฺมณึ ปชาย สเทวมนุสฺสาย สยំ อภิญฺญา สจฺฉิกตฺวา ปเวเทติ ។ โส ธมฺมំ เทเสติ อาทิกลฺยาณំ มชฺเฌกลฺยาณំ ปริโยสานกลฺยาณំ สาตฺถំ สพฺยญฺชนំ เกวลปริปุณฺณំ ปริสุทฺธំ พฺรหฺมจริยំ ปกาเสติ ។ ตถารูปานं[1] อรหตานំ ทสฺสนំ สาธุ โหติ ។ ตถารูปา หิ โข อรหนฺโต อรหตฺตปฺปตฺติยา ธมฺมំ เทเสนฺติ ។ ตถารูปานំ อรหตานំ ทสฺสนเมว ปฏิลาภาย ปฏิปชฺชติ ។ ตถารูปานំ อรหตานំ ทสฺสนเมว ปฏิลาภาย ปฏิปชฺชมาโน ทิฏฺเฐว ธมฺเม ปญฺจหากาเรหิ ถามวา ปฏิลาภี โหติ

យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានពាក្យយ៉ាងនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា នែអ្នកដ៏ចំរើន ខ្លួននេះមានរូប ប្រកបដោយមហាភូតរូប៤ កើតអំពីមាតាបិតា លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងមិនមាន នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននោះឯង ឈ្មោះថាដាច់សូន្យជាប្រពៃជ ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមាន+នុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួន+នុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្លួននេះមិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ នែអ្នកដ៏ចំរើន មានខ្លួនដទៃទៀត មានរូបជាទិព្វ ជាកាមាវចរទេវតា (ត្រាច់ទៅកាន់កាមភព) មានភក្ខុដ្ឋិក្តីរាកហារជាចំណី អ្នកមិនដឹងមិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំទើបដឹងទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯង លុះមានកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាសខាងមុខ

ฉ ภោតេ ปរំ มរណา ฌ្ញាវតា ខោ ភោ អយំ អត្តា
សញ្ញ សមុច្ឆិជ្ជោ ភោតីតិ ។ ឥត្ថេកេ សតេ សត្តស្ស
ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញេ ឯវមាហ
អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វេទេសិ នេសោ
ឧត្តិតិ វិនាម នោ ឆ ខោ ភោ អយំ អត្តា ឥត្តាវតា
សញ្ញ សមុច្ឆិជ្ជោ ភោតេ អត្ថិ ខោ ភោ អញ្ញោ អត្តា
ឱឡារិកោ មនោមយោ សព្វង្គប្បច្ចង្គី អហីនិន្ទ្រិយោ តំ ត្វំ
ឆ ជានាសិ ឆ បស្សសិ តមហំ ជានាមិ បស្សាមិ សោ
ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ
ឆ ភោតេ បរម្មរណា ឥត្តាវតា ខោ ភោ អយំ អត្តា
សញ្ញ សមុច្ឆិជ្ជោ ភោតីតិ ។ ឥត្ថេកេ សតេ សត្តស្ស
ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញេ ឯវមាហ អត្ថិ
ខោ ភោ ឯសោ អត្តា យំ ត្វំ វេទេសិ នេសោ ឧត្តិតិ

អំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ នៃអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមាន ក៏មានម្ល៉េះ ឯខ្ញុំមិននិយាយថាខ្លួនមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្លួននេះមិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះទៀត នែអ្នកដ៏ចំរើន មានខ្លួនដទៃទៀត មានរូបជាទីតាំង សម្រេចដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកទាប គឺមានឥន្ទ្រិយពេញលេញ អ្នកមិនដឹង មិនឃើញនូវខ្លួននោះទៀត ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងជាដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថា

វាទាមិ ខោ ឯ ខោ កោ អយំ អត្តា រូបាវតា សញ្ញី
សមនុស្សោ ហោតិ អនុ ខោ កោ អញ្ញោ អត្តា សព្វសោ
រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា
នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ(๑)
អាកាសានញ្ចាយតនូបគោ យំ(๒) នូ ន ជានាមិ ន
បស្សាមិ តមហំ ជានាមិ បស្សាមិ សោ ខោ កោ អត្តា
យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ
បរម្មរណា រូបាវតា ខោ កោ អយំ អត្តា សញ្ញី សមនុស្សោ
ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ
វិភវំ បញ្ញាបេន្តិ ។ តមញ្ញេ វាមាហ អតុ ខោ កោ រូបាសោ
អត្តា យំ នូ វទេសិ នេសោ ន ខ្វត្ថិ វាទាមិ ខោ ឯ ខោ
កោ អយំ អត្តា រូបាវតា សញ្ញី សមនុស្សោ ហោតិ អនុ

---

๑ ឧ. ឧកាសោតិ ។ ๒ ឧ. ម. តំ ។

ខ្លួនមានន្ទុះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួនន្ទុះមិនមានទេ នៃអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ នៃអ្នកដ៏ចំរើន មានខ្លួនដទៃដែលចូលទៅកាន់អាកាសានញ្ចាយតនភព មានអារម្មណ៍ថាអាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា គឺសេចក្តីសំគាល់ក្នុងរូប ព្រោះអស់ទៅនៃបដិឃសញ្ញា គឺសេចក្តីសំគាល់ ក្នុងអារម្មណ៍ដែលជាទីខ្ពាំងខ្ពប់ចិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញា គឺសេចក្តីសំគាល់ក្នុងអារម្មណ៍ផ្សេង ៗ ដោយសព្វគ្រប់ អ្នកមិនដឹង មិនឃើញនូវខ្លួនណា ខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នៃអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងជាដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ នៃអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ។ សមណព្រាហ្មណ៍ ពួកមួយបានត្ទូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា នៃអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមានន្ទុះ ក៏មានមែន ឯខ្ញុំមិននិយាយថាខ្លួនន្ទុះមិនមានទេ នៃអ្នកដ៏ចំរើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ

ខោ កោ អញ្ញោ អត្តា សព្វសោ អាកាសានញ្ចាយតនំ
សមតិក្កម្ម អនន្តំ វិញ្ញាណន្តំ វិញ្ញាណញ្ចាយតនូបគោ
យំ ភុំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ
បស្សាមិ សោ ខោ កោ អត្តា យតោ កាយស្ស ភេទា
ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ
កោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេ-
កេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។
តមញ្ញោ ឯវមាហ អត្ថិ ខោ កោ ឯសោ អត្តា យំ ត្វំ
វទេសិ នេសោ ឧត្តិតិ វទាមិ ខោ ច ខោ កោ អយំ
អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ កោ
អញ្ញោ អត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម
ឥត្តំ តំញ្ញេតិ អាកិញ្ចញ្ញាយតនូបគោ យំ ភុំ ន ជានាសិ
ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ
កោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ

នៃអ្នកដ៏ចំរើន មានខ្លួនដទៃ ដែលកន្ទុះបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនកព មានអារម្មណ៍ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ អ្នកមិនដឹង មិនឃើញនូវខ្លួនណា ខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នៃអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនមែនតែទៀតទេ ឬនៃអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឈ្មោះថាដាសការៈដាច់សូន្យដោយពិត ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្ត នូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមានន្ទុះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួនន្ទុះមិនមានទេ នែអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែន ជាដាសការៈដាច់សូន្យ ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ នែអ្នកដ៏ចំរើន មានខ្លួនដទៃដែលកន្ទុះបង់នូវវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនកព មានអារម្មណ៍ថា អ្វីតិចតួចក៏មិនមានដូច្នេះ អ្នកមិនដឹង មិនឃើញនូវខ្លួនណា ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នៃអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស

ន ហោតិ បរម្មរណា ឯត្តាវតា ខោ កោ អយំ អត្តា សម្មា
សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ
វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញេ ឯវមាហ អត្ថិ ខោ
កោ ឯសោ អត្តា យំ តុវំ វទេសិ នេសោ ឯតិស្សា វិជាមិ
នោ ច ខោ កោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិ-
ន្នោ ហោតិ អត្ថិ ខោ កោ អញ្ញោ អត្តា សព្ពសោ អា-
កិញ្ចញ្ញាយតនំ សមតិក្កម្ម សន្តមេតំ បណីតមេតន្តិ
នេវសញ្ញានាសញ្ញាយតនូបគោ យំ តុវំ ន ជានាសិ ន
បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ កោ
អយំ[1] អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិន-
ស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ កោ អយំ
អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ ស-
តោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។

---

๑ ឧ. អយន្តិ បាឋោ ន ទិស្សតិ ។

ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតឡើយ នែអ្នកដ៏ចំរើន ខ្លួននេះ ឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ឯង។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមានន្ទុះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួនន្ទុះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែន ជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ ម្នាលអ្នកដ៏ចំរើន មានខ្លួនដទៃ ដែលកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនកត មានអារម្មណ៍ថា នេះជាធម្មជាត សូប់ នេះជាធម្មជាត ឧត្តម អ្នកមិនដឹង មិនឃើញនូវខ្លួនណា ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននេះឯង លុះតាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ មិនកើតទៀតឡើយ នែអ្នកដ៏ចំរើន ខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឯង ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។

ឥមេហិ ខោ តេ កស្សប សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សន្តមេវ អត្តានំ ។ យេ ហិ កេចិ កស្សប សមណា វា ព្រាហ្មណា វា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សព្ពេ តេ ឥមេហេវ សន្តមេវ អត្តានំ ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(๕๐) សន្តិ កស្សប ឯកេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្ពានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្ពានំ បញ្ញបេន្តិ បញ្ចហិ អង្គេហិ ។ តេ ច ភោន្តោ សមណ-ព្រាហ្មណា កាមានញ្ច អត្ថា កាមានញ្ច ព្យាបាទា ទិដ្ឋធម្មនិព្ពានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្ពានំ បញ្ញបេន្តិ បញ្ចហិ អង្គេហិ ។ ឥធ កស្សប ឯកច្ចោ សមណោ វា ព្រាហ្ម-ណោ វា ឥរិយតិ ហោតិ ឥរិយិត្វា យេនេ ខោ

ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះ ជាទុច្ចេតវាទ រមែងបញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយហេតុ ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ ជាទុច្ចេតវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៧ យ៉ាងនេះឯង ។ បេ ។ ពួកជន កាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។

(៥០) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាទិដ្ឋធម្មនិព្វានវាទ (អ្នកពោលនូវនិព្វានគឺសេចក្តីរលត់ទុក្ខក្នុងបច្ចុប្បន្ន) បញ្ញត្តព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែងរបស់សត្វ ដែលមាននៅដោយហេតុ ៥ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណ យ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍មានពាក្យយ៉ាងនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា

កោ អយំ អត្តា បញ្ចហិ កាមគុណេហិ សមប្បិតោ
សមង្គីភូតោ បរិចារេតិ ឯត្តាវតា ខោ កោ អយំ អត្តា
បរមទិដ្ឋធម្មនិព្ពានប្បត្តោ(๑) ហោតីតិ ។ ឯត្តកេ សតោ
សត្តស្ស បរមទិដ្ឋធម្មនិព្ពានំ បញ្ញាបេន្តិ ។ តមញ្ញោ
ឯវមាហ អត្តំ ខោ កោ ឯសោ អត្តា យំ ភុំ
វិនេសិ នេសោ ឧត្តិតិ វាទាមិ ខោ ឧ ខោ កោ
អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្ពានប្បត្តោ
ហោតិ តំ កិស្ស ហេតុ កាមា ហិ កោ អនិច្ចា
ទុក្ខា វិបរិណាមធម្មា តេសំ វិបរិណាមញ្ញថាភាវ
ឧប្បជ្ជតិ សោកបរិទេវទុក្ខទោមនស្សុបាយាសា យតោ
ខោ កោ អយំ អត្តា ឥមេហេវ កាមេហិ វិវិច្ច អកុស-
លេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ
បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ កោ

---

๑ បរមទិដ្ឋធម្មនិព្ពានំ បត្តោតិបិ បាឋោ ។

ព្រហ្មជាលសូត្រ ទិដ្ឋធម្មនិព្វានវាទ

នៃអ្នកដ៏ចំរើន កាលណាបើខ្ញុំនេះឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាម-គុណ ៥ ម្ចាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះឯង ទើបខ្ញុំនេះឈ្មោះថាជាអត្តភាពដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្ញុំមានន្ទុះ ក៏មានមែន ឯខ្ញុំមិននិយាយថាខ្ញុំកន្ទុះមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្ញុំនេះមិនមែនដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណេះទេ ពាក្យដែលខ្ញុំថាដូចោះតើព្រោះហេតុអ្វី ម្ចាលអ្នកដ៏ចំរើន ព្រោះហេតុថាកាមទាំងឡាយមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បានសេចក្តីស្គាយស្រណោះសោកក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើង ព្រោះតាមទាំងនោះ ប្រែប្រួលទៅប្រព្រឹត្តទៅដោយប្រការដទៃ នែអ្នកដ៏ចំរើន ខ្ញុំនេះឯង កាលណាបានសូម្បីស្វាត់ចាកកាមទាំងឡាយហើយ បានសូម្បីស្វាត់ចាកអកុសលធម៌ទាំងឡាយហើយ បានដល់បឋមជ្ឈានប្រកបដោយវិតក្កៈវិចារៈមានបីតិនិងសុខៈកើតអំពីសេចក្តីស្ងាត់ ម្ចាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ

อยํ อตฺตา ปรมทิฏฐธมฺมนิพฺพานปฺปตฺตา โหตีติ ฯ
เอกจฺเจ สเต สตฺตสฺส ปรมทิฏฐธมฺมนิพฺพานํ ปญ-
ญเปนฺติ ฯ ตมญฺเญ ฌายมาหา อตฺถิ โข เม สเห
อตฺตา ยถ ทิฏฐเธ สิ เนเสา ทตฺติ วาทมิ เห ต โข
เม อยํ อตฺตา ปิตฺตาวสา ปรมทิฏฐธมฺมนิพฺพานปฺปตฺตา
โหตีติ ตถ กิสฺส เหตุ ยเถว ตฺถ วิสกฺกิตฺถ วิจารีตฺถ
ปเถน ปถ ปฺปฺปาวิตฺถ อกฺขายติ ยเถ เห เม อยํ
อตฺตา วิสกฺกวิจารมตฺต ปฺปสมา อชฺฌตฺตฺ สมฺปสาทนฺ
เจตโส เอโกทิภาวฺ อวิตกฺกฺ อวิจารฺ สมาธิช
ปีติสุขฺ ทุติยฺ ฌาน อุปสมฺปชฺช วิหรติ ปิตฺตาวสา เห
เม อยํ อตฺตา ปรมทิฏฐธมฺมนิพฺพานปฺปตฺตา โหตีติ ฯ

ទើបខ្លួននេះឈ្មោះថា ជានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណ-
ជាតយ៉ាងក្រៃលែង ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន
ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយ
ប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាង
នេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមានន៎ះ ក៏មានមែន ឯខ្ញុំ
មិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិន
មែនដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ព្រោះ
ហេតុមានប្រមាណប៉ុណ្ណេះឡើយ ពាក្យដែលថាដូច្នោះ តើព្រោះហេតុអ្វី
ព្រោះហេតុថា ចិត្តដែលប្រកបដោយវិតក្កៈនឹងវិចារៈមាននៅក្នុងបឋមជ្ឈាន
នោះ បឋមជ្ឈាននុ៎ះនៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានវិតក្កៈនឹង
វិចារៈនុ៎ះនៅឡើយ ម្នាលអ្នកដ៏ចំរើន កាលណាបើខ្លួននេះបានរម្ងាប់វិតក្កៈ
នឹងវិចារៈអស់ហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតប្រាស់ប្រាកដ
ក្នុងខ្លួន មានសេចក្តីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក មិនមាន
វិតក្កៈ មិនមានវិចារៈ មានតែបីតិនឹងសុខៈកើតអំពីសមាធិ គឺបឋមជ្ឈាន
ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឈ្មោះ
ថាបានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ។

តត្ថេកេ សមេា សត្តសុ បរមធិដ្ឋធម្មនិព្ពានំ បញ្ញ-
បេន្តិ ។ តមញ្ញេ ឯវមាហ អត្ថិ ខោ កោ ចិសោ
អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ ខោ ច
ខោ កោ អយំ អត្តា ឯត្តាវតា បរមធិដ្ឋធម្មនិព្ពានប្បត្តោ
ហោតិ តំ កិសុ ហេតុ យនេវ តត្ថ បរិកប្បំ
ឧបេសោ ទុព្ពិលាវិតត្តំ(១) ឯតេនេតំ ទិដ្ឋិវិកប្បំ អត្តាយតំ
យតោ ខោ កោ អយំ អត្តា បរិយោ ច វិភាគា
ទុបេក្ខោតោ ច វិមោតិ សមេា ច សម្បជាតោ សុខញ្ច
តោយេន បរិស្សវេតិ យន្នំ អរិយោ អាចិក្ខតិ ទុ-
បេក្ខោតោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧប-
សម្បជ្ជ វិហរតិ ឯត្តាវតា ខោ កោ អយំ អត្តា
បរមទិដ្ឋធម្មនិព្ពានប្បត្តោ ហោតីតិ ។ តត្ថេកេ សមេា
សត្តសុ បរមេទិដ្ឋធម្មនិព្ពានំ បញ្ញបេន្តិ ។ តមញ្ញេ

---

១ ម. ឥច្ចេវមាទិកំ ។ ម. ឥច្ចាទិវមាទិកំ ។

សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណ.
ជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។
មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏
ចំរើន អ្នកនិយាយថា ខ្លួនមានន៎ុះ ក៏មានមែន ខ្ញុំមិននិយាយថា ខ្លួនន៎ុះមិន
មានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែន បានដល់នូវព្រះនិព្វាន
ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណ
ប៉ុណ្ណោះទេ្លយ ពាក្យដែលពោលថាយ៉ាងនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា
បីតិជាទីកើតឡើងនៃចិត្តមានក្នុងទុតិយជ្ឈានន៎ុះ នៅប្រាកដជាឈានគ្រោត
គ្រោត ព្រោះមានបីតិន៎ុះនៅទេ្លយ ម្នាលអ្នកដ៏ចំរើន កាលណាបើ
ខ្លួននេះប្រកបដោយទុបេក្ខាផង មានស្មារតីដឹងខ្លួនផង រមែងបានទទួល
សុខដោយនាមកាយផង ព្រោះអស់ទៅនៃបីតិ ក៏បានដល់នូវតតិយជ្ឈាន
ដែលព្រះអរិយៈតំាងឡាយប្រាប់ថា លោកអ្នកបានតតិយជ្ឈាននោះប្រកប
ដោយទុបេក្ខា មានស្មារតីនៅជាសុខដូច្នេះ ម្នាលអ្នកដ៏ចំរើន ព្រោះ
ហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វាន
ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ។ សមណព្រាហ្មណ៍
ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង
របស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃ

ฬามหา อหนฺ เอว เอกา ฬเสา อตฺตา ยโต ทิฏฺ ปาเณสิ
เนเสา ธมฺโมติ เอว จ เอว เอกา อยเมว อตฺตา
ฬตฺถาวา ปรมทิฏฺธมฺมนิพฺพานปฺปตฺโต เหาติ ตเมว กิสฺส
เหตุ ยเนว ตตฺถ สุขมิติ เวทยเสา อาเกาเกา
ฬเตเนตเมว ทิฏฺปาเทกเมว อกฺกายติ ยโต เอว เอกา
อยเมว อตฺตา สุขสฺส จ ปหานา ทุกฺขสฺส จ ปหานา
ปุพฺเพว เสามนสฺสโทมนสฺสานเมว อตฺถงฺคมา อทุกฺขมสุขเมว
อุเปกฺขาสติปาริสุทฺธึ จตุตฺถนฺ ฌานเมว อุปสมฺปชฺช วิหรติ
ฬตฺถาวา เอว เอกา อยเมว อตฺตา ปรมทิฏฺธมฺมนิพฺพา-
นปฺปตฺโต เหาติ ติ ฯ สนฺเตเกว สเต สตฺตสฺส ปรมทิฏฺ-
ธมฺมนิพฺพานเมว ปญฺญเปนฺติ ฯ สเมวเมว เอว เต ภิกฺขเว
สมณพฺราหฺมณา ทิฏฺธมฺมนิพฺพานเมว สเต สตฺตสฺส
ปรมทิฏฺธมฺมนิพฺพานเมว ปญฺญเปนฺติ ปญฺญเปนฺติ เหว ฯ

ក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយ
ថា ខ្លួនមាន+នុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួន+នុ៎ះមិនមានទេ ម្នាលអ្នក
ដ៏ចំរើន តែថា ខ្លួននេះមិនមែនបានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជា
គុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ ពាក្យ
ដែលខ្ញុំថា យ៉ាងនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា សេចក្តីអើពើ
ប្លែកសេចក្តីក្តួចកាន់នៃចិត្តថាសុខដូច្នេះ រមែងមានក្នុងតតិយជ្ឈាននោះ តតិ-
យជ្ឈាន+នុ៎ះនៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានសុខនៅឡើយ
ម្នាលអ្នកដ៏ចំរើន កាលណាបើខ្លួននេះបានលះបង់សុខផង លះបង់ទុក្ខផង
មានសោមនស្សទឹងតោមនស្សអស់ហើយក្នុងកាលមុន ហើយបានដល់នូវ
ចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មាន
សតិដ៏បរិសុទ្ធកើតអំពីឧបេក្ខាវេទនា ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រ-
មាណប៉ុណ្ណេះឯង ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្ន
ថាជាគុណជាតយ៉ាងក្រៃលែង ។ សមណព្រាហ្មណ៍ពួកមួយបញ្ញត្តនូវ
ព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែងរបស់សត្វដែលមាន
នៅ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍
នោះ ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណ-
ជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាងនេះឯង ។

យេ ហិ កេចិ កិត្តវេ សមណា ច ព្រាហ្មណា
ច ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្ម-
និព្វានំ បញ្ញបេន្តិ សព្វេ តេ ឥមេហេវ បញ្ចហិ
វត្ថូហិ ។បេ។ យេបិ តថាគតស្ស យថាភុច្ចំ វណ្ណំ
សម្មា វទមានា វទេយ្យុំ ។ ឥមេហិ ខោ តេ កិត្តវេ
សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋោ
អបរន្តំ អារព្ភ អនេកវិហិតាធិ អធិមុត្តិបទានិ អភិ-
វទន្តិ ចតុដ្ឋានីយស្មាយ វត្ថូហិ ។ យេ ហិ កេចិ
កិត្តវេ សមណា ច ព្រាហ្មណា ច អបរន្តកប្បិកា
អបរន្តានុទិដ្ឋោ អបរន្តំ អារព្ភ អនេកវិហិតាធិ
អធិមុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមេហេវ ចតុ-
ដ្ឋានីយស្មាយ វត្ថូហិ ។បេ។ យេបិ តថាគតស្ស
យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។ ឥមេហិ
ខោ តេ កិត្តវេ សមណព្រាហ្មណា បុព្វន្តកប្បិកា
ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច

ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ ជាទិដ្ឋធម្ម-
និញ្ញានវាទ បញ្ញត្តនូវព្រះនិញ្ញាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង
របស់សត្វដែលមាននៅ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្ត
ដោយហេតុ ៥យ៉ាងនេះឯង ។ បេ ។ ពួកជនគាលនិយាយសរសើរគុណ
របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។ ម្នាល
ភិក្ខុទាំងឡាយ ពួកសម្ព័ណព្រាហ្មណ៍នោះ ជាអ្នកប្រកបដោយអបរន្ត-
កប្បវិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ។ នូវខន្ធជាចំណែកខាងមុខ
ប្រាថ្នាខន្ធជាចំណែកខាងមុខ តែងសំដែងនូវចំណែកនៃទិដ្ឋិ ច្រើនប្រការ
ដោយហេតុទាំង៤៤នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្ម-
ណ៍ឯណាមួយ ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តី
យល់ឃើញនូវខន្ធជាចំណែកខាងមុខ ប្រាថ្នាខន្ធជាចំណែកខាងមុខ សំ-
ដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ សមណព្រាហ្មណ៍ទាំងអស់នោះ រមែង
បញ្ញត្តដោយហេតុទាំង ៤៤ នេះឯង ។ បេ ។ ពួកជនគាលនិយាយសរសើរ
គុណរបស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។ ម្នាល
ភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍នោះ ជាអ្នកប្រកបដោយបុព្វន្តកប្ប-
ទិដ្ឋិ ប្រកបដោយអបរន្តកប្បទិដ្ឋិ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ

ปุพฺพนฺตปรนฺตานุทิฏฺโน ปุพฺพนฺตปรนฺตํ อารพฺภ อเนกวิหิตานิ
อธิมุตฺตปทานิ อกาเรหิ ทสฺสนฺติ ฯ เยหิ เกจิ กิฺจาปิ สมณา วา ព្រាហ្មณา วา
បុพฺพนฺตกปฺปิกา วา អបรนฺตกปฺปิกา วา បุพฺพนฺตปรนฺต-
กปฺปิกา วา បុพฺพนฺตปรนฺตานุทิฏฺโน បុพฺพนฺตปรนฺตំ អារพฺភ
អเนกวิหิตานิ អธิมุตฺตปทานิ អกาเรหิ สพฺเพ តេ
ឥមេហេវ ทสฺสนฺติ វត្ថូหิ ฝតេสំ วา អញฺญตเรน ឧត្តុ
ឥតោ ពហิទฺธา ฯ តយิทំ កิฺจาปิ តថาคតោ បជานาติ
ឥเม ទิฏฺฐิคตา ฝវំกหิตา ฝវំបกมฺปา ฝវំกតิกา ភវนฺติ
ฝวំ អกิสมฺปกยาติ ฯ តញฺจ តថาคតោ បជานาติ
តតោ ច ឧត្តរិตรំ បជานาติ តញฺจ បជานนំ ឧបกมฺมสติ

ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធ
ជាចំណែកខាងមុខ ច្រើនប្រការដោយហេតុ ៦២ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ
ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិក្តី ប្រកប
ដោយអបរន្តកប្បទិដ្ឋិក្តី ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិក្តី ជាអ្នកមាន
សេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែក
ខាងមុខ ច្រើនប្រការ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងសំដែង
ដោយហេតុទាំង ៦២ នេះឯង ឬក៏បណ្តាហេតុទាំង ៦២ នុ៎ះ ដោយ
ហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ
ព្រះតថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះដូចេ្នះថា ហេតុនៃទិដ្ឋិទាំងឡាយ
នេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ មានគតិយ៉ាង
នេះ មានការប្រព្រឹត្តិទៅក្នុងខាងមុខ យ៉ាងនេះ ។ ព្រះតថាគតដឹងច្បាស់
នូវហេតុនៃទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីល សមាធិ និងសព្វញ្ញុតញ្ញាណ)
ដែលជាគុណជាតលើសលុបក្រៃលែង ជាងនោះទៅទៀតផង កាលបើ
ដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ មួយ

អបរាមសតោ ជស្ស បច្ចត្តញ្ញេវ[๑] ឩត្តរិំ វិនិតា វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ តិក្ខវេ តថាគតោ ។ ឥមេ ខោ តេ តិក្ខវេ ធម្មា គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(๙๑) តត្រ តិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតិកា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ

---

๑ ម. បច្ចត្តំយេវ ។

ទៀត កាលបើព្រះតថាគតមិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វាន ជាគ្រឿងរលត់ទៅ ( នៃបពមាសក្តិលេស ) ដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវសេចក្តីឆ្ងាញ់ពីសារបស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ផុតស្រឡះហើយ ( ចាកកិលេស ) ព្រោះមិនបានប្រកាន់ ( នូវធម៌ណាមួយមានខន្ធជាដើម ) ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយអាចសំដែងនូវធម៌ទាំងឡាយបាន ពួកជន កាលពោលសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ដែលបុគ្គលកម្រឃើញបាន ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីស្ងប់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញ ទើបអាចដឹងបាន ។

(៥១) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទ បញ្ញត្តខន្ធទាំងឡោក

ចតូហិ វត្ថូហិ តថេវ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ(១) ។

(៥២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តថេវ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ ។

(៥៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ តថេវ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ ។

---

១ ម. បរិត្តសិតវិប្ផន្ទិតមេវ ។

ថា ទៀងដោយវត្ត ៤ យ៉ាង ឯអារម្មណ៍ (កុងទិដ្ឋិ) នោះ ដែលពួកសមណៈ ព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយឯកច្ចសស្សតឯកច្ចអស-ស្សតទិដ្ឋិ បញ្ញត្តខ្លួនទ្រឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយវត្ត ៤ យ៉ាង ឯអារម្មណ៍ (កុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៩៧) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកថា មានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយវត្ត ៤ យ៉ាង ឯអារម្មណ៍ (កុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៥៦) តត្រ កតមេ យេ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ត តត្ត បញ្ហំ បុដ្ឋា សមានា ឯកច្ចំ វិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ តទេវ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេធយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ ។

(៥៧) តត្រ កតមេ យេ តេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ឯតូហិ វត្ថូហិ តទេវ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេធយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ ។

(៥៤) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកផង សាកសួរប្រស្នា ក្នុងកុសលទំាងអកុសលនោះៗហើយ ក៏ដល់នូវការរេចារេចាំ ចោះសំដី មិនឲ្យស្ទាប់ពាក្យ ដោយវត្ថុ ៤ យ៉ាង ឯអាម្នាំ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្តុតអន្ទះអន្ទែងវិញ ។

(៥៥) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តខន្ធទំាងឡាយថា កើតឡើងដោយឥតហេតុ ដោយវត្ថុ ៤ យ៉ាង ឯអាម្នាំ (ក្នុងទិដ្ឋិ) នោះដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្តុតអន្ទះអន្ទែងវិញ ។

(๕๖) តត្រ កតមេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋោ បុព្វន្តំ អារព្ភ អនេកា. វិហិតានំ អធិមុត្តិបធានំ(๑) អភិវទន្តំ អជ្ឈាសយា វត្ថុមិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ ។

(๕๗) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីភទា ឧទ្ធមាឃតនា សញ្ញីមត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថុហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តសិតំ វិប្ផន្ទិតមេវ ។

---

๑ ឧ. អធិមុត្តិបធានំ ។

(៥៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញវៀរ ។ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធជាចំណែកខាងដើម សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ១៧ យ៉ាង ឯអារម្មណ៍ (កុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ខ្ពួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្តុត អន្ទះអន្ទែងវិញ ។

(៥៧) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយខន្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តខ្លះថា មានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ១៦ យ៉ាង ឯអារម្មណ៍ (កុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ខ្ពួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្តុត អន្ទះអន្ទែងវិញ ។

(๕๘) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា អសញ្ញីវាទា ឧទ្ធមាឃតា អសញ្ញិ. មត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តស្សិតំ វិប្ផន្ទិតមេវ ។

(๕๙) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតា នេវសញ្ញីនាសញ្ញិ មត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តស្សិតំ វិប្ផន្ទិតមេវ ។

(๖๐) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ

(៥៨) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយទុទ្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តខ្លួនថា មិនមានសញ្ញា ទាំងមុខអំពីសេចក្តីស្លាប់ ដោយវត្ត ៨ យ៉ាង ឯអាត្មាណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៥៩) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយទុទ្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តខ្លួនថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងមុខអំពីសេចក្តីស្លាប់ ដោយវត្ត ៨ យ៉ាង ឯអាត្មាណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៦០) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ

បញ្ញាបេន្តំ សន្តមេវ វត្ថុមេវ តថតំ តេសំ ភវតំ សមណ-
ព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហា-
គតានំ បរិត្តស្សិតំ វិប្ផន្ទិតមេវ ។

(៦១) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
ឯដ្ឋគមនិញ្ញាគារិកា សតោ សត្តស្ស បរមឯដ្ឋគមនិញ្ញំ
បញ្ញាបេន្តំ បញ្ញមេវ វត្ថុមេវ តថតំ តេសំ ភវតំ សមណ-
ព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ
បរិត្តស្សិតំ វិប្ផន្ទិតមេវ ។

(៦២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេ-
កវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុក្ខន្ធាទ្យីសា-
យ វត្ថុមេវ តថតំ តេសំ ភវតំ សមណព្រាហ្មណានំ

ដោយវត្ថុ ៧ យ៉ាង ឯអារម្មណ៍(ក្នុងទិដ្ឋិ)នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ ( តាមសភាវធម៌ដែលពិត ) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្ទុត អន្ទះអន្ទែងវិញ ។

(៦១) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយវត្ថុ ៥ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ)នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្ទុត អន្ទះអន្ទែងវិញ ។

(៦២) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយអបរន្តកប្បទិដ្ឋិ មានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ៤៤ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ )នោះដែលពួកសមណព្រាហ្មណ៍

អជានតំ អបស្សតំ វេនយិកំ តណ្ហាភតានំ បរិត្តសទ្ទំ វិប្ផន្ទិតមេវ ។

(៦៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋោ បុព្វន្តាបរំ អារព្ភ អនេកវិហិតានិ អធិមុត្តិបថានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ តត្ថបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេនយិកំ តណ្ហាភតានំ បរិត្តសទ្ទំ វិប្ផន្ទិតមេវ ។

(៦៤) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តត្ថបិ ឧស្សុប្បន្នយា ។

ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្ទុត អន្ទះអន្ទែងវិញ ។

(៦៣) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយបុព្វន្តកប្បទិដ្ឋិ ផង ប្រកបដោយអបរន្តកប្បទិដ្ឋិផង ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិផង មានសេចក្តីយល់ឃើញរឿយ ។ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញច្រើនប្រការ ដោយវត្ថុ ៦២ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ)នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្ទុត អន្ទះអន្ទែងវិញ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ដែលជាសស្សតវាទ បញ្ញត្តខន្ធនឹងលោកថា ទៀង ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៥) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្চអសស្សតិកា ឯកច្চំ សស្សតំ ឯកច្চំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តទបិ ជស្សប្បដិយា ។

(៦៦) តត្រ កតមេ យេ តេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ តទបិ ជស្សប្បដិយា ។

(៦៧) តត្រ កតមេ យេ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ត តត្ត បញ្ហំ បុដ្ឋា សមានា ឯជា-រាវិក្ខេបំ អាបជ្জន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ តទបិ ជស្សប្បដិយា ។

(៦៨) តត្រ កតមេ យេ តេ សមណព្រាហ្មណា អធិច្চសមុប្បន្និកា អធិច្চសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ តទបិ ជស្សប្បដិយា ។

(៦៥) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកប ដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តខ្ទនទំនឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកថា មានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៧) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកផង សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ។ ហើយ ក៏ដល់នូវការរោចរាយ បោះសំដីមិនឲ្យស្ទាប់ពាក្យ ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៨) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តខ្ទនទំនឹងលោកថា កើតឡើងដោយឥតហេតុ ដោយវត្ថុ ២ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(๖๙) តត្រ កតមេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ អជ្ឈារសហិ វត្ថូហិ តទេបិ ឧស្សជ្ជន្តិ ។

(๗๐) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីវាទា ឧទ្ធមាឃតនា សញ្ញីមត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថូហិ តទេបិ ឧស្សជ្ជន្តិ ។

(๗๑) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា អសញ្ញីវាទា ឧទ្ធមាឃតនា អសញ្ញីមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទេបិ ឧស្សជ្ជន្តិ ។

(๗๒) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនា

(៦៩) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ មានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ច្រើនជាងនូវខន្ធ ជាចំណែកខាងដើម ហើយសំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ជាច្រើនប្រការដោយវត្ថុ ១៨ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧០) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តខ្លះថា មានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ១៦ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧១) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តខ្លះថា មិនមានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៨ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧២) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តខ្លះថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា

ឧទាសញ្ញីនាសញ្ញាមត្តានំ បញ្ញបេន្តំ អដ្ឋហិ វត្ថូហិ តទបិ ឧសញ្ញប្បដិយា ។

(៧៣) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តំ សត្តហិ វត្ថូហិ តទបិ ឧសញ្ញប្បដិយា ។

(៧៤) តត្រ កតមេ យេ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្ពានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្ពានំ បញ្ញបេន្តំ បញ្ចហិ វត្ថូហិ តទបិ ឧសញ្ញប្បដិយា ។

(៧៥) តត្រ កតមេ យេ តេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុក្ខត្តុំសាយ វត្ថូហិ តទបិ ឧសញ្ញប្បដិយា ។

សញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៨ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៣) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាខ្ចេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយវត្ថុ ៧ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៤) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយវត្ថុ ៥ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៥) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ មានសេចក្តីយល់ឃើញរឿយ ។ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ជាច្រើនប្រការ ដោយវត្ថុ ៤៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៣៦) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ ឥធបិ ឧស្សុទ្ធច្ចយា ។

(៣៧) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តេ វត អញ្ញត្រ ឧស្សា បដិសំវេទិសន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៣៨) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្চំ សស្សតំ ឯកច្চំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តេ វត អញ្ញត្រ ឧស្សា បដិសំវេទិសន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(๗๖) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិផង ប្រកបដោយអបរន្តកប្បទិដ្ឋិផង ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិផង មានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ក្រោវឮនូវខន្ធ ជាចំណែកខាងដើម ទំនឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញច្រើនប្រការ ដោយវត្ថុ ๑๒ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(๗๗) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទ បញ្ញត្តខន្ធទំនឹងលោកថា ទៀងដោយវត្ថុ ๔ យ៉ាង ឯពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ ទំនងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ គឺថាបើរៀរចាកផស្សៈ មិនអាចទទួលអារម្មណ៍បានឡើយ ។

(๗๘) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឯកច្ចសស្សតៈ-ឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តខន្ធទំនឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយវត្ថុ ๔ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ ទំនងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៧៩) តត្រ កតមេ យេ តេ សមណព្រាហ្មណា អត្តានន្តិកា អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចត្តារោ វត្ថុវាទា តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨០) តត្រ កតមេ យេ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ត តត្ត បញ្ហំ បុដ្ឋា សមានា ឯកាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចត្តារោ វត្ថុវាទា តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨១) តត្រ កតមេ យេ តេ សមណព្រាហ្មណា អធិច្চសមុប្បន្និកា អធិច្চសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វេបិ វត្ថុវាទា តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៧៩) ម្នាលគហបតិទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ដែលជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកថា មានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយវត្ថុ ៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរគចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨០) ម្នាលគហបតិទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកផង សាកសួរប្រស្នាកុសលនឹងអកុសលនោះៗហើយ ក៏ដល់នូវការរេចរាចរៈសំដីមិនឲ្យស្ងាប់ពាក្យ ដោយវត្ថុ ៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨១) ម្នាលគហបតិទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអធិច្চសមុប្បន្នទិដ្ឋិ បញ្ញត្តខ្លួននឹងលោកថា កើតឡើងដោយឥតហេតុ ដោយវត្ថុ ២ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨២) តត្រ កតមេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេកវិហិតាឝំ អធិមុត្តិបទានំ អភិវទន្តិ អជ្ឈាសយហិ វត្ថូហិ តេ វត អញ្ញត្រ ជស្សា បដិសំវេទិសន្តីតំ នេតំ ឋានំ វិជ្ជតិ ។

(៨៣) តត្រ កតមេ យេ តេ សមណព្រាហ្មណា ខុទ្ទមាឝនិកា សញ្ញីវាទា ខុទ្ទមាឝនា សញ្ញីមត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថូហិ តេ វត អញ្ញត្រ ជស្សា បដិសំវេទិសន្តីតំ នេតំ ឋានំ វិជ្ជតិ ។

(៨៤) តត្រ កតមេ យេ តេ សមណព្រាហ្មណា ខុទ្ទមាឝនិកា អសញ្ញីវាទា ខុទ្ទមាឝនា អសញ្ញីមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តេ វត អញ្ញត្រ ជស្សា បដិសំវេទិសន្តីតំ នេតំ ឋានំ វិជ្ជតិ ។

(៨២) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ មានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធ ជាចំណែកខាងដើម សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ១៨ យ៉ាង ពួកសមណព្រាហ្មណ៍នោះ រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តខ្លួនថា មានសញ្ញាខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៦ យ៉ាងពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៤) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយទុទ្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តខ្លួនថាមិនមានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៨ យ៉ាង ពួកសមណព្រាហ្មណ៍នោះ រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៥) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនា នេវសញ្ញីនាសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តេ វត អញ្ញត្រ ឥមស្មា បដិសំវេទនស្សន្តិតិ នេតំ ឋានំ វិជ្ជតិ ។

(៨៦) តត្រ កតមេ យេ តេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សត្តហិ វត្ថូហិ តេ វត អញ្ញត្រ ឥមស្មា បដិសំវេទនស្សន្តិតិ នេតំ ឋានំ វិជ្ជតិ ។

(៨៧) តត្រ កតមេ យេ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្ពានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្ពានំ បញ្ញបេន្តិ បញ្ចហិ វត្ថូហិ តេ វត អញ្ញត្រ ឥមស្មា បដិសំវេទនស្សន្តិតិ នេតំ ឋានំ វិជ្ជតិ ។

(៨៥) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយទិដ្ឋមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តខន្ធថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៩ យ៉ាង ពួកសមណព្រាហ្មណ៍នោះ រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយវត្ថុ ៧ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង នៃសត្វដែលមាននៅ ដោយវត្ថុ ៥ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៨) តត្រ កតមេ យេ តេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបថានិ អភិវទន្តិ ឯត្តកម្បិ សាយ វត្តុំ តេ វត អញ្ញត្រ ឧសញ្ញា បដិសំវេទិសញ្ញីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៩) តត្រ កតមេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបថានិ អភិវទន្តិ ន្វាសង្ខយា វត្តុំ តេ វត អញ្ញត្រ ឧសញ្ញា បដិសំវេទិសញ្ញីតិ នេតំ ឋានំ វិជ្ជតិ ។

ព្រហ្មជាលសូត្រ ប្រកបដោយអបរន្តកប្បទិដ្ឋិជាដើម

(៨៨) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងមុខ សំដែងនូវចំណែក នៃសេចក្តីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ៤៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដំណឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ប្រកបដោយអបរន្តកប្បទិដ្ឋិ ទាំងប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ៦២ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង រៀរចាកផស្សៈចេញហើយ នឹងទទួលដំណឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៤០) តត្រ កតមេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ យេបិ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា យេបិ តេ សមណព្រាហ្មណា អន្តានន្តិកា យេបិ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា យេបិ តេ សមណព្រាហ្មណា អធិច្চសមុប្បន្និកា យេបិ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា យេបិ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីវាទា យេបិ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា អសញ្ញីវាទា យេបិ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា យេបិ តេ សមណព្រាហ្មណា ឧច្ឆេទវាទា យេបិ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្ពានវាទា យេបិ តេ សមណព្រាហ្មណា អបរន្តកប្បិកា[1] យេបិ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា

---

១ ឧ. យេបិ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា យេបិ តេ សមណព្រាហ្មណា អបរន្តកប្បិកាវ ទិស្សន្តិ ។

(៩០) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទ បញ្ញត្តខ្លួនទំាងសោកថា ទៀងដោយវត្ថុ ៤ យ៉ាងក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអធិច្চសមុប្បន្នទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយទ្ធមាយតនទិដ្ឋិ ជាសញ្ញីវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយទ្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយទ្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាឧច្ឆេទវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាទិដ្ឋធម្មនិព្វានវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ប្រកប

ច បុព្វន្តាបរន្តកប្បិកា ច[1] បុព្វន្តាបរន្តានុទិដ្ឋោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបធានានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ សព្វេ តេ ឥមេ ឥស្សរ. យតនេហិ ឯុស្សរ ឯុស្សរ[2] បដិសំវេទន្តិ ។ តេសំ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបា. ទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ច. យា ឥមេសំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ ឆន្នំ ឥស្សាយ. តនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីន. វញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ វុច្ចតេ. ហិ សព្វេហេវ ឧត្តរិតរំ បជានាតិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា បុព្វន្តកប្បិកា វា

---

១ ម. ជាតិ ន ទិស្សតិ ។ ២ ម. ឯុស្សរ ឯុស្សរ ។ កត្ថចិ អម្ហាកំ ឱតត្តវកេសុបិ ឆឡិទំសោយេវ ។

ព្រហ្មជាលសូត្រ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិជាដើម

ដោយអបរន្តកប្បទិដ្ឋិ តាំងប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញវៀរ ។ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែក នៃសេចក្តីយល់ឃើញច្រើនប្រការ ដោយវត្ថុ ៦២ ក្តី ពួកសមណព្រាហ្មណ៍តាំងអស់នោះ ទទួលដឹង ( នូវអារម្មណ៍ ) ព្រោះប៉ះពាល់ត្រូវដោយអាយតនៈ ជាទីកើតនៃផស្សៈ ៦ យ៉ាង ។ តណ្ហារបស់សមណព្រាហ្មណ៍តាំងនោះ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោកស្រណោះ សេចក្តីខ្សឹកខ្សួល សេចក្តីមិនស្រួលកាយ សេចក្តីតូចចិត្ត សេចក្តីចង្អៀតចិត្ត ក៏កើតមាន ព្រោះជាតិជាបច្ច័យដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើង នឹងសេចក្តីវិនាស នឹងសេចក្តីត្រេកអរ នឹងទោសនឹងឧបាយជាគ្រឿងរលាស់ចេញនូវអាយតនៈ ជាទីកើតនៃផស្សៈទាំង ៦ តាមសេចក្តីពិតប្រាកដ ក្នុងកាលណា ។ ភិក្ខុនេះរមែងដឹងច្បាស់នូវធម៌ដ៏លើសលុបជាងទិដ្ឋិទាំងឡាយទាំងពួងនេះ ( ក្នុងកាលនោះឯង ) ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ជាអ្នកប្រកបដោយបុព្វន្តកប្ប-

អបរន្តកប្បិកា វ បុព្វន្តាបរន្តកប្បិកា វ បុព្វន្តាប-
រន្តានុទិដ្ឋោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានំ អធិ-
ម្មុត្តិបដានំ អភិវន្ទនំ សព្ពេ តេ ឥមេហេវ ទ្វាសដ្ឋិយា
វត្ថូហិ អន្តោជាលិកតា ឯត្ថ សិតា វ ផុដ្ឋមានា
ផុដ្ឋន្តិ ឯត្ថ បរិយាបន្នា អន្តោជាលិកតា វ ផុដ្ឋមានា
ផុដ្ឋន្តិ សេយ្យថាបិ កុក្កុដេនក្កោ កោដ្ឋោ វ កោដ្ឋន្តរេ-
វ សិ វ សុខុមច្ឆិន្នកេន ជាលេន បរិក្ខិត្តំ ឧទកមហន្តំ(1)
ឯវមេវ្យ តស្ស ឯវមស្ស យេ ខោ កេចិ ឥមស្មិំ ផុដ-
កាយមានេ ឯឆ្ឆាវិតា ចាណា សព្ពេបេតេ(2) អន្តោជាលិ-
កតា ឯត្ថ សិតា វ ផុដ្ឋមានា ផុដ្ឋន្តិ ឯត្ថ បរិយាបន្នា
អន្តោជាលិកតា វ ផុដ្ឋមានា ផុដ្ឋន្តិ ឯវមេវ ខោ
កុក្កុដេ យេ ហិ កេចិ សមណា វ ព្រាហ្មណា វ

---

1 ឧ ម. ឧទកមហំ ។ 2 ឧ. ម. សព្ពេ តេ ។

ទិដ្ឋិ៨ ប្រកបដោយអបរន្តកប្បទិដ្ឋិ៨ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ៨ ជាអ្នកមានសេចក្តីយល់ឃើញវៀរ ។ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើមនឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញប្រែនប្រការ ពួកសមណ-ព្រាហ្មណ៍ទាំងអស់នោះ ដែលវាត ៦២ នេះឯង (គ្របសង្កត់) ធ្វើឲ្យដូចជានៅខាងក្នុងសំណាញ់ គឺធម្មទេសនារបស់ព្រះតថាគត អាស្រ័យនៅក្នុងសំណាញ់នេះ កាលរើបឡើង ក៏រើបឡើង (ក្នុងសំណាញ់នេះ) ជាប់នៅក្នុងសំណាញ់នេះ ធ្វើឲ្យដូចជានៅខាងក្នុងសំណាញ់ គឺធម្មទេសនារបស់ព្រះតថាគត កាលរើបឡើង ក៏រើបឡើង (ក្នុងសំណាញ់នេះ) ម្នាលភិក្ខុទាំងឡាយ នាយនេសាទមច្ឆជាតិក្តី កម្មការរបស់នាយនេសាទមច្ឆជាតិក្តី ដែលបុំនប្រសប់បង់សំណាញ់ មានក្រឡាដ៏ញឹកនៅក្នុងអន្ទង់ទឹកតូចនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសត្វធំតូចណាមួយ នៅក្នុងអង្គុដ់ទឹកនេះ ពួកសត្វធំតូចទាំងនោះ អញធ្វើឲ្យនៅខាងក្នុងសំណាញ់ អាស្រ័យនៅក្នុងសំណាញ់នេះ កាលបើរើបឡើង ក៏រើបឡើង (ក្នុងសំណាញ់នេះ) ជាប់ចំពាក់នៅក្នុងសំណាញ់នេះ អញធ្វើឲ្យនៅខាងក្នុងសំណាញ់ កាលបើរើបឡើង ក៏រើបឡើង (ក្នុងសំណាញ់) សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ

បុព្វន្តកប្បិកា ឯ អបរន្តកប្បិកា ឯ បុព្វន្តាប-
រន្តកប្បិកា ឯ បុព្វន្តាបរន្តាទិដ្ឋិនោ បុព្វន្តាបរន្តំ
អារព្ភ អនេកវិហិតានិ អធិមុត្តិបធានានិ អភិវទន្តិ សព្ពេ
តេ ឥមេហេវ ទ្វាសដ្ឋិយា វត្ថូហិ អន្តោជាលិកតា
ឯត្ថ សិតា វុម្មុជ្ជមានា ឧម្មុជ្ជន្តិ ឯត្ថបរិយាបន្នា អន្តោ-
ជាលិកតា វុម្មុជ្ជមានា ឧម្មុជ្ជន្តិ ។ ឧច្ឆិន្នភវនេត្តិកោ
តិក្ខវេ តថាគតស្ស កាយោ តិដ្ឋតិ យាវស្ស កាយោ
ឋស្សតិ តាវ នំ ទក្ខន្តិ[1] ទេវមនុស្សា កាយស្ស
ភេទា ឧទ្ធំ ជីវិតបរិយាទានា ន នំ[2] ទក្ខន្តិ ទេវម-
នុស្សា សេយ្យថាបិ តិក្ខវេ អម្ពបិណ្ឌិយា វណ្ដូបនិពន្ធនា[3] សញ្ញិ តានិ

---

๑ ម. ទក្ខិន្តិ ។ ๒ ម. នត្ថិ ន ទិស្សតិ ។ ๓ ម. វណ្ដូបនិពន្ធនានិ ។

ព្រហ្មជាលសូត្រ ប្រែកបដោយបុព្វន្តកប្បទិដ្ឋិជាដើម

ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ប្រកបដោយអបរន្តកប្បទិដ្ឋិ ប្រកប
ដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកឃើញរឿយ ។ ទ្វាទ្វន្ទជាចំណែកខាង
ដើមនិងទ្វន្ទជាចំណែកខាងមុខ ទ្រាវញ្ចទ្វាទ្វន្ទជាចំណែកខាងដើម និងទ្វន្ទ
ជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ
ពួកសមណព្រាហ្មណ៍ទាំងអស់នោះ ដែលតែ ៦២ នេះឯង (គ្រប់សង្កត់)
ធ្វើឲ្យដូចជានៅខាងក្នុងនៃសំណាញ់ គឺធម្មទេសនារបស់តថាគត អាស្រ័យ
នៅក្នុងសំណាញ់នេះ កាលដើរឡើងក៏ដើរឡើង (ក្នុងសំណាញ់នេះ)
ជាប់នៅក្នុងសំណាញ់នេះ ធ្វើឲ្យដូចជានៅក្នុងសំណាញ់ គឺធម្មទេសនា
របស់ព្រះតថាគត កាលបើដើរឡើងក៏ដើរឡើង (ក្នុងសំណាញ់នេះ) មាន
ឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាយរបស់ព្រះតថាគតមាន
តណ្ហានាំទៅកាន់កំពង់ទៀត ដាច់អស់ហើយ តែកាយបិតនៅ (កាយ
របស់ព្រះតថាគតនេះ) បិតនៅ ត្រឹមណា នៅតាន់ទឹមនុស្សទាំងឡាយ
ក៏នឹងឃើញកាយនោះត្រឹមណោះ លុះអស់ទ្វន្ទខាងមុខអំពីកំរិយាអស់
ទៅនៃជីវិត ទើបពួកទេវតានឹងមនុស្ស លែងឃើញកាយនោះ ម្នាល
ភិក្ខុទាំងឡាយ កាលបើបង្គោមផ្ទះស្វាយ ដែលមានទងដាច់ហើយ ផ្ទះ
ស្វាយណាមួយដែលជាប់នៅក្នុងទង (ជាមួយគ្នា) ផ្ទះស្វាយទាំងអស់នោះ

តនន្ទយាដំ ភវន្តំ ឯវមេវ ខោ តំ តុម្ហេ ឧច្ចិន្តភវនេត្តិកោ
តថាភតស្ស តាយោ តំជនំ យាវស្ស តាយោ ឋស្សតំ
តាវ ដំ ឧក្កន្តំ ទេវមនុស្សា តាយស្ស តេតា ឧច្ចំ
ជីវិតបរិយោធាតា ឧ ដំ ឧក្កន្តំ ទេវមនុស្សាតំ ។ ឯវំ
វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ចយំ
ភន្តេ អច្ចគំ ភន្តេ តោនាមោ អយំ ភន្តេ ឆម្មបរំ-
យាយោតំ ។ តស្មាតំហា តុំ អានន្ទ ឥមំ ឆម្មបរិយាយំ
អត្តជាលន្តិមំ ដំ ជាវេហិ ឆម្មជាលន្តិ ដំ ជាវេហិ
ព្រហ្មជាលន្តិមំ ដំ ជាវេហិ ទិដ្ឋិជាលន្តិមំ ដំ ជាវេហិ

រមែង(ដាច់ជ្រុះ)ទៅតាមគ្នាដែរ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាយរបស់ព្រះតថាគត មានតណ្ហាដែលនាំទៅកាន់ភពថ្មីទៀតដាច់អស់ហើយ (តែកាយនេះ) បិតនៅ កាយរបស់ព្រះតថាគតនេះបិតនៅ ត្រឹមណា ទេវតានឹងមនុស្សទាំងឡាយ នឹងឃើញកាយនោះ ត្រឹមណោះ លុះកាយបែកធ្លាយទៅ ខាងមុខអំពីតិរិយាអស់ទៅនៃជីវិត ទើបពួកទេវតានឹងមនុស្សលែងបាននឃើញកាយ របស់ព្រះតថាគតនោះ ក៏មានឧបមេយ្យដូច្នោះឯង ។ កាលដែលព្រះមានព្រះភាគ ត្រាស់សំដែងយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីនេះជាអស្ចារ្យ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីនេះមិនធ្លាប់មានមកទេ បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះឈ្មោះដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុនោះ អ្នកចូរចាំទុកនូវធម្មបរិយាយនេះ ក្នុងសាសនានេះថា អត្ថជាលៈ (មានអត្ថដូចជាបណ្តាញ) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះថា ធម្មជាលៈ (មានធម៌ដូចជាបណ្តាញ) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះថា ព្រហ្មជាលៈ (មានធម៌ដ៏ប្រសើរដូចជាបណ្តាញ) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះថា ទិដ្ឋិជាលៈ (មានទិដ្ឋិ ៦២ ដូចជាបណ្តាញ) ដូច្នេះក៏បាន

ព្រហ្មជាលសុត្តេ ភគវតោ ភាសិតំ អភិនន្ទនំ

អនុត្តរោ សង្គាមវិជយោតិបិ ឥំ ជាតវេហីតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។ ឥមស្មឹ ច បន វេយ្យាករណស្មឹ ភញ្ញមានេ ទសសហស្សី លោកធាតុ អកម្បិត្ថាតិ ។

ព្រហ្មជាលសុត្តំ បឋមំ និដ្ឋិតំ ។

ចូរចាំទុកនូវធម្មបរិយាយនោះថា សង្គ្រាមវិជយៈ(មានជ័យជំនះក្នុងសង្គ្រាម) ដ៏ប្រសើរដូច្នេះក៏ថាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងព្រះសូត្រនេះហើយ ។ ភិក្ខុទាំងនោះ មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ ថាន ត្រាស់សំដែងព្រះសូត្រនេះ ជាគាថ្យវេយ្យាករណ៍(ចប់)ហើយ លោក-ជាតុទាំងមួយហ្មឺន ក៏កម្រើកញាប់ញ័រ ។

ចប់ ព្រហ្មជាលសូត្រ ទី ១ ។

# សាមញ្ញផលសុត្តំ ទុតិយំ

(៩១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ភគ-
គហេ វិហរតិ ជីវកម្ពវនេ មហតា
ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។
តេន ខោ បន សមយេន ភគវា អាគតោ អជាតសត្តុ
វេទេហីបុត្តោ តទហុបោសថេ បណ្ណរសេ កោមុទិយា
ចាតុម្មាសិនិយា បុណ្ណាយ បុណ្ណមាយ រត្តិយា ភគវ-
មេវុបរិវុតោ ឧបរិបាសាទវរគតោ និសិន្នោ ហោតិ ។
អថខោ ភគវា អាគតោ អជាតសត្តុ វេទេហីបុត្តោ
ឧដ្ឋាយំ ឧដ្ឋាយេវំ រមណីយា វត ភោ ទោសិនា រត្តិ
អភិរូបា វត ភោ ទោសិនា រត្តិ ទស្សនីយោ វត ភោ
ទោសិនា រត្តិ ចាសាទិកា វត ភោ ទោសិនា រត្តិ
លក្ខញ្ញា វត ភោ ទោសិនា រត្តិ កំ នុ ខ្វជ្ជ សម-
ណំ វា ព្រាហ្មណំ វា បយិរុបាសេយ្យាម យន្នោ

# សាមញ្ញផលសូត្រ ទី ២

(៩១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តអម្ពវ័ន (ព្រៃស្វាយ) ជារបស់ជីវកកោមារភព្យ ទៀប ក្រុងរាជគ្រឹះ មួយអន្លើនឹងភិក្ខុសង្ឃច្រើន ចំនួនមួយពាន់ពីររយហាសិប រូប ។ សម័យនោះឯង ព្រះបាទអជាតសត្តុវេទេហីបុត្ត (ជាព្រះរាជបុត្រ របស់ព្រះរាជទេវី ទ្រង់ព្រះនាមវេទេហី) ជាធំក្នុងជែនមគធៈ មានពជ-អាមាត្យចោមរោម ទ្រង់គង់ប្រថាប់លើប្រាសាទដ៏ប្រសើរ ក្នុងពត្រីមាន ព្រះចន្ទពេញវង់ ជាពត្រីមានរដូវក្តៅ គ្រប់គ្រាន់ហើយ ជាទីបំផុត នៃខែ ៤ ជាកាលមានផ្កាកុមុទរីក ជាថ្ងៃឧបោសថទី ១៥ គឺពេញបូណ៌មី ខែកត្តិក ។ គ្រានោះឯង ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងជែន មគធៈ ទ្រង់បន្ទឺឧទានវាចាថា ពត្រីប្រាសចាកទោស (ស្អាតរុងរឿង) គួរជាទីត្រេកអរ អ្ហីម្ល៉ះហ្ន៎ ពត្រីប្រាសចាកទោស មានភាពល្អ អ្ហីម្ល៉ះហ្ន៎ ពត្រីប្រាសចាកទោស គួរជាទីរមិលមើល អ្ហីម្ល៉ះហ្ន៎ ពត្រីប្រាសចាកទោស ជាទីនាំមកនូវសេចក្តីជ្រះថ្លា អ្ហីម្ល៉ះហ្ន៎ ពត្រីប្រាសចាកទោស គួរជាទីកំណត់ដឹង អ្ហីម្ល៉ះហ្ន៎ ក្នុងថ្ងៃនេះ តើ យើងគប្បីចូលទៅរកសមណៈឬព្រាហ្មណ៍ ណាហ្ន៎ យើងចូលទៅ

បយិរុថាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ អាមន្តេសិ ភគវាតិ អជាតសត្តុ វេទេហិបុត្តោ ភគវន្តំ ឯតទវោច អយំ ទេវ បូរណោ កស្សបោ សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរប្បព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ តំ ទេវោ បូរណំ កស្សបំ បយិរុថាសតុ អប្បេវនាម ទេវស្ស បូរណំ កស្សបំ បយិរុថាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ ភគវា មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហី អហោសិ ។ អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ អាមន្តេសិ ភគវាតិ អជាតសត្តុ វេទេហិបុត្តោ ភគវន្តំ ឯតទវោច អយំ ទេវ មក្ខលិ គោសាលោ សង្ឃីចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរប្បព្វជិតោ អទ្ធគតោ

អង្គុយដិតបុគ្គលណា ទើបនឹងមានចិត្តជ្រះថ្លាបាន ។ កាលបើព្រះពជាមានព្រះបន្ទូលយ៉ាងនេះហើយ មានពជអាមាត្យម្នាក់ ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះបូរណកស្សបនេះជាអ្នកមានពួកមានគណៈ(ច្រើន)ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិមហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងក្រឡុយ បួសយូរជាងជនច្រើនតាំងនៅជាយូរអង្វែង (អស់ពីរបីកប្បមកហើយ) ដល់ហើយនូវបច្ចូមវ័យ សូមព្រះសម្មតិទេពស្តេចចូលទៅរកគ្រូឈ្មោះបូរណកស្សបនោះចុះ កាលបើព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះបូរណកស្សបហើយ មុខជានឹងមានព្រះពជហឫទ័យជ្រះថ្លាមិនខាន ។ កាលបើពជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈទ្រង់ព្រះតុណ្ហីភាព ។ មានពជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះមក្ខលិគោសាលនេះ ជាអ្នកមានពួកមានគណៈ(ច្រើន)ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិមហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងក្រឡុយ បួសយូរជាងជនច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីកប្បមកហើយ) ដល់ហើយ

វាយោអនុបវ្ឋន្តោ តំ ឋានំ មក្ខលិ គោសាលំ បយិរុទា-
សតុ អប្បវាទាម ឋានស្ស មក្ខលិ គោសាលំ បយិរុទា-
សតោ ចិត្តំ បសីទេយ្យាតំ ។ ឃំ វុត្តេ ភជា មាកណ
អជាតសត្តុ វេទេហីបុត្តោ តុណ្ហី អហោសិ ។ អញតរេបិ
ខោ ភជាមហ្ឋោ ភជានំ មាកណំ អជាតសត្តុំ វេទេហីបុត្តំ
ឯតទវោច អយំ ឋានំ អជិតោ កេសកម្ពលោ សង្ឃិ ច
គណិ ច គណាចរិយោ ច ញាតោ យសស្សិ តិត្ថករោ
សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរប្បព្វជិតោ អទ្ធ-
គតោ វាយោអនុបវ្ឋន្តោ តំ ឋានំ អជិតំ កេសកម្ពលំ
បយិរុទាសតុ អប្បវាទាម ឋានស្ស អជិតំ កេសកម្ពលំ
បយិរុទាសតោ ចិត្តំ បសីទេយ្យាតំ ។ ឃំ វុត្តេ ភជា
មាកណោ អជាតសត្តុ វេទេហីបុត្តោ តុណ្ហី អហោសិ ។
អញតរេបិ ខោ ភជាមហ្ឋោ ភជានំ មាកណំ អជាត-
សត្តុំ វេទេហីបុត្តំ ឯតទវោច អយំ ឋានំ បកុធោ

ន្ទរៀបច្ចូមវ័យ សូមព្រះសម្មតិទេព ស្តេចចូលទៅគង់ជិតគ្រូឈ្មោះមក្ខលិ-
គោសាលនោះចុះ កាលបើ ព្រះសម្មតិទេព ស្តេចចូលទៅកគ្រូឈ្មោះ
មក្ខលិគោសាលហើយ មុខដាន់ឆ៍មានព្រះពជហប្ចុទ័យជ្រះថ្លាមិនខាន ។
កាលបើពជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុ
វៃទេហីបុត្ត ជាធំកង់ដែនមគធៈ ក៏ទ្រង់ព្រះតុណ្ហីភាព ។ មានពជអាមាត្យ
ម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវៃទេហីបុត្ត ជាធំកង់ដែនមគធៈ
ដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះអជិតកេសកម្ពលនេះ ជាអ្នក
មានពួកមានគណៈ(ច្រើន)ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកិត្តិ
ឈ្មោះ ជាអ្នកមានយស ជាអ្នកឆ្លៀនូវលទ្ធិ មហាជនសន្មតថាជាសប្បុរស
ជាអ្នកដឹងពត្រើយរួ ប្ចូសយូរជាង់ជនដាច្រើន តាំង់នៅជាយូរអង្វែង (អស់
ពីរើពជ្យមកហើយ) ដល់ហើយន្ទរៀបច្ចូមវ័យ សូមព្រះសម្មតិទេព ស្តេច
ចូលទៅកគ្រូឈ្មោះអជិតកេសកម្ពលនោះចុះ កាលបើ ព្រះសម្មតិទេព
ស្តេចចូលទៅកគ្រូឈ្មោះអជិតកេសកម្ពលហើយ មុខដាន់ឆ៍មានព្រះពជ-
ហប្ចុទ័យជ្រះថ្លាមិនខាន។ កាលបើពជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះ
ហើយ ព្រះបាទអជាតសត្តុវៃទេហីបុត្ត ជាធំកង់ដែនមគធៈ ទ្រង់ព្រះតុណ្ហី-
ភាព ។ មានពជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវៃទេ-
ហីបុត្ត ជាធំកង់ដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះបកុធ

กจฺฉายเนา สงฺฆี เจว คณี จ คณาจริโย จ ญาตา ยสสฺสี ติตฺถกเร สาธุสมฺมตา พหุชฺ-
ชนสฺส รตฺตญฺญู จิรปพฺพชิตา อทฺธคตา วยาอนุปฺปตฺตา
ตีหิ เอเกน ปกฺขุ กจฺฉายนิ ปยิรุปาสิตพฺพา อเยฺยหิ ตาม
เนวสฺส ปกฺขุ กจฺฉายนิ ปยิรุปาสิตา จิตฺตี ปสี-
เทยฺยาติ ฯ ฆโร วุตฺเตภชา มาคเนา อชาตสตฺตุ เวเท-
หีปุตฺตา ตุณฺหี อโหสิ ฯ อถ ตเกปิ เนา ภชา-
ยเนา ภชานิ มาคนิ อชาตสตฺตุ เวเทหีปุตฺตี ปจฺจเกเน
อยิ เนว สญฺญเนา เวลฏฺฐปุตฺตา สงฺฆี เจว คณี จ
คณาจริโย จ ญาตา ยสสฺสี ติตฺถกเร สาธุสมฺม-
ตา พหุชนสฺส รตฺตญฺญู จิรปพฺพชิตา อทฺธคตา วยา-
อนุปฺปตฺตา ตีหิ เอเกน สญฺญยิ เวลฏฺฐปุตฺตี ปยิรุปาสิตพฺพา
อเยฺยหิ เนวสฺส สญฺญยิ เวลฏฺฐปุตฺตี ปยิรุปาสิตา

កថ្ថាយនៈនេះ ជាអ្នកមានពួកមានគណៈ (ច្រើន) ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវិលទ្ធិមហាជនសន្ធត ថាជាសប្បុរស ជាអ្នកដឹងពត្រីយ្យរ បួសយូរជាងជនជាច្រើន តាំងនៅជាយូរអង្វែង (អស់ពីរថើពជ្រមកហើយ) ដល់ហើយ នូវបច្ឆិមវ័យ សូមព្រះសម្មតិទេព ស្តេចចូលទៅកគ្រូឈ្មោះបកុធកច្ចាយនៈនោះចុះ កាលបើ ព្រះសម្មតិទេព ស្តេចចូលទៅកគ្រូឈ្មោះបកុធកច្ចាយនៈហើយ មុខជានឹងមានព្រះពជហប្ញទ័យជ្រះថ្លាមិនខាន ។ កាលបើពជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែងដែនមគធៈទ្រង់ព្រះតុណ្ហីភាព ។ មានពជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តនេះ ជាអ្នកមានពួកមានគណៈ (ច្រើន) ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវិលទ្ធិ មហាជនសន្ធតថាជាសប្បុរស ជាអ្នកដឹងពត្រីយ្យរ បួសយូរជាងជនជាច្រើន តាំងនៅ ជាយូរអង្វែង (អស់ពីរបើពជ្រមកហើយ) ដល់ហើយនូវបច្ឆិមវ័យ ព្រះសម្មតិទេព ស្តេចចូលទៅកគ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តនោះចុះ កាលបើព្រះសម្មតិទេព ស្តេចចូលទៅកគ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តហើយ មុខជានឹងមាន

ចំតំ បសីទេយ្យាតំ ។ ឃំ វុត្តេ ភជា មាកណ្ឌោ អជាតសត្តុ វេទេហីបុត្តោ តុណ្ហី អហោសិ ។ អញ្ញតរោបិ ខោ ភជាមច្ចោ ភជាតំ មាកណ្ឌំ អជាតសត្តុំ វេទេហីបុត្តំ ឯតទវោច អយំ ទេវ ឯកណ្ឌោ ជាជបុត្តោ(๑) សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរបព្ពជិតោ អទ្ធគតោ វយោអនុប្បត្តោ តំ ទេវោ ឯកឡ្ឍំ ជាជបុត្តំ បយិរុបាសតុ អប្បេវនាម ទេវស្ស ឯកឡ្ឍំ ជាជបុត្តំ បយិរុបាសតោ ចិត្តំ បសីទេយ្យាតំ ។ ឃំ វុត្តេ ភជា មាកណ្ឌោ អជាតសត្តុ វេទេហីបុត្តោ តុណ្ហី អហោសិ ។

[๔๒] តេន ខោ បន សមយេន ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហីបុត្តស្ស អវិទូរេ តុណ្ហីភូតោ និសិន្នោ ហោតិ ។ អថ ខោ ភជា មាកណ្ឌោ អជាតសត្តុ វេទេហីបុត្តោ ជីវកំ កោមារភច្ចំ ឯតទវោច តុំ បន សម្ម ជីវក កឹ តុណ្ហីតិ ។

---

๑ ម. នាគពុទ្ធោ ។

ព្រះពាជហឬទ័យជ្រះថ្លាមិនខាន ។ កាលបើពាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែនមគធៈ ទ្រង់ព្រះតុណ្ហីភាព ។ មានពាជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះនិគណ្ឋនាដបុត្តនេះ ជាអ្នកមានពួកមានគណៈ(ច្រើន)ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិមហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងពត្រីយូរ បួសយូរជាង៨ជនជាច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីពាជវង្សមកហើយ) ដល់ហើយ នូវបច្ចុមវ័យ សូមព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះនិគណ្ឋនាដបុត្តនោះចុះ កាលបើព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះនិគណ្ឋនាដបុត្តហើយ មុខជានឹងមានព្រះពាជហឬទ័យជ្រះថ្លាមិនខាន ។ កាលៈ បើពាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែនមគធៈ ទ្រង់ព្រះតុណ្ហីភាព ។

(៤២) សម័យនោះឯង ដីវកកោមារកតវ្តអង្គុយស្ងៀម ជិតព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែនមគធៈ ។ គ្រានោះ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំកង្វែនមគធៈ ទ្រង់មានព្រះពាជឧទ្ធារនឹងដីវកកោមារកតវ្តដូច្នេះថា នែដីវកៈជាសំឡាញ់ ចុះហេតុអ្វីបានជាអ្នកស្ងៀម ។

อยญฺหิ เถโร ภควติ อาทรชาตตาย อตฺตโน ปฏิลาภสฺส อจฺฉริยตาย ตสฺมิญฺจ ปฏิลาภสฺส อนุรูปาย ปฏิปตฺติยา

ទ្រង់មានព្រះកត្តុរតាកាយ ទ្រង់មានព្រះឧស្សុរសកាយ ទ្រង់មានព្រះវាចាមុនគេ (តែកន្លងកាលខ្លះ) បានត្មៃថា ព្រះសមណគោតមដ៏ចំរើន មានបរិសទ្យចាំង ៤ ពួក ធ្លើសក្ការៈ គោរព កប់អាន បូជា កោតក្រែង បានត្មៃថា ពួកទេវតា នឹងមនុស្សជាច្រើន ដ្រះថ្លានឹងព្រះសមណគោតម បានត្មៃថា (បើ) ព្រះសមណគោតមដ៏ចំរើន នៅអាស្រ័យក្នុងស្រុកណា ឫនិគមណា ពួកអមនុស្សមិនហ៊ានបៀតបៀន ដល់មនុស្សចាំងច្បាយក្នុងស្រុក ឫនិគមនោះឡើយ បានត្មៃថា ព្រះសមណគោតម មានពួកមានក្រុម នឹងអាចារ្យនៃពួកក្រុម (ជាច្រើន) ប្រដុំដនតែងពោលថា ព្រះអង្គប្រសើរជាងពួកតិរ្ថិយដ៏ច្រើន នៃអ្នកចាំងច្បាយដ៏ចំរើន ក៏យសរបស់សមណព្រាហ្មណ៍ចាំងនេះ តែងចំរើនរុងរឿងឡើង ដោយហេតុតាមតែបាន យ៉ាងណាមិញ ឯយសរបស់ព្រះសមណគោតម មិនមែនចំរើនរុងរឿងឡើងយ៉ាងនោះទេ តាមដែលពិតនោះ យសរបស់ព្រះសមណ-គោតម ចំរើនរុងរឿងឡើង ព្រោះការបរិបូណ៌ ដោយវិជ្ជានឹងចរណៈដ៏ប្រសើរ បានត្មៃថា ព្រះបាទមាគធសេនិយពិម្ពិសារ ព្រមចាំងព្រះរាជបុត្រ ព្រះអគ្គមហេសី រាជបរិសទ្យនឹងរាជអាមាត្យ បានដល់នូវព្រះសមណ-គោតមជាសរណៈ ស្មើដោយជីវិត បានត្មៃថា ព្រះបាទបសេនទិកោសល

ភជា បសេនទិកោសលោ សបុត្តោ សភរិយោ សប-
រិសោ សាមច្ចោ ចាណោហំ សរណគ្គតោ សមណំ
ខលុ ភោ គោតមំ ព្រាហ្មណោ ចោក្ខរសាតំ សបុត្តោ
សភរិយោ សបរិសោ សាមច្ចោ ចាណោហំ សរណគ្គតោ
សមណោ ខលុ ភោ គោតមោ រញ្ញោ មាគធស្ស
សេនិយស្ស ពិម្ពិសារស្ស សក្ខាតោ ភវតោ មានិតោ
បូជិតោ អបចិតោ សមណោ ខលុ ភោ គោតមោ
រញ្ញោ បសេនទិកោសលស្ស សក្ខាតោ ភវតោ
មានិតោ បូជិតោ អបចិតោ សមណោ ខលុ ភោ
គោតមោ ព្រាហ្មណស្ស ចោក្ខរសាតិស្ស សក្ខាតោ
ភវតោ មានិតោ បូជិតោ អបចិតោ សមណោ
ខលុ ភោ គោតមោ ចម្បំ អនុប្បត្តោ ចម្បាយំ
វិហរតិ កណ្ណកេយ្យ ចោក្ខរណិយា តីរេ យេ ខោ បន
ភោ(๑) កេចិ សមណា វា ព្រាហ្មណា វា អម្ហាកំ
តាមក្ខេត្តំ អាគច្ឆន្តិ អតិថិនោ តេ មោឡ្ហំ អតិថី
ខោ(๒) បនម្ហិ សក្ខាតព្ពា ភវតោ មានេតព្ពា

---

๑ ឧ. ភោសព្ពេ ន ទិស្សតិ ។ ๒ ឧ អតិថីបិ ភោ ។

ព្រមទាំងព្រះរាជបុត្រ ព្រះអគ្គមហេសី រាជបរិស័ទ្យទទឹងអាមាត្យ បានដល់នូវព្រះសមណគោតមដ៏ចំរើនជាសរណៈស្មើដោយជីវិត បានឮថា ចោក្ខវសាតិព្រាហ្មណ៍ព្រមទាំងបុត្រភរិយា បរិស័ទ្យទទឹងអាមាត្យ បានដល់នូវព្រះសមណគោតមជាសរណៈស្មើដោយជីវិត បានឮថា ព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណគោតម បានឮថា ព្រះបាទបសេនទិកោសល ទ្រង់បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណគោតម បានឮថា ចោក្ខវសាតិព្រាហ្មណ៍បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណគោតម បានឮថា ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរមកដល់ក្រុងចម្បា ហើយ ឥឡូវទ្រង់គង់ទៀបឆ្នេរស្រះចោក្ខវណីឈ្មោះគគ្គរា ជិតក្រុងចម្បានៃគ្នាយើងដ៏ចំរើន ពួកសមណៈឬព្រាហ្មណ៍ឯណាមួយ ដែលមកដល់តាមក្តេរ្តរបស់យើងហើយ ពួកសមណព្រាហ្មណ៍អម្បាលនោះ សុទ្ធតែជាភ្ញៀវរបស់យើង ធម្មតាភ្ញៀវ គួរតែយើងធ្វើសក្ការៈ គោរព រាប់អាន

ឃ្លាតេតព្ពា អបនេតព្ពា យម្បិ តោ សមណោ គោតមោ ធម្មំ អនុប្បត្តោ ធម្មាយំ វិហារតិ តក្កាយ តោក្ករ-ណាយ តីរេ អតិដ្ឋស្មាកំ សមណោ គោតមោ អតិដ្ឋិ ខោ បនម្ហេហិ សក្កាតព្ពោ ភរុកាតព្ពោ មានេតព្ពោ ឃ្លាតេតព្ពោ អបចិតព្ពោ ឥមិនា ចង្កមេន ន អរហតិ សោ ភវំ តោគមោ អម្ហាកំ ឧស្សាយ ឧបសង្កមិតុំ អដ្ឋខោ មយមេវ អរហាម តំ ភវន្តំ តោគមំ ឧស្សាយ ឧបសង្កមិតុំ ឯត្តកេ ខោ អហំ តោតោ តោគមស្ស វណ្ណោ បរិយាបុណាមិ នោ ច ខោ សោ ភវំ តោគមោ ឯត្តកវណ្ណោ អបរិមាណវណ្ណោ ហិ សោ ភវំ តោគមោតិ ។

(១៨៣) ឯវំ វុត្តេ តេ ព្រាហ្មណា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោចុំ យថា ខោ ភវំ សោណ-ទណ្ឌោ សមណស្ស តោគមស្ស វណ្ណោ ភាសតិ ឥតោ ឆេបិ សោ ភវំ តោគមោ យោជនសតេ វិហរតិ

បូជា គោតក្រែង នែគ្នាយើងដ៏ចំរើន ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរ
មកដល់ក្រុងចម្បាហើយ ឥឡូវទ្រង់គង់ទៀបឆ្នេរស្រះបោក្ខរណីឈ្មោះគគ្គរា
ដ៏តក្រុងចម្បា ព្រះសមណគោតមឈ្មោះថា ជាក្មៀវរបស់យើងហើយ
ធម្មតាក្មៀវ គួរតែយើងធ្វើសក្ការៈ គោរព រាប់អាន បូជា គោតក្រែង
ព្រោះហេតុនេះ ព្រះសមណគោតមដ៏ចំរើននោះ មិនគួរបូលមកជួប
នឹងយើងទេ តាមដែលពិតនោះ យើងទេតើ ទើបគួរបូលទៅគាល់ព្រះ
សមណគោតមដ៏ចំរើននោះវិញ ខ្ញុំរៀបរាប់គុណរបស់ព្រះគោតមដ៏ចំរើន
បានតែប៉ុណ្ណេះ ឯព្រះគោតមដ៏ចំរើននោះ មិនមែនមានគុណត្រឹមប៉ុណ្ណេះ
ទេ ព្រោះថា ព្រះគោតមដ៏ចំរើននោះ មានគុណនឹងប្រមាណពុំបាន ។

(๑๘๓) កាលដែលសោណទណ្ឌព្រាហ្មណ៍ និយាយយ៉ាងនេះហើយ
ពួកព្រាហ្មណ៍ទាំងនោះ បាននិយាយទៅ នឹងសោណទណ្ឌព្រាហ្មណ៍
ដូច្នេះថា អម្ប្រាលយ៉ាងសោណទណ្ឌដ៏ចំរើន ម្តេចគង់ពោលសរសើរ
គុណព្រះសមណគោតមទៅហើយ ព្រោះហេតុនោះ បើទុកជាព្រះសមណ-
គោតមដ៏ចំរើននោះ គង់នៅកងទ័ព្វាយមួយរយយោជន៍ អំពីទីនេះក្តី

អលមេវ សង្ឃេន កុលបុត្តេន ឧស្សាយ ឧបសង្កមិតុំ អបិ បុជ្ជាសេនាតិ(๑) ។ តេនហិ តាសេ វ មយំ សមណំ គោតមំ ឧស្សាយ ឧបសង្កមិស្សាមាតិ ។ អថខោ សោណទណ្ឌោ ព្រាហ្មណោ មហតា ព្រាហ្មណគណេន សទ្ធិ យេន កក្ករា តោក្ករណី តេនុបសង្កមិ ។ អថខោ សោណទណ្ឌស្ស ព្រាហ្មណស្ស តំកោវនសណ្ឌតតស្ស ឯវំ ចេតសោ(๒) បរិវិតក្កោ ឧទបាទិ អហាញ្ហេវ ខោ បន សមណំ គោតមំ បញ្ហំ បុច្ឆេយ្យំ ឥត្រ ចេមំ សមណោ គោតមោ ឯវំ វាទេយ្យ ន ខោ ឯស(๓) ព្រាហ្មណោ បញ្ហោ ឯវំ បុច្ឆិតព្ពោ ឯវំ ជាមេស ព្រាហ្មណោ បញ្ហោ បុច្ឆិតព្ពោតិ តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ សោណទណ្ឌោ ព្រាហ្មណោ អត្យាគ្គោ ជាសក្ខំ សមណំ គោតមំ យោនិសោ បញ្ហំ បុច្ឆិតុន្តិ យំ ខោ បជាយំ បរិសា បរិភវេយ្យ យសោមិ តស្ស ហាយេថ យស្ស

---

๑ ម. បុជ្ជំសេនាតិ ។ ម. ឆុជ្ជោសេនាតិ ។ ๒ ម. ចេតសោ ។ ๓ ម. ន ចេស ។

កុលបុត្រដែលមានសទ្ធា គួរណាស់តែរកស្បៀងយកទៅ ដើម្បីនឹងចូលទៅគាល់ឲ្យបាន ។ សោណទណ្ឌព្រាហ្មណ៍និយាយថា នែអ្នកគាំងគ្បាយដ៏ចំរើន បើដូច្នោះយើងទាំងអស់គ្នា នឹងចូលទៅគាល់ព្រះសមណគោតម ។ លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ ព្រមទាំងពួកព្រាហ្មណ៍ជាច្រើន បានចូលសំដៅទៅត្រង់ស្រះបោក្ខរណីឈ្មោះគគ្គា ។ លុះសោណទណ្ឌព្រាហ្មណ៍ ចូលទៅដល់ខាងក្រៅជង្រៃ(១) ក៏កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា ប្រសិនជាអាត្មាអញ សួរប្រស្នាចំពោះព្រះសមណគោតម បើព្រះសមណគោតម ពោលយ៉ាងនេះ នឹងអាត្មាអញក្នុងប្រស្នានោះថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះ អ្នកមិនត្រូវសួរ យ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរសួរយ៉ាងនេះវិញ (បើដូច្នេះ) បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះ ថាសោណទណ្ឌព្រាហ្មណ៍ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាច ដើម្បីនឹងសួរប្រស្នាចំពោះព្រះសមណគោតម ដោយយោបល់បាន បរិសទ្យនេះបើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះ គប្បីសាបសូន្យ

---

១ បើតាមអដ្ឋកថាពន្យល់ថា ខាងក្នុង គឺជ្រៃដែលនៅត្រង់បន្ទោះមីដែលព្រះអង្គគង់ ។

ខោ បន យាសោ ហាយេថ តោតាបំ តស្ស ហាយេយ្យុំ យាសោលទ្ធា ខោ បនម្ហាកំ តោតា មញ្ញេ បន[1] សមណោ តោតមោ បញ្ចាំ បុច្ឆេយ្យ តស្ស ចាហំ បញ្ហស្ស វេយ្យាតរណេន ចិត្តំ ន អារាធេយ្យំ តត្រ ចេ មំ សមណោ តោតមោ ឃរំ វាទេយ្យ ន ខោ ឯស[2] ព្រាហ្មណ បញ្ហោ ឃរំ ឥតោ-តញ្ហោ ឃរំ ជាមេស ព្រាហ្មណ បញ្ហោ ឥតោតញ្ហោតំ តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ សោណ-ឌណ្ឌោ ព្រាហ្មណោ អឥរ្ជោ ជាសក្កិ សមណស្ស តោតមស្ស បញ្ហស្ស វេយ្យាតរណេន ចិត្តំ អារា-ធេតុន្តិ យំ ខោ បនាយំ បរិសា បរិភវេយ្យ យាសោ-បំ តស្ស ហាយេថ យស្ស ខោ បន ឃរំ យាសោ ហាយេថ តោតាបំ តស្ស ហាយេយ្យុំ យាសោលទ្ធា ខោ បនម្ហាកំ តោតា អហាញ្ញេ ខោ បន ឃរំ សម័បតតោ សមានោ អធិស្ស វ សមណំ តោតមំ ឯវាវត្តេយ្យុំ តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ

---

๑ ម. មំ ឯវំ ខោ បន ។ ម មម្ញេវ ខោ បន ។ ๒ ម. ន ឯវេស ។

យសរបស់បុគ្គលណា ដែលសាបសូន្យហើយ កោគៈទាំង៦ឱ្យរបស់បុគ្គលនោះគប្បីសាបសូន្យដែរ ដ្បិតកោគៈទាំង៦ឱ្យរបស់យើង សុទ្ធតែបានដោយយស មួយទៀត បើព្រះសមណគោតម សួរប្រស្នានឹងអាត្មាអញ ។ មុខជានឹងធ្វើព្រះទ័យរបស់ព្រះអង្គ ឱ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍នោះមិនបានទេ បើព្រះសមណគោតម ពោលនឹងអាត្មាអញក្នុងប្រស្នានោះ យ៉ាងនេះថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះ អ្នកមិនត្រូវធ្វើយ យ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរធ្វើយយ៉ាងនេះវិញទេតើ (បើដូច្នេះ) បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះ ថា សោណទណ្ឌព្រាហ្មណ៍ ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាចដើម្បីធ្វើព្រះទ័យ របស់ព្រះសមណគោតម ឱ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍ទេ បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ កោគៈទាំង៦ឱ្យរបស់បុគ្គលនោះ ក៏គប្បីសាបសូន្យដែរ ដ្បិតកោគៈទាំង៦ឱ្យរបស់យើង សុទ្ធតែបានដោយយស មួយវិញទៀត បើអាត្មាអញបានទៅដល់ទីដ៏តយ៉ាងនេះហើយ តែមិនទាន់បានឃើញព្រះសមណគោតមនៅឡើយ ក៏ស្រាប់តែត្រឡប់មកវិញ បរិសទ្យនេះមុខជានឹងមើលងាយ

សោណទណ្ឌោ ព្រាហ្មណោ អញ្ញត្រោ មាទិសេន តេវិជ្ជេន តេ វិសមា សមណា គោតមំ ឧស្សាទាយ ឧបសង្កមិតុំ តាទិនា ញាយេន វា សមេន វា សមាទោ អនិស្សា សមណំ គោតមំ ឯវត្តិស្សតីតិ យំ ខោ បនាយំ បរិសា បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ តោតមិ តស្ស ហាយេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ តោតាតិ ។

(១៨៤) អថខោ សោណទណ្ឌោ ព្រាហ្មណោ យេន តកវា តេនុបសង្កមិ ឧបសង្កមិត្វា តកវតា សទ្ធឹ សម្មោទិ សម្មោទនីយំ តថំ សារណីយំ វីតិសារេត្វា ឯតមត្ថំ ឯរិ ។ តម្បេយ្យតាបិ ខោ ព្រាហ្មណ-តហាបតិតា អម្បតរេ តកវន្តំ អតិភវេត្វា ឯតមត្ថំ ឯរិ អម្បតរេ តកវតា សទ្ធឹ សម្មោទិ សម្មោទនីយំ តថំ សារណីយំ វីតិសារេត្វា ឯតមត្ថំ

អាត្មាអញ ដោយហេតុនោះ ថា សោណទណ្ឌព្រាហ្មណ៍ជាមនុស្សល្ងង់ ខ្លៅ មិនឈ្លាសវៃ មានមានះរឹងត្អឹង ខ្ជាប មិនហ៊ានចូលទៅគាល់ព្រះសមណគោតមទេ មិនសមបើសោណទណ្ឌព្រាហ្មណ៍ ចូលមកដល់ទីដែតយ៉ាងនេះហើយ មិនបានបានឃើញព្រះសមណគោតមទៅឡើយ ក៏ស្រាប់តែត្រឡប់មកវិញសោះ បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ កោគៈទាំងឡាយរបស់បុគ្គលនោះ ក៏គប្បីសាបសូន្យដែរ ដ្បិតកោគៈទាំងឡាយរបស់យើង សុទ្ធតែបានដោយយស ។

(១៨៤) លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ ដើរចូលសំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះណាល ទៅកាព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីសុខស្ងាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ចំណែកខាងព្រាហ្មណ៍គហបតីទាំងឡាយអ្នកក្រុងចម្បា ពួកខ្លះក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះពោលពាក្យរាក់ទាក់សំណេះសំណាលទៅកាព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកល្មមឲ្យកើតសេចក្តីសុខស្ងាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ

ฉสีสีสุ อเปฺรกฺขเตฺว เยน ภควา เตนญฺชลิมปฺปณาม.
เมตฺตา ผรมนฺโต ฉสีสีสุ อเปฺรกฺขเตฺว ตามเตฺต
สาเวตฺวา ผรมนฺโต ฉสีสีสุ อเปฺรกฺขเตฺว ตุณฺหีภูตา
ผรมนฺโต ฉสีสีสุ ฯ ตตฺร สุทํ สาณาคมฺหา
พฺราหฺมณา ผลเกฬิ(๑) ตหุลมนฺโตสกฺกาโต ฉสีเฏฺฐ
หาเต อหาเสฺว ขา ปน สมณา โคตมา ปญฺ
ปุเจฺจยฺยุ ตตฺร เต มา สมณา โคตมา ฬา
ฉ ขา ผล พฺราหฺมณา ปเญฺห ฬา ปุจฺฉิตเพฺพ ฬา
ตามเส พฺราหฺมณา ปเญฺห ปุจฺฉิตเพฺพ เตน มา อยา
ปริสา ปริกเยฺย ตาณา สาณาคมฺหา พฺราหฺมณา
อตฺถาโต ตาสกฺขุ สมณา โคตมา โยตาสา ปญฺ
ปุจฺฉนฺตุ ยา ขา ปตายา ปริสา ปริกเยฺย ยสาป
ตสฺส ภายา ยสฺส ขา ปน ยสา ภายา
โคตาป ตสฺส ภายายฺยุ ยสาลทฺธา ขา ปนมฺหาก
โคตา มเสฺว ขา ปน สมณา โคตมา

๑ ฉ. ผลเกฬิตา ฉ ทีฆนิ ฯ

ពួកខ្លះប្រណម្យរញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រកាសនាមនឹងគោត្រ (របស់ខ្លួន) ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយស្ងៀម ក្នុងទីដ៏សមគួរ ។ សោណទណ្ឌព្រាហ្មណ៍អង្គុយត្រិះរិះ នូវហេតុមានប្រមាណច្រើន ក្នុងទីនោះ ដូច្នេះថា ប្រសិនបើអាត្មាអញ សួរប្រស្នានឹងព្រះសមណគោតម បើព្រះសមណគោតមពោលយ៉ាងនេះនឹងអាត្មាអញ ក្នុងប្រស្នានោះ ថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះ អ្នកមិនត្រូវសួរយ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរសួរយ៉ាងនេះវិញទើតើ បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះ ថា សោណទណ្ឌព្រាហ្មណ៍ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាចនឹងសួរប្រស្នានឹងព្រះសមណគោតម ដោយយោបល់ចាន បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ កោគៈ: តំណក្បាយរបស់បុគ្គលនោះ ក៏គប្បីសាបសូន្យដែរ ដ្បិតកោគៈតំណក្បាយរបស់យើងសុទ្ធតែបានដោយយស មួយវិញទៀត បើព្រះសមណគោតម

បញ្ចាំ បុព្ពេយ្យ តស្ស ចាហំ បញ្ចស្ស វេយ្យាករណេន
ចំតំ ន អាភតេយ្យំ តត្រ ចេ មំ សមណោ គោតមោ
ឯវំ វទេយ្យ ន ខោ ឯស ព្រាហ្មណ បញ្ហោ ឯវំ ព្យា-
កាតព្ពោ ឯវំ ឯតមេស ព្រាហ្មណ បញ្ហោ ព្យាកា-
តព្ពោតិ តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ
សោណទណ្ឌោ ព្រាហ្មណោ អព្យត្តោ ឯាសង្កំ សម-
ណស្ស គោតមស្ស បញ្ចស្ស វេយ្យាករណេន ចំតំ
អាភតេតុន្តិ យំ ខោ បឯាយំ បរិសា បរិភវេយ្យ
យសោបំ តស្ស ហាយេថ យស្ស ខោ បន យសោ
ហាយេថ ភោគាបំ តស្ស ហាយេយ្យុំ យសោលទ្ធា
ខោ បនម្ហាតំ ភោគា អហោ វត តំ សមណោ
គោតមោ សតេ អាចរិយកេ តេវិជ្ជកេ មំ បញ្ចំ
បុព្ពេយ្យ អទ្ធា វ តស្សាហំ ចំតំ អាភតេយ្យំ បញ្ចស្ស
វេយ្យាករណោឯាតិ ។

ស្តីប្រស្នានឹងអាត្មាអញ ។ មុខជាធ្វើព្រះទ័យរបស់ព្រះអង្គឲ្យត្រេកអរ ដោយបញ្ហាវេយ្យាករណ៍មិនបានឡើយ បើព្រះសមណគោតមពោលនឹងអាត្មាអញ ក្នុងប្រស្នានោះ ថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះអ្នកមិនត្រូវធ្វើយ យ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរធ្វើយយ៉ាងនេះវិញទេតើ បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះថា សោណទណ្ឌព្រាហ្មណ៍ ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាចធ្វើព្រះទ័យរបស់ព្រះសមណគោតមឲ្យត្រេកអរ ដោយបញ្ហាវេយ្យាករណ៍បាន បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ កោគៈ ពាំងឡាយរបស់បុគ្គលនោះ គប្បីសាបសូន្យដែរ ដ្បិតកោគៈពាំងឡាយរបស់យើង សុទ្ធតែបានដោយយស ។ ធ្វើម្តេចហ្ន៎ នឹងបានព្រះសមណគោតមស្តីប្រស្នានឹងអាត្មាអញ ត្រង់ត្រៃវេទដែលអាត្មាអញបានសិក្សាមកអំពីសំណាក់អាចារ្យរបស់ខ្លួនអេះ អាត្មាអញមុខជានឹងធ្វើព្រះទ័យនៃព្រះសមណគោតម ឲ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍បានដោយពិត ។

(๑๘๔) អថខោ ភគវាតោ សោណទណ្ឌស្ស ព្រាហ្ម-
ណស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ ឯតទវោច
វិហញ្ញតិ ខោ អយំ សោណទណ្ឌោ ព្រាហ្មណោ
សកេន ចិត្តេន យទ្ធនាហំ សោណទណ្ឌំ ព្រាហ្មណំ
សកេ អាចរិយកេ តេវិជ្ជកេ បញ្ហំ បុច្ឆេយ្យន្តិ ។
អថខោ ភគវា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោច
កតីហិ បន ព្រាហ្មណ អង្គេហិ សមន្នាគតំ ព្រាហ្ម-
ណំ ព្រាហ្មណំ បញ្ចបេត្វា ព្រាហ្មណោស្មីតិ ច វទមានោ
សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។
អថខោ សោណទណ្ឌស្ស ព្រាហ្មណស្ស ឯតទហោសិ
យេ វត តេ អហោសិ ឥដ្ឋំ យំ អាកង្ខិតំ យំ អភិប្បេតំ
យំ អភិបត្ថិតំ អហោ វត មំ សមណោ គោតមោ
សកេ អាចរិយកេ តេវិជ្ជកេ បញ្ហំ បុច្ឆេយ្យ អទ្ធា វ
តស្សាហំ ចិត្តំ អារាធេយ្យំ បញ្ហស្ស វេយ្យាករណេនាតិ

(១៨៥) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីត្រិះរិះក្នុងចិត្ត របស់សោណទណ្ឌព្រាហ្មណ៍ ដោយព្រះហឫទ័យហើយ ក៏ទ្រង់ព្រះតម្រិះយ៉ាងនេះថា សោណទណ្ឌព្រាហ្មណ៍នេះចង្អៀតចង្អល់ ព្រោះតែគំនិតរបស់ខ្លួន បើដូច្នោះ គួរតថាគត សួរប្រស្នានឹងសោណទណ្ឌព្រាហ្មណ៍ ត្រង់ត្រៃវេទ ដែលគាត់បានសិក្សា មកអំពីសំណាក់អាចារ្យ របស់ខ្លួន (ឲ្យត្រូវតាមបំណងចុះ) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរសោណទណ្ឌព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ ចុះពួកព្រាហ្មណ៍បញ្ញត្តមនុស្សប្រកបដោយអង្គប៉ុន្មាន ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គប៉ុន្មាន) កាលបើពោលថា ខ្ញុំទ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។ គ្រានោះ សោណទណ្ឌព្រាហ្មណ៍ មានសេចក្តីត្រិះរិះ ដូច្នេះថា ទុហ្ន៎ អាត្មាអញមានសេចក្តីប្រាថ្នា សេចក្តីប៉ុនប៉ងឯ សេចក្តីពេញចិត្ត សេចក្តីប្រុងប្រៀងណា រួមមកហើយថា ទុ ធ្វើដូចម្តេចហ្ន៎ នឹងបានព្រះសមណគោតម សួរប្រស្នានឹងអាត្មាអញ ត្រង់ត្រៃវេទ ដែលអាត្មាអញបានសិក្សាមក អំពីសំណាក់អាចារ្យរបស់ខ្លួន អាត្មាអញនឹងធ្វើព្រះទ័យនៃព្រះសមណគោតមឲ្យត្រេកអរ ដោយបញ្ហាវេយ្យាករណ៍បានដោយពិត

តត្រ ចេ មំ សមណោ គោតមោ សកេ អាចរិយកេ តេវិជ្ជកេ បញ្ហំ បុដ្ឋតំ អន្ធា វ តស្សាហំ ចិត្តំ អារាធេស្សាមិ បញ្ញស្ស វេយ្យាករណានាតិ ។

(១៨៦) អថខោ សោណទណ្ឌោ ព្រាហ្មណោ អញ្ញតរេន កាយិ អនុវិលោកេត្វា បរិសំ ភគវន្តំ ឯតទវោច បញ្ចហិ ភោ គោតម អង្គេហិ សមន្នាគតំ ព្រាហ្មណោ ព្រាហ្មណិំ បញ្ញបេន្តំ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាភាសិំ អាបជ្ជេយ្យ កតមេហិ បញ្ចហិ ឥធ ភោ គោតម[1] ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយកោ ច[2] ហោតិ មន្តធរោ តិណ្ណំ វេទានំ ចារកូ សនិឃណ្ដុកេតុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ អកិរ្ហចោ ច[3] ហោតិ

---

๑ ម. ភោតមាតិ ន ទិស្សតិ ។ ๒-๓. ម ម. បិសទ្ទោ ន ទិស្សតិ ។

ក៏ឥឡូវនេះ ព្រះសមណគោតម សូរប្រសូនធំឯអាត្មាអញត្រង់ត្រៃវេទ ដែលអាត្មាអញបានសិក្សាមក អំពីសំណាក់អាចារ្យរបស់ខ្លួន ត្រូវចំសេចក្តីប្រាថ្នាអញនោះហើយ អាត្មាអញមុខជាឆ្លើព្រះទ័យ នៃព្រះសមណគោតម ឲ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍ បានដោយពិត ។

(១៨៦) លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ ក៏បង្អើបខ្លួនអើតមើលបរិសទ្យ ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គ ៥ ថាជាព្រាហ្មណ៍ ( មនុស្សដែលប្រកបដោយអង្គ ៥ នោះ) កាលបើពោលថា ខ្ញុំទាំងឡាយជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង អង្គទាំង ៥ នោះតើដូចម្តេច បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ក្នុងលោកនេះ មានជាតិដ៏ល្អទាំងពីរចំណែក គឺចំណែកខាងមាតានឹងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដរាបអំពីតំណនៃជីដូនជីតាជាគំរប់ ៧ មក មិនដែលមាននរណា ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើត ១ ជាអ្នកពាយមន្ត ចេះចាំមន្ត ជាអ្នកដល់ទូរត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេតុភៈ អក្ខរប្បភេទគឺសិក្ខានិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្ទាល់បទនឹងវេយ្យាករណ៍ ជាអ្នកមិនទុនថយគឺស្ទាត់ដំនាញ ក្នុងលោកាយតសាស្ត្រ នឹងមហាបុរិសលក្ខណាព្យាករណសាស្ត្រ ១ ជាអ្នកមានរូបល្អ

ธสฺสนียา ตาสาหนิเกา ปรมาย วณฺณาเวกฺขาย สมนฺนาคตา ปญฺหาวณฺหิ ปญฺหาวฺยากรณี อกุปฺปาวกาสา ธสฺสนาย สีลกฺขนฺธสฺส วิสุทฺธิยา วิสุทฺธิลาภาย สมนฺนาคตา ปณฺฑิตา ตตฺถ วิญฺญูหิ[๑] ปตฺตพฺพาภาวโต ภควา เอวมาห อตฺถิ ปนาวุโส เกจิ สมณพฺราหฺมณา ปรมาย วณฺณาเวกฺขาย สมนฺนาคตา ปณฺฑิตา วาลเวฬฺหกชาตา ปญฺหาวณฺหิ ปญฺหาวฺยากรณี อกุปฺปาวกาสา ธสฺสนาย สีลกฺขนฺธสฺส วิสุทฺธิยา วิสุทฺธิลาภาย สมนฺนาคตา ปณฺฑิตา ตตฺถ วิญฺญูหิ

គួរឲ្យពិតពិលរមិលមើល គួរឲ្យជ្រះថ្លា ប្រកបដោយសម្បុរដ៏ស្អាតក្រៃលែង មានសម្បុរដ៏ប្រសើរ មានសរីរៈស្រដៀងនឹងព្រហ្ម មានសព៌ាង្គកាយគួរឲ្យចង់មើលមិនលែង ១ ជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកច្បាស់មានច្បាស់ ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គ៤ ៥ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ៥ នេះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(១៨៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បណ្តាអង្គ៤ ៥ ប្រការនេះ អ្នកអាចលើកអង្គ ១ ចេញ ហើយបញ្ញត្តមនុស្សដែលប្រកបដោយអង្គត្រឹមតែ ៤ ថាជាព្រាហ្មណ៍វិញ (មនុស្សដែលប្រកបដោយអង្គ ៤ នោះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចបញ្ញត្តបាន បពិត្រព្រះគោតមដ៏ចំរើន ក៏បណ្តាអង្គ៤ ៥ យើងលើកអង្គ គឺសម្បុរចេញ ដ្បិតសម្បុរនឹងយកជាការពុំបាន បពិត្រព្រះគោតមដ៏ចំរើន

พฺราหฺมโณ ขตฺติโย สุชาโต โหติ มาตโต จ ปิตโต จ สํสุทฺธคฺคหณิโก ยาว สตฺตมา ปิตามหยุคา อกฺขิตฺโต อนุปกุฏฺโฐ ชาติวาเทน อชฺฌายโก จ โหติ มนฺตธโร ติณฺณํ เวทานํ ปารคู สนิฆณฺฑุเกตุภานํ สาครปฺปเภทานํ อิติหาสปญฺจมานํ ปทโก เวยฺยากรณโณ โลกายตมหาปุริสลกฺขณโณสุ อนวโย สีลวา จ โหติ วุฑฺฒสีลี วุฑฺฒสีลเนน สมนฺนาคโต ปณฺฑิโต จ โหติ เมธาวี ปหโม ฌานาภิญฺญานํ สเมตา โข ปเนเต จตูหิ อฏฺฐหิ สมนฺนาคตา พฺราหฺมณา พฺราหฺมณานญฺเจว พฺราหฺมณีนญฺจ ปโรสตาย สมฺมา วเทยฺยุ น จ ปน มุสาวาทาภิภูตา ๆ

(๑๘๘) เอเตสุ ปน พฺราหฺมเณสุ จตูสุ อฏฺฐงฺคสมนฺนาคเตสุ เอกจฺเจ อฏฺฐ ปหเย ปหาย เอตฺถ อฏฺฐหิ สมนฺนาคตา พฺราหฺมณานญฺเจว พฺราหฺมณีนญฺจ ปโรสตาย

๑ ฉ. ม. สุภา ๆ

ព្រាហ្មណ៍ (ដែលប្រកប ដោយអង្គត្រឹមតែ ៤ នោះ) គឺជាអ្នកមានជាតិដ៏ល្អ ចាំងពីចំណែក គឺចំណែកខាងមាតា ទំាងចំណែកខាងបិតា កើតអំពីផ្ទៃវិបរិសុទ្ធស្អាត ដកបអំពីតំណនៃជីដូនជីតាជាគំរប់ ៧ មក មិនដែលមាននរណា ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតបាន ១ ជាអ្នកពាយមន្ត ចេះចាំមន្ត ជាអ្នកដល់ទូវត្រើយនៃត្រៃវេទព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេតុភៈ ព្រមទាំងអក្ខរប្បភេទគឺសិក្ខានិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្គាល់បទទំាងវេយ្យាករណ៍ ជាអ្នកមិនខ្ចីថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ ទំាងមហាបុរិសលក្ខណៈ-ព្យាករណោសាស្ត្រ ១ ជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ប្លុកទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលទូវត្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍បញ្ចតុមនុស្ស ដែលប្រកបដោយអង្គត្រឹមតែ ៤ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ៤ នេះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(១៨៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទំាង ៤ នេះ អ្នកពាបលើកអង្គ ១ ចេញ ហើយបញ្ចតុមនុស្ស ដែលប្រកប ដោយអង្គត្រឹមតែ ៣ ថាជាព្រាហ្មណ៍វិញ (មនុស្ស

សម្មា វេទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។
សក្កា នោ តោតម ឥមេសំ ហិ នោ តោតម ចតុន្នំ
អដ្ឋានំ មន្តេ បឋយាម តំ ហិ មញ្ញ តាវសុទ្ធំ
យតោ ខោ នោ តោតម(๑) ព្រាហ្មណោ ឧភតោ
សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គ.
ហាណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ
អនុបក្កុដ្ឋោ ជាតិវាទេន សីលវា ច ហោតិ វុឌ្ឍសីលី
វុឌ្ឍសីលេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី
បឋមោ ឈានស្ស ឧតិយោ ឈានស្ស ភូជំ(๒) បត្តស្ស កាមានំ ឥមេ.
ហិ ខោ នោ តោតម តីហិ អង្គេហិ សមន្នាគតំ
ព្រាហ្មណា ព្រាហ្មណិំ បញ្ញាបេន្តិ ព្រាហ្មណោស្មីតិ ច
វទមានោ សម្មា វេទេយ្យ ន ច បន មុសាវាទំ
អាបជ្ជេយ្យាតិ ។

---

๑ ម. តោតមាតិ ន ទិស្សតិ ។ ๒ ម. ម. សុដ្ឋុ ។

ដែលប្រកបដោយអង្គ៣នោះ) កាលបើពោលថា ខ្ញុំទុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចបញ្ញត្តបាន បពិត្រព្រះគោតមដ៏ចំរើន ក៏បណ្តាអង្គទាំង ៤ នេះ យើងលើកអង្គ គឺមន្តចេញ ដ្បិតមន្តនឹងធ្វើអ្វីកើត បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ (ដែលប្រកបដោយអង្គត្រឹមតែ ៣ នោះ) គឺជាអ្នកមានជាតដ៏ល្អទាំងពីរចំណែក គឺចំណែកខាងមាតានឹងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដរាបអំពីតំណនៃដីដូនដីតាជាគំរប់ ៧ មក មិនដែលមាននរណា ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតបាន ១ ជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គត្រឹមតែ ៣ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ៣ នេះ) កាលបើពោលថា ខ្ញុំទុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(๑๘๙) ឥមេសំ បន ព្រាហ្មណា តំ ឈ្លាំ អង្គានំ សក្កា ឯកំ អង្គំ បហាយ តីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណំ បញ្ញបេតុំ ព្រាហ្មណោ ស្មីតិ ច វេទមាតោ សជ្ឈា វេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។ សក្កា កោ តោតម ឥមេសំ ហិ កោ តោតម តំ ឈ្លាំ អង្គានំ ជាតិ បហយាម កិំ ហិ ជាតិ ករំសុតិ យតោ ខោ កោ តោតម ព្រាហ្មណោ សីលវា ច ហោតិ វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី បឋមោ ឈានុតិយោ ឈា ឫជុំ បក្ខណ្ឌាន្តំ ឥមេហិ ខោ កោ តោតម តីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញបេន្តិ ព្រាហ្មណោ ស្មីតិ ច វេទមាតោ សជ្ឈា វេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។

## សោណទណ្ឌសូត្រ ការបញ្ញត្តិជាព្រាហ្មណ៍មានអង្គ ๒

(๑๘๙) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទាំង ๓ នេះ អ្នកអាចលើកអង្គ ๑ ចេញ ហើយបញ្ញត្តមនុស្ស ដែលប្រកបដោយអង្គត្រឹមតែ ๒ ថាជាព្រាហ្មណ៍វិញ (មនុស្សប្រកបដោយអង្គ ๒ នោះ) កាលបើពោលថា ខ្ញុំទ្ធុំជាព្រាហ្មណ៍ ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចបញ្ញត្តបាន បពិត្រព្រះគោតមដ៏ចំរើន ក៏បណ្តាអង្គទាំង ๓ នេះ យើងលើកអង្គ គឺជាតិចេញ ដ្បិតជាតិនឹងធ្វើអ្វីកើត បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ (ដែលប្រកបដោយអង្គត្រឹមតែ ๒ នោះ) គឺជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ๑ ជាអ្នកច្រើនមានច្រើនដោយ ជាបុគ្គលទី ๑ ឬទី ๒ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ๑ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គ ត្រឹមតែ ๒ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ๒ នេះ) កាលបើពោលថា ខ្ញុំទ្ធុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(๑๙๐) ឯវំ វុត្តេ តេ ព្រាហ្មណា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោចុំ មា ភវំ សោណទណ្ឌោ ឯវំ អវច មា ភវំ សោណទណ្ឌោ ឯវំ អវច អបវទតំ ភវំ សោណទណ្ឌោ វណ្ណំ អបវទតំ មន្តេ អបវទតំ ជាតឹ ឯកំសេន ភវំ សោណទណ្ឌោ សមណស្សុ-យេវ[1] តោតមស្ស ភគវតោ អនុបក្ខន្តឹតំ ។ អថខោ កកភ តេ ព្រាហ្មណេ ឯតទវោច សចេ ខោ តុម្ហាកំ ព្រាហ្មណានំ ឯវំ ហោតំ អយ្យស្សុតោ ច សោណទណ្ឌោ ព្រាហ្មណោ អកលរ្យាណភក្តារណោ ច សោណទណ្ឌោ ព្រាហ្មណោ ឧុបរ្ជញ្ញោ ច សោណទណ្ឌោ ព្រាហ្មណោ ន ច បហោតំ សោណទណ្ឌោ ព្រាហ្មណោ សមណេន តោតមេន សទ្ធឹ អស្មឹ វចនេ បតំ. មន្តេតុនំ តំជតុ សោណទណ្ឌោ ព្រាហ្មណោ តុម្ហេ មយា សទ្ធឹ មន្តេហិ សចេ បន តុម្ហាកំ ព្រាហ្មណានំ ឯវំ ហោតំ ឥមស្សុតោ ច សោណទណ្ឌោ ព្រាហ្មណោ កលរ្យាណភក្តារណោ ច សោណទណ្ឌោ ព្រាហ្មណោ

---

๑ ឧ. សមណស្សេវ ។ ម. សមណស្ស ។

(๑๙๐) កាលដែលសោណទណ្ឌព្រាហ្មណ៍ ពោលយ៉ាងនេះហើយ ពួកព្រាហ្មណ៍ទាំងនោះ ក៏បាននិយាយនឹងសោណទណ្ឌព្រាហ្មណ៍ដូច្នេះថា សោណទណ្ឌដ៏ចំរើន កុំនិយាយយ៉ាងនេះ សោណទណ្ឌដ៏ចំរើន កុំនិយាយយ៉ាងនេះឡើយ សោណទណ្ឌដ៏ចំរើន និយាយបង្អាប់សម្បុរ និយាយបង្អាប់មន្ត និយាយបង្អាប់ជាតិ សោណទណ្ឌដ៏ចំរើន បណ្តាយ តាមពាក្យរបស់ព្រះសមណគោតម ដោយចំណែកមួយហើយតើ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកព្រាហ្មណ៍ទាំងនោះដូច្នេះថា បើអ្នកទាំងឡាយជាព្រាហ្មណ៍មានសេចក្តីយល់ឃើញថា សោណទណ្ឌ-ព្រាហ្មណ៍ ជាមនុស្សចេះដឹងតិចផង សោណទណ្ឌព្រាហ្មណ៍ ពោលពាក្យមិនពីពោះផង សោណទណ្ឌព្រាហ្មណ៍ជាអ្នកឥតប្រាជ្ញាផង សោណទណ្ឌ-ព្រាហ្មណ៍ មិនល្មមនឹងនិយាយឆ្លើយឆ្លងពាក្យនេះ ជាមួយនឹងព្រះសមណ-គោតមបានផង សោណទណ្ឌព្រាហ្មណ៍ ចូរឈប់ចុះ អ្នកទាំងឡាយ ចូរនិយាយឆ្លើយឆ្លងជាមួយនឹងតថាគតវិញ តែបើអ្នកទាំងឡាយជាព្រាហ្ម-ណ៍មានសេចក្តីយល់ឃើញយ៉ាងនេះថា សោណទណ្ឌព្រាហ្មណ៍ជាមនុស្ស ចេះដឹងច្រើនផង សោណទណ្ឌព្រាហ្មណ៍ ពោលពាក្យពីពោះផង

បណ្ឌិតោ ច សោណទណ្ឌោ ព្រាហ្មណោ បហោតិ ច សោណទណ្ឌេន ព្រាហ្មណេន សមណេន គោតមេន សទ្ធឹ អស្មឹ វាចនេ បតិមន្តេតុន្តិ តិដ្ឋថ តុម្ហេ សោណទណ្ឌោ ព្រាហ្មណោ មយា សទ្ធឹ បតិមន្តេតូតិ ។

(១៩១) ឯវំ វុត្តេ សោណទណ្ឌោ ព្រាហ្មណោ ភគវន្តំ ឯតទវោច តិដ្ឋតុ ភវំ គោតមោ តុណ្ហី ភវំ គោតមោ ហោតុ អហាមេវ តេសំ សមាទម្មេន បដិវចនំ ភវិស្សតីតិ ។ អថខោ សោណទណ្ឌោ[1] តេ ព្រាហ្មណោ ឯតទវោច មា ភវន្តោ ឯវំ អវចុត្ថ មា ភវន្តោ ឯវំ អវចុត្ថ អបវទតិ ភវំ សោណទណ្ឌោ ព្រាហ្មណោ វណ្ណំ អបវទតិ មន្តេ អបវទតិ ជាតឹ ឱកាសេន ភវំ សោណទណ្ឌោ ព្រាហ្មណោ សមណសេ្សវ គោតមស្ស វាទំ អនុបក្ខន្ទតីតិ ជាហំ ភោ អបវទាមិ វណ្ណំ វា មន្តេ វា ជាតឹ វាតិ ។

---

๑. ម. សោណទណ្ឌោ ព្រាហ្មណោ ។

សោណទណ្ឌព្រាហ្មណ៍ ជាអ្នកប្រាជ្ញផង សោណទណ្ឌព្រាហ្មណ៍ ល្មមទំនងនិយាយឆ្លើយតួនពាក្យនេះ ជាមួយនឹងព្រះសមណគោតមបានផង អ្នកចាំងឡាយ ចូរឈប់ចុះ ចូរឲ្យសោណទណ្ឌព្រាហ្មណ៍និយាយឆ្លើយតួនជាមួយនឹងតថាគតវិញ ។

(๑๙๑) កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សោណទណ្ឌព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចំរើន បង្អង់សិនចុះ សូមព្រះគោតមដ៏ចំរើន គង់ស្ងៀមចុះ ខ្ញុំព្រះអង្គនឹងធ្វើនូវពាក្យតបត ប្រកបដោយហេតុ ដល់ព្រាហ្មណ៍ទាំងនោះវិញ ។ លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍បាននិយាយនឹងពួកព្រាហ្មណ៍ទាំងនោះដូច្នេះថា នែអ្នកចាំងឡាយដ៏ចំរើន អ្នកចាំងឡាយកុំពោលយ៉ាងនេះឡើយ នែអ្នកចាំងឡាយដ៏ចំរើន អ្នកចាំងឡាយកុំពោលយ៉ាងនេះថា សោណទណ្ឌព្រាហ្មណ៍ដ៏ចំរើន និយាយបង្អាប់សម្បុរ និយាយបង្អាប់មន្ត និយាយបង្អាប់ជាតិ សោណទណ្ឌព្រាហ្មណ៍ដ៏ចំរើនបណ្តាយតាមវាទៈរបស់ព្រះសមណគោតម ដោយចំណែកមួយដូច្នេះឡើយ ម្នាលអ្នកដ៏ចំរើនទាំងឡាយ ខ្ញុំមិនមែននិយាយបង្អាប់សម្បុរ ឬមន្តនឹងជាតិទេ ។

(๑๙๒) តេន ខោ បន សមយេន សោណទណ្ឌោ ព្រាហ្មណោ ព្រាហ្មណានំ កាតនេយ្យោ អជ្ឈាយកោ ជាម មាណវកោ តស្សំ បរិសាយំ ឯកមន្តេ ហោតិ ។ អថ ខោ សោណទណ្ឌោ ព្រាហ្មណោ តេ ព្រាហ្មណេ ឯតទវោច បស្សន្តិ ភោ ភោន្តោ ឥមំ អជ្ឈកំ មាណវកំ អម្ហាកំ កាតនេយ្យន្តិ ។ ឯវំ ភោ អជ្ឈោ ខោ ភោ មាណវកោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អភិក្កន្តវណ្ណោ ទស្សនាយ ជាស្ស ឥមំស្មិំ បរិសាយំ(๑) សមសមោ អត្តំ វណ្ណេន បដិពលោ សមណំ ភោតមំ ។ អជ្ឈោ ខោ ភោ មាណវកោ អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុភេតុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ អហមស្ស មន្តេ វាចេតា

๑ ម. ឥមិស្សា បរិសាយ ។

(๑๙๒) សម័យនោះឯង មានមាណព (មនុស្សដំទន់) ម្នាក់ ឈ្មោះអង្គក: ត្រូវជាកូយសោណទណ្ឌព្រាហ្មណ៍ អង្គុយក្នុងពួកបរិសទ្យ នោះដែរ ។ លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ បាននិយាយនឹងពួកព្រាហ្មណ៍ទាំងនោះដូច្នេះថា អ្នកដ៏ចំរើនទាំងឡាយ បានឃើញមាណព ឈ្មោះអង្គក:នេះជាកូយយើងដែរឬទេ ។ ព្រាហ្មណ៍ទាំងនោះ ក៏ឆ្លើយថា បពិត្រលោកដ៏ចំរើន បានឃើញដែរ បពិត្រលោកដ៏ចំរើន អង្គក-មាណព មានរូបល្អ គួរពិតពិល រមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង មានសម្បុរដ៏ប្រសើរ មានសរីរ:ស្រដៀងនឹងព្រហ្ម មានសព៌ាង្គកាយ គួរឲ្យចង់មើលមិនលែង ក្នុងបរិសទ្យនេះ រកអ្នកណាឲ្យមានសម្បុរស្មើនឹងអង្គកមាណពនេះ គ្មានឡើយ លើកលែងតែព្រះសមណគោតមចេញ ។ សោណទណ្ឌព្រាហ្មណ៍ពោលថា ម្នាលអ្នកទាំងឡាយដ៏ចំរើន អង្គកមាណព ជាអ្នកកាយមន្ត ចេះចាំមន្ត ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរ និឃណ្ឌុ គម្ពីរ កេតុភ: អក្ខ-រប្បភេទគឺសិក្ខានឹងនិរុត្តិ ដែលមានគម្ពីរឥតិហាស:ជាគំរប់ ៥ ជាអ្នកចាំស្ទាត់នូវបទនឹងវេយ្យាករណ៍ ជាអ្នកស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ នឹងមហាបុរិសលក្ខណៈព្យាករណសាស្ត្រ ឯខ្ញុំជាអ្នកបង្រៀនមន្ត ដល់ក

អដ្ឋកោ ខោ កោ មាណវកោ ឧភតោ សុជាតោ មាតិ-
តោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា
បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន
អភិសញ្ញ មាតាបិតរោ ជាជាមិ អដ្ឋកោ ខោ កោ
មាណវកោ ចាណាំបិ ហានេយ្យ អធិដ្ឋិបិ អាធិយេយ្យ
បរិហរិបិ កាយេយ្យ មុសាបិ ភាសេយ្យ មជ្ជំបិ បិវេយ្យ
ឯត្តធាធិ(๑) កឺ វណ្ណោ ភវិស្សតិ កឺ មត្តា(๒) កឺ ជាតិ
យតោ ខោ កោ ព្រាហ្មណោ សីលវា ច ហោតិ
វុឌ្ឍសីលី វុឌ្ឍសីលេន សមណ្ណាគតោ បណ្ឌិតោ ច
ហោតិ មេធាវី បឋមោ ឈានស្ស លាភី ហោតិ បញ្ចហង្គេហិ
វិប្បហីនេហិ ឆហិ អង្គេហិ សមន្នាគតំ ព្រាហ្មណោ
ព្រាហ្មណិ បញ្ចង្គិកំ ព្រាហ្មណោស្មីតិ ច វេទមាគោ
សម្ភ វេយ្យ ន ច បន មុសាភិ អាបជ្ជេយ្យាតិ ។

---

๑ ខ. ម. ឯត្តកាធិ ភោ ។ ๒ ខ. មត្តំ ។

## សោណទណ្ឌសូត្រ ការពោលអំពីគុណរបស់អង្គកមាណព

ម្នាលអ្នកចំឆ្នាយដ៏ចំរើន ឯអង្គកមាណពមានជាតដ៏ល្អចាំពីរចំណែក គឺចំណែកខាងមាតានឹងចំណែកខាងបិតា កើតអំពីផ្នែដ៏បរិសុទ្ធស្អាត ដរាបអំពីតំណនៃដីដូនដីតាជាគំរប់ ៧មក មិនដែលមាននរណាមួយពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតបាន ខ្ញុំក៏ស្គាល់មាតាបិតារបស់ឯ ម្នាលអ្នកចំឆ្នាយដ៏ចំរើន តែអង្គកមាណពសម្លាប់សត្វខ្លះ យកទ្រព្យដែលគេមិនបានឲ្យខ្លះ ប្រព្រឹត្តខុសក្នុងកាមារម្មណ៍ខ្លះ និយាយកុហកខ្លះ ផឹកទឹកស្រវឹងខ្លះ ឥឡូវបើលើកយកសេចក្តីនេះមកនិយាយ ណា: នឹងយកជាការអ្វីបាន មន្តនឹងយកជាការអ្វីបាន ជាតិនឹងយកជាការអ្វីបាន ម្នាលអ្នកចំឆ្នាយ ដ៏ចំរើន ព្រាហ្មណ៍ (ដែលប្រកបដោយអង្គ ២) គឺជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ប្លែទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ១ ម្នាលអ្នកចំឆ្នាយដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្ស ដែលប្រកបដោយអង្គ ត្រឹមតែ ២ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ២ នេះ) កាលបើពោលថា ខ្ញុំទាំងព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(๑๙๓) ឥមេសំ បន ព្រាហ្មណា ទ្វិន្នំ អង្គានំ សក្កា ឯតំ អង្គំ ឋបយិត្វា ឯកេន អង្គេន សមន្នាគតំ ព្រាហ្មណំ បញ្ញបេតុំ ព្រាហ្មណោស្មីតិ ច វេទមាតោ សម្មា វេទេយ្យ ន ច បន មុសាភាសំ អាបជ្ជេយ្យាតិ ។ តោ ហិទំ តោ តោតម សីលបរាមោតា ហិ តោ តោតម បញ្ច បញ្ចបរាមោតំ(๑) សីលំ យត្ត សីលំ តត្ត បញ្ច យត្ត បញ្ច តត្ត សីលំ សីលវាតោ បញ្ច បញ្ច-តោ សីលំ សីលប្បញ្ញេនញ្ច បន លោកស្មឹ អគ្គមក្ខាយតិ សេយ្យថាបិ តោ តោតម មហាព្រហ្ម ឯវ មហន្តំ តោ-វេយ្យ ចាទេន ឯវ ចាទំ តោវេយ្យ ឯវមេវ តោ តោតម សីលបរាមោតា បញ្ច បញ្ចបរាមោតំ សីលំ យត្ត សីលំ តត្ត បញ្ច យត្ត បញ្ច តត្ត សីលំ សីលវាតោ បញ្ច

๑ ឧ. បញ្ចបរាមោតំ ។

(๑๙๓) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទាំង៦នេះ អ្នកអាចលើកអង្គមួយចេញ ហើយបញ្ញត្តមនុស្សដែលប្រកបដោយអង្គត្រឹមតែ ๑ ថាជាព្រាហ្មណ៍វិញ (ទាំងមនុស្សដែលប្រកបដោយអង្គតែ ๑ នោះ) កាលបើពោលថា ខ្ញុំនឹងជាព្រាហ្មណ៍ដូច្នេះឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ? សោណទណ្ឌព្រាហ្មណ៍ ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន អង្គទាំង ๖ នេះ នឹងលើកអង្គណាមួយចេញមិនបានទេ បពិត្រព្រះគោតមដ៏ចំរើន ដ្បិតប្រាជ្ញារមែងដំរះសីលឲ្យបរិសុទ្ធ សីលសោតក៏រមែងដំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញាប្រកបជាគុណធម៌ប្រសើរក្នុងលោក បពិត្រព្រះគោតមដ៏ចំរើន បុគ្គលលាងដៃ ដោយដៃក្តី លាងជើង ដោយជើងក្តី សេចក្តីនេះមានឧបមាយ៉ាងណាមិញ បពិត្រព្រះគោតមដ៏ចំរើន មានឧបមេយ្យដូចជា ប្រាជ្ញា រមែងដំរះសីលឲ្យបរិសុទ្ធ សីលសោតក៏រមែងដំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា

បញ្ញវតោ សីលំ សីលប្បញ្ញាណញ្ច បន លោកស្មឹ អគ្គមក្ខាយតីតិ ។

(๑๙๖) ฝ่ายเมตัง พราหฺมณา ฝ่ายเมตัง พราหฺมณา สีลปริโภคา หิ พราหฺมณา ปญฺญา ปญฺญาปริโภคัง สีลัง ยสฺส สีลัง ตสฺส ปญฺญา ยสฺส ปญฺญา ตสฺส สีลัง สีลวตา ปญฺญา ปญฺญวตา สีลัง สีลปฺปญฺญาณญฺจ បន លោកស្មឹ អគ្គមក្ខាយតិ เสยฺยถาปิ พราหฺมณา มหาปถวิ ก มหนฺโต ปาเวยฺยา ทาเฒน ก ทาฒัง ปาเวยฺยา ฝ่ายเมว โข พราหฺมณา สีลปริโภคา ปญฺญา ปญฺญาปริโภคัง สีลัง ยสฺส สีลัง ตสฺส ปญฺญา ยสฺส ปญฺญา ตสฺส สีลัง สีลวตา ปญฺญา ปญฺญวตา สีลัง สีลปฺปญฺญาณญฺจ បន លោកស្មឹ អគ្គมក្ខាយតីតិ กตมัง បន តัง พราหฺมณา สีลัง กตมา จ ปญฺญาติ ?

អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញានេះ អ្នកប្រាជ្ញតែងពោលថាជាគុណធម៌ដ៏ប្រសើរ ក្នុងលោក ។

(១៩៤) ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ សេចក្តីខ្ពស់ខ្ពាន់យ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ សេចក្តីខ្ពស់ខ្ពាន់យ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ ដ្បិតប្រាជ្ញា រមែងដំរះសីលឲ្យបរិសុទ្ធ សីលសោត ក៏រមែងដំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញា អ្នកប្រាជ្ញតែងពោលថាជាគុណធម៌ដ៏ប្រសើរ ក្នុងលោក ម្នាលព្រាហ្មណ៍ បុគ្គលលាងដៃដោយដៃក្តី លាងដើងដោយដើងក្តី សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលព្រាហ្មណ៍ មានឧបមេយ្យដូចជាប្រាជ្ញា រមែងដំរះសីលឲ្យបរិសុទ្ធ សីលសោត ក៏រមែងដំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញា អ្នកប្រាជ្ញតែងពោលថាជាគុណធម៌ដ៏ប្រសើរ ក្នុងលោក ម្នាលព្រាហ្មណ៍ បុគ្គលសីលនោះដូចម្តេច ប្រាជ្ញានោះដូចម្តេច ។ សោណទណ្ឌព្រាហ្មណ៍ ក្រាប

ฬตฺตกปรมา ๘[๑] มยิ๋ เภา โคตม กาสฺมึ[๒] อหุตฺวา สาตฺถ ราต ภวิสฺสเยว[๓] โคตมิ ปชาปติ ฬตสฺส ภาสิตสฺส อตฺถาตี ฯ

[๑๙๕] เตนหิ ภฺราหฺมณ สุณาหิ สาธุกๆ มนสิกโรหิ ภาสิสฺสามีติ ฯ เอวๆ ภนฺเตติ โข โสณทณฺฑ ภฺราหฺมณ ภควโต ปจฺจสฺโสสิ ฯ ภควา เอตทโวจ ส ภฺราหฺมณ ตถาคโต โลเก อุปฺปชฺชติ อรหๆ สมฺมาสมฺพุทฺโธ ฯ เป ฯ (ยถา สามญฺญผเล เอวๆ วิตฺถาเรตพฺพๆ) ฯ เป ฯ เอวๆ โข ภน ภฺราหฺมณ ภิกฺขุ สีลสมฺปนฺโน โหติ ฯ ส๎ส โข ตๆ ภฺราหฺมณ สีลๆ ฯ ปฐมๆ ฌานๆ อุปสมฺปชฺช วิหรติ ฯ ทุติยๆ ฌานๆ ฯ ตติยๆ ฌานๆ ฯ จตุตฺถๆ ฌานๆ อุปสมฺปชฺช วิหรติ ฯ เป ฯ ภฺราหฺมณ ภิกฺขุ จิตฺตๆ อภินีหรติ อภินินฺนาเมติ ฯ เป ฯ ส๎ส เอวๆ ภวิสฺสติ ภญฺญาย ฯ เป ฯ

---

๑ ฉ. ม. ๑ ฯ ๒ ฉ. ม. ภิกฺขุสฺมึ ฯ ๓ ฉ. ภวิสฺสเยว เภ ฯ

បង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គគ្រាន់តែបានដឹងថា សីលនឹងប្រាជ្ញាប៉ុណ្ណោះ ឯត្រង់សេចក្តីអធិប្បាយ (មិនដឹងជា) ដូចម្តេចទេ សូមព្រះគោតមដ៏ចំរើន ទ្រង់ត្រាស់បំភ្លឺសេចក្តីអធិប្បាយនៃភាសិតនុ៎ះឲ្យបាន ។

(๑๙๕) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរអ្នកយកចិត្តទុកដាក់ឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ សោណទណ្ឌព្រាហ្មណ៍ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលព្រាហ្មណ៍ ព្រះតថាគតបានកើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ (រឿងនេះ អ្នកប្រាជ្ញគប្បីសំដែងឲ្យពិស្តារដូចគឺងសាមញ្ញផលសូត្រធម៌ចុះ) ។បេ។ ម្នាលព្រាហ្មណ៍ តថាគតមានសីលយ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ នេះឯង ដែលហៅថាសីលនោះ។ តថាគតបានសម្រេចបឋមជ្ឈាន សម្រេចឥរិយាបថទៅ ។ ទុតិយជ្ឈាន ។តតិយជ្ឈាន ។ បានសម្រេចចតុត្ថជ្ឈាន សម្រេចឥរិយាបថទៅ ។បេ។ តថាគតាញ្ញនាំបង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ ។បេ។ នេះឯង ជា (សេចក្តីអធិប្បាយ) នៃប្រាជ្ញារបស់តថាគតនោះ ។បេ។

ឆាបរំ ឥត្តត្តាយាតំ បជាឆាតំ ។ ឥធម្បាស្ស មោតំ បញ្ញាយ ។ អយំ ខោ សា ព្រាហ្មណា បញ្ញាតំ ។

(๑๙๖) ឃំ ពុទ្ធេ សោណទណ្ឌោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម ឯក្កុដ្ឋិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ អធិវាសេតុ ច មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សោណទណ្ឌោ ព្រាហ្មណោ

ភិក្ខុជ័ន្ធប្បាស់ថា កិច្ចដទៃក្រៅអំពីនេះមិនមានទេ ។ នេះឯង (ជាសេចក្តីអធិប្បាយ) នៃប្រជ្ញារបស់ភិក្ខុនោះ ។ ម្នាលព្រាហ្មណ៍ នេះឯងដែលហៅថា ប្រជ្ញានោះ ។

(១៩៦) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សោណទណ្ឌព្រាហ្មណ៍ បានក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើនទ្រង់សំដែង ដោយអនេកបរិយាយ (នេះ) គួរនាដូចជាមនុស្សផ្ងារវត្ថុដែលផ្កាប់ ឬបើកបង្ហាញវត្ថុដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាមនុស្ស កាន់ប្រទីបប្រោលបំភ្លឺកន្លែងងងឹតដោយគិតថា មនុស្សដែលមានភ្នែក (ភ្លឺ) មើលឃើញរូបច្បាស់បាន ខ្ញុំព្រះអង្គសូមដល់ព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចំរើន ជ្រាបថា ខ្ញុំព្រះអង្គជាឧបាសក ដល់សរណគមន៍ស្មើដោយជីវិតចាប់ដើមអំពីថ្ងៃនេះទៅ មួយទៀត សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃទ្រង់ទទួលចង្ហាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លុះសោណទណ្ឌព្រាហ្មណ៍

กตวาโต อฉิกสนฺโ วิธิตฺวา ขุชฺชายาสตา กตวนฺโ
อกิกาเนตฺวา ปเนกฺขิณาโ กตฺวา ปกฺกามิ ฯ

(๑๙๗) อถโข สาณทณฺฑา ปฺราหฺมณา
ตสฺสา รตฺติยา อจฺจเยน สเก นิเวสเน ป-
ณีตาโ ขาทนียาโ โภชนียาโ ปฏิยาเปตฺวา กต-
โต กาลาโ อาโรเจาเปสิ กาโล โภ โตตม
นิฏฺิโต กตฺตพฺโ ฯ อถโข กตก บุพฺพณฺหสมยาโ
นิวาเสตฺวา ปตฺตจีวรมาทาย สทฺธิ กิกฺขุสเตฺ
เยน สาณทณฺฑสฺส ปฺราหฺมณสฺส นิเวสนา
เตนุปสงฺกมิ อุปสงฺกมิตฺวา ปญฺเตฺ อาสเน นิสีทิ ฯ
อถโข สาณทณฺฑา ปฺราหฺมณา พุทฺธปฺปมุขา
กิกฺขุสงฺฆา ปณีเตน ขาทนียเน โภชนียเน
สหตฺถา สนฺตปฺเปสิ สมฺปวาเรสิ ฯ

(๑๙๘) อถโข สาณทณฺฑา ปฺราหฺมณา
กตวนฺโ กุตฺถาริ ขิณิตปตฺตปาณี อญฺตรา นีจา อาสนา
กเหตฺวา เอกมนฺโ นิสีทิ ฯ เอกมนฺโ นิสินฺโ
โข สาณทณฺฑา ปฺราหฺมณา กตวนฺโ เอตทโวจ

ដឹងច្បាស់ថា ព្រះអង្គទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយដើរចេញទៅ ។

(១៩៧) លុះដល់វេលាព្រឹកឡើង សោណទណ្ឌព្រាហ្មណ៍ បង្គាប់ជនទាំងឡាយ ឲ្យចាត់ចែងធ្វើខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសាកុងលំនៅរបស់ខ្លួនស្រេចហើយ ទើបចាត់បម្រើឲ្យទៅក្រាបបង្គំទូលកត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កត្តកាលដល់ហើយ ចង្ហាន់ក៏បានរៀបចំស្រេចហើយ ។ លំដាប់នោះ លុះដល់បុព្វណ្ហសម័យ ព្រះមានព្រះភាគ ទ្រង់ចាត្រនឹងចីវរហើយ ស្តេចចូលទៅកាន់លំនៅនៃសោណទណ្ឌព្រាហ្មណ៍ ព្រមដោយភិក្ខុសង្ឃ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ ។ វេលានោះ សោណទណ្ឌព្រាហ្មណ៍បានអង្គាសខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពីសា ដោយដៃខ្លួនឯង ប្រគេនព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែប្រកែកលែងទទួលទៀត ។

(១៩៨) លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តចេញក្នុងបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសោណទណ្ឌព្រាហ្មណ៍ អង្គុយស៊ប់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះ

អហញ្ចេវ ខោ បន តេ តោតមេ បរិសតិ សមាធោ អាសជ្ជ វុដ្ឋហិត្វា តវត្តំ តោតមំ អភិវាទេយ្យុំ តេន មំ សា បរិសា បរិភវេយ្យ យំ ខោ បន សា បរិសា បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ តោតាបិ តស្ស ហាយេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ តោតា អហញ្ចេវ ខោ បន តេ តោតមេ បរិសតិ សមាធោ អញ្ជលឹ បគ្គណ្ហោយ្យុំ អាសជ្ជ មេ តំ ភវំ តោតមោ បច្ចុដ្ឋានំ ជានេតុ អហញ្ចេវ ខោ បន តេ តោតមេ បរិសតិ សមាធោ វុដ្ឋានំ ឧទ្ធរេយ្យុំ សិរសា មេ តំ ភវំ តោតមោ អភិវាទនំ ជានេតុ អហញ្ចេវ ខោ បន តេ តោតមេ យានគតេ សមាធោ យានា បច្ចោរោហិត្វា តវត្តំ តោតមំ អភិវាទេយ្យុំ តេន មំ សា បរិសា បរិភវេយ្យ យំ ខោ បន សា បរិសា បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ តោតាបិ តស្ស

ភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន បើខ្ញុំព្រះអង្គកំពុងនៅក្នុងបរិសទ្យ ហើយនឹងក្រោកចាកអាសនៈ ថ្វាយបង្គំព្រះគោតមដ៏ចំរើន បរិសទ្យនោះ មុខជានឹងមើលងាយខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង បរិសទ្យនោះ (បើ) មើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះ ក៏នឹងសាបសូន្យទៅផង (បើ) យសរបស់បុគ្គលណាសាបសូន្យហើយ កោគៈតំឆ្ងាយរបស់បុគ្គលនោះ ក៏នឹងសាបសូន្យទៅផង ដ្បិតកោគៈតំឆ្ងាយរបស់យើងខ្ញុំសុទ្ធតែបានមកដោយសារយសតែប៉ុណ្ណោះ បពិត្រព្រះគោតមដ៏ចំរើន តែបើខ្ញុំព្រះអង្គកំពុងនៅក្នុងបរិសទ្យ គួរប្រណាមអញ្ជលីបាន សូមព្រះគោតមដ៏ចំរើន ចាំទុកនូវការប្រណាមអញ្ជលីនោះ ថាជាការក្រោកអំពីអាសនៈរបស់ខ្ញុំព្រះអង្គចុះ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត (បើ) ខ្ញុំព្រះអង្គកំពុងនៅក្នុងបរិសទ្យ គួរដោះឈ្នួតក្បាលបាន សូមព្រះគោតមដ៏ចំរើន ចាំទុកនូវការដោះឈ្នួតក្បាលនោះ ថាជាការថ្វាយបង្គំដោយសិរ្សៈរបស់ខ្ញុំចុះ បពិត្រព្រះគោតមដ៏ចំរើន (បើ) ខ្ញុំព្រះអង្គកំពុងជិតនៅលើយានហើយ ចុះពីលើយានមកថ្វាយបង្គំព្រះគោតមដ៏ចំរើន បរិសទ្យនោះមុខជានឹងមើលងាយខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង បរិសទ្យនោះ (បើ) មើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះ ក៏នឹងសាបសូន្យទៅផង យសរបស់បុគ្គលណាសាបសូន្យហើយ កោគៈតំឆ្ងាយ របស់បុគ្គលនោះ

ภาเยยฺยุ์ ยเสาลทฺธา ខោ បនម្ភាកំ គោតา អภา-
ញ្ញេវ ខោ បន តោ គោតម យាទិសោ សមาโณ
បเรាธลฺเล អฏฺฐาเนยฺยุ์ យาทา เม តំ ภវំ គោตเมา
បฏิภาเคหาธิ ชาเนยฺยุ์ អภาญ្ញេវ ខោ បន តោ គោตม
យาទิสโต សมาโณ ชนฺตุ์ អปชาเนยฺยุ์ สំวาเส เม
តំ ภวំ គោตเมา អភิภายิตพฺพំ ชาเนยฺยุ์ ។ អថខោ
ภគวา เสาណทณฺฑំ ព្រាហฺมณំ ឯตทโวจ តេន
หิ ตฺวំ พฺราหฺมณ ยาวตเกน ตฺวំ อตฺตโน
ปฏิภานេน สกฺโกสิ តาวตเกน ตฺวំ ปฏิภาหิ
เม ตฺวา ឧฏฺฐายาสนา បក្កាมิ ។

เสาณทณฺฑสุตฺตំ បឋมំ ឯกាทสមំ ។

ក៏ទំនងសាបសូន្យទៅផង ដ្បិតកោគៈចាំងល្បាយរបស់យើងសុទ្ធតែឋានមកដោយសារតែយសប៉ុណ្ណោះ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត ខ្ញុំព្រះអង្គកំពុងឋិតនៅលើយានហើយ នឹងលើកជង្ឃញ្ញាឡើង សូមព្រះគោតមដ៏ចំរើន ទ្រង់ចាំទុកនូវកិរិយាលើកជង្ឃញ្ញានោះ ថាជាកិរិយាចុះអំពីយានរបស់ខ្ញុំព្រះអង្គចុះ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត (ទៅ) ខ្ញុំព្រះអង្គកំពុងឋិតនៅលើយានហើយ គួរដំឡោះឆត្រឋាន សូមព្រះគោតមដ៏ចំរើន ទ្រង់ចាំទុកនូវការដំឡោះឆត្រនោះ ថាជាកិរិយាថ្វាយបង្គំដោយសិរ្សៈរបស់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងពន្យល់សោណទណ្ឌព្រាហ្មណ៍ (ឲ្យយល់ប្រយោជន៍ក្នុងបច្ចុប្បន្ននឹងបរលោក) ឲ្យជឿជាក់ (ក្នុងកុសលធម៌) ឲ្យសង្វាតធ្វើការកុសល ឲ្យរីករាយ (ដោយគុណដែលមានក្នុងខ្លួន) ដោយធម្មីកថា រួចទ្រង់ក្រោកអំពីអាសនៈ ហើយទ្រង់ពុទ្ធដំណើរចេញទៅ ។

ចប់ សោណទណ្ឌសូត្រ ទី ៤ ។

# មាតិកាបត្តាំ

## សុត្តន្តបិដកេ ទីឃនិកាយស្ស បឋមោ ភាគោ

## សីលក្ខន្ធវគ្គោ

### ព្រហ្មជាលសុត្តំ បឋមំ


| | | អង្កៀ |
|---|---|---|
| ព្រហ្មជាលសុត្តេ | សុត្តនិទានំ . . . . . | ៣ |
| | ចូឡសីលំ . . . . . | ៧ |
| | មជ្ឈិមសីលំ ពីជគាមភូតគាមសមារម្ភាទិ.. | ១៣ |
| | មជ្ឈិមសីលំ ដូតបច្ចមាទដ្ឋានានុយោគោ .. | ១៥ |
| | មជ្ឈិមសីលំ មណ្ឌនវិភូសនដ្ឋានានុយោគោ | ១៧ |
| | មជ្ឈិមសីលំ វិគ្គាហិកកថា . . . . | ១៩ |
| | មជ្ឈិមសីលំ កុហនលបនាទិ . . . . | ២១ |
| | មហាសីលំ តិរច្ឆានវិជ្ជា . . . . . | ២៣ |
| | បុព្វន្តកប្បិកា បុព្វន្តិកាសានុស្សតិ . . . | ៣១ |
| | បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ . . . . | ៤៣ |

# សុត្តន្តបិដក ទីឃនិកាយ បឋមភាគ

## សីលក្ខន្ធវគ្គ

### ព្រហ្មជាលសូត្រ ទី ១


| | | លេខទំព័រ |
|---|---|---|
| ព្រហ្មជាលសូត្រ | សុត្តនិទាន . . . . . | ៣ |
| | ទ្វេឧបសីល. . . . . | ៧ |
| | មជ្ឈិមសីល ការធ្វើពីដំណាមនឹងភ្លុតតាមឲ្យវិនាស ជាដើម | ១៣ |
| | មជ្ឈិមសីល ការប្រកបល្បែងជាស្ថានដែលជាហេតុជាទីតាំង នៃសេចក្តីប្រមាទ. . . . . | ១៥ |
| | មជ្ឈិមសីល ប្រកាន់ខ្លួនថាជាទីតាំងនៃការប្រជាប់ស្អិត-ស្អាងរាងកាយ . . . . . | ១៧ |
| | មជ្ឈិមសីល និយាយអំពីពាក្យច្រណែនឯងប្រជែងឯង . . | ១៩ |
| | មជ្ឈិមសីល ការពោលកុហក និងការពោលពាក្យពាក់ព័ន្ធ ជាដើម . . . . . | ២១ |
| | មហាសីល តិរច្ឆានវិជ្ជា. . . . . | ២៣ |
| | ការកំណត់ខ្លួនចំណែកនៃទន្ទឹងដើម ប្រព្រឹត្តិសាសនុស្សត . | ៣១ |
| | ការកំណត់ខ្លួនចំណែកនៃទន្ទឹងដើម ហេតុ ៤ យ៉ាង . | ៤៣ |

# មាតិកាបត្តាធិ


| | | អង្កៃ |
|---|---|---|
| ព្រហ្មជាលសុត្តៃ | បុព្វន្តកប្បិកា បុព្វេនិវាសានុស្សតិ . . . | ៤៥ |
| | បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ . . . . . | ៤៧ |
| | បុព្វន្តកប្បិកា អមរាវិក្ខេបិកា . . . . | ៦៣ |
| | អធិច្ចសមុប្បន្និកា . . . . . | ៧១ |
| | អបរន្តកប្បិកា . . . . . | ៧៥ |
| | ទ្វេមាយតនិកា អសញ្ញីវាទា . . . . | ៧៧ |
| | ទ្វេមាយតនិកា នេវសញ្ញីនាសញ្ញីវាទា . . | ៧៩ |
| | ទ្វេវាទា . . . . . | ៨១ |
| | ទិដ្ឋធម្មនិព្វានវាទា . . . . . | ៨៧ |
| | អបរន្តកប្បិកា ទិដ្ឋធម្មនិព្វានវាទា . . . | ៩១ |
| | សស្សតវាទា . . . . . | ៩៣ |
| | អមរាវិក្ខេបិកាទេយ្យា . . . . . | ៩៥ |
| | ទ្វេមាយតនិកាទេយ្យា . . . . . | ៩៧ |
| | បុព្វន្តកប្បិកាទេយ្យា . . . . . | ៩៩ |
| | អបរន្តកប្បិកាទេយ្យា . . . . . | ១០៧ |

# សង្ខិត្តចន្ទ័លមាតិកា


លេខទំព័រ

ព្រហ្មជាលសូត្រ កំណត់នូវចំណែកនៃខន្ធខាងដើម បុព្វេនិវាសានុស្សតិ . . ៤៥

កំណត់នូវចំណែកនៃខន្ធខាងដើម ហេតុ ៤ យ៉ាង . . . ៤៧

កំណត់នូវចំណែកនៃខន្ធ ខាងដើម ប្រកបដោយអមរា-

វិក្ខេបទិដ្ឋិ. . . . . ៦៣

ប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ . . . . . ៧១

ប្រកបដោយអបរន្តកប្បទិដ្ឋិ. . . . . ៧៥

ប្រកបដោយខន្ធមាយតនទិដ្ឋិ ជាអសញ្ញីវាទ . . . . ៧៧

ប្រកបដោយខន្ធមាយតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ. . ៧៩

ឧច្ឆេទវាទ . . . . . ៨១

ទិដ្ឋធម្មនិព្វានវាទ . . . . . ៨៧

ប្រកបដោយអបរន្តកប្បទិដ្ឋិ ទិដ្ឋធម្មនិព្វានវាទ. . . . ៨១

សស្សតវាទ . . . . . ៨៣

ប្រកបដោយអមរាវិក្ខេបទិដ្ឋិ ជាដើម . . . . . ៨៥

ប្រកបដោយខន្ធមាយតនទិដ្ឋិ ជាដើម. . . . . ៨៧

ប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាដើម . . . . . ៨៨

ប្រកបដោយអបរន្តកប្បទិដ្ឋិ ជាដើម . . . . . ១០៧

## មាតិកាបត្តាង


| | | អង្កេ |
|---|---|---|
| ព្រហ្មជាលសុត្តេ | បុព្វន្តាបរន្តកប្បិកាទយោ . . . . . | ១០៩ |
| | បុព្វន្តកប្បិកាទយោ . . . . . | ១១១ |
| | កតវតោ កាសិតំ អតិនន្ទនំ . . . . | ១១៣ |


## សាមញ្ញជលសុត្តំ ទុតិយំ


| | | |
|---|---|---|
| សាមញ្ញផលសុត្តេ | អជាតសត្តុវត្ថុ . . . . . | ១១៥ |
| | ពុទ្ធគុណកថា . . . . . | ១១៩ |
| | អជាតសត្តុទានំ . . . . . | ១២១ |
| | សន្និដ្ឋិតសាមញ្ញផលបុច្ឆា . . . . . | ១២៣ |
| | បូរណវាទោ . . . . . | ១២៥ |
| | មក្ខលិវាទោ . . . . . | ១២៩ |
| | អជិតវាទោ . . . . . | ១៣៥ |
| | បកុធវាទោ . . . . . | ១៣៩ |
| | និគណ្ឋវាទោ . . . . . | ១៤១ |
| | សញ្ជយវាទោ . . . . . | ១៤៣ |
| | សន្និដ្ឋិតសាមញ្ញផលបុច្ឆា . . . . . | ១៤៧ |

# សន្ទីកាចន្ទ័លមាតិកា


លេខទំព័រ

ព្រហ្មជាលសូត្រ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាដើម . . . ១០៩

ប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាដើម . . . . ១១១

ការត្រួតអប់រំពោះភាសិតរបស់ព្រះមានព្រះភាគ . . ១១៣

## សាមញ្ញផលសូត្រ ទី ២

សាមញ្ញផលសូត្រ រឿងព្រះបាទអជាតសត្តុ . . . . . ១១៥

ពុទ្ធគុណកថា . . . . . ១១៩

ព្រះនាមនៃព្រះបាទអជាតសត្តុ . . . . ១២១

ការសួរអំពីផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់

ដោយខ្លួនឯង . . . . . ១២៣

វាទៈរបស់ត្រូវឈ្មោះបូរណៈ . . . . . ១២៥

វាទៈរបស់ត្រូវឈ្មោះមក្ខលិ . . . . . ១២៩

វាទៈរបស់ត្រូវឈ្មោះអជិតៈ . . . . . ១៣៥

វាទៈរបស់ត្រូវឈ្មោះបកុធៈ . . . . . ១៣៩

វាទៈរបស់ត្រូវឈ្មោះនិគណ្ឋៈ . . . . . ១៤១

វាទៈរបស់ត្រូវឈ្មោះសញ្ជ័យ . . . . . ១៤៣

ការសួរអំពីផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់

ដោយខ្លួនឯង . . . . . ១៤៧

# មាតិកាបត្តង


| | អង្កេ |
|---|---|
| សាមញ្ញផលសុត្តេ សន្ទិដ្ឋិកសាមញ្ញផលទេសនា . . . . | ១៤៩ |
| ពុទ្ធគុណកថា . . . . . | ១៥៥ |
| សីលក្ខន្ធកថា ចូឡសីលំ . . . . . | ១៥៧ |
| សីលក្ខន្ធកថា មជ្ឈិមសីលំ . . . . | ១៦១ |
| សីលក្ខន្ធកថា មហាសីលំ . . . . . | ១៦៩ |
| ឥន្ទ្រិយសំវរោ . . . . . | ១៧៧ |
| សតិសម្បជញ្ញំ សន្ទដ្ឋិ . . . . . | ១៧៩ |
| បញ្ចនីវរណប្បហានំ . . . . . | ១៨១ |
| បញ្ចនីវរណប្បហានំ . . . . . | ១៨៥ |
| ទុតិយជ្ឈានំ ទុតិយវោហារោបមា . . . | ១៨៧ |
| ចតុត្ថជ្ឈានំ . . . . . | ១៨៩ |
| ញាណទស្សនាភិនិហារណំ . . . . | ១៩១ |
| មនោមយាភិនិម្មិនំ . . . . . | ១៩៣ |
| ឥទ្ធិវិធញ្ញាណំ . . . . . | ១៩៥ |
| ទិព្វសោតធាតុ . . . . . | ១៩៧ |

# សន្ទីកចន្ទ្រលមាតិកា


លេខទំព័រ

សាមញ្ញផលសូត្រ ការទ្រង់សំដែងផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង . . . . . ១៤៩

ពុទ្ធគុណកថា . . . . . ១៥៥

សីលកថា ចូឡសីល . . . . . ១៥៧

សីលកថា មជ្ឈិមសីល . . . . . ១៦១

សីលកថា មហាសីល . . . . . ១៦៩

សេចក្តីសង្រួមក្នុងឥន្ទ្រិយ . . . . . ១៧៧

សតិសម្បជញ្ញៈ សេចក្តីសន្តោស . . . . . ១៧៩

សេចក្តីឧបមានៃនីវរណធម៌ទាំង ៥ . . . . ១៨១

ការលះបង់នូវនីវរណធម៌ទាំង ៥ . . . . ១៨៥

ទុតិយជ្ឈាន សេចក្តីប្រៀបដោយអន្លង់ទឹក . . ១៨៧

ចតុត្ថជ្ឈាន . . . . . ១៨៨

ការបង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ . . ១៩១

ការតំម្កើងនូវកាយដែលសម្រេចអំពីចិត្ត . . . ១៩៣

ញាណជាគ្រឿងកាត់តែងឫទ្ធិ . . . . . ១៩៥

សោតធាតុ ជាទិព្វ . . . . . ១៩៧

# មាតិកាបត្តាំង


| | | អង្គ |
|---|---|---|
| សាមញ្ញផលសុត្តេ | ចេតោបរិយញ្ញាណំ . . . . . | ១៩៩ |
| | បុព្វេនិវាសានុស្សតិញ្ញាណំ . . . . | ២០១ |
| | ចុតូបបាតញ្ញាណំ . . . . . | ២០៥ |
| | អាសវក្ខយញ្ញាណំ . . . . . | ២០៩ |
| | អជាតសត្តុស្ស រុជាសកត្តទេសនា . . . | ២១១ |
| | អជាតសត្តុស្ស អនុមោទនា . . . . | ២១៣ |


## អម្ពដ្ឋសុត្តំ តតិយំ


| | | |
|---|---|---|
| អម្ពដ្ឋសុត្តេ | និទានំ អម្ពដ្ឋមាណវត្ថុ . . . . . | ២១៧ |
| | ទុតិយតតិយឥញ្ជាវទនិជ្ជាតនំ . . . . | ២២៥ |
| | សក្យវំសកថា . . . . . | ២២៧ |
| | ពាសីបុត្តវទនិម្មាទនំ . . . . . | ២២៩ |
| | អម្ពដ្ឋមាណវំសកថា . . . . . | ២៣១ |
| | វិជ្ជាចរណសម្បទា . . . . . | ២៤១ |
| | វិជ្ជាចរណសម្បទាយ អជ្ឈាយមុខានិ . . | ២៤៣ |
| | បុព្វកឥសយោ . . . . . | ២៤៩ |

# សន្ទីកថង្កុលមាតិកា


| | | លេខទំព័រ |
|---|---|---|
| សាមញ្ញផលសូត្រ | បេតោបរិយញ្ញាណ . . . . . | ១៩៥ |
| | បុព្វេនិវាសានុស្សតិញ្ញាណ . . . . . | ២០១ |
| | ចុតូបបាតញ្ញាណ . . . . . | ២០៥ |
| | អាសវក្ខយញ្ញាណ . . . . . | ២០៩ |
| | ការទ្រង់សំដែងព្រះអង្គជាទាសការបស់ព្រះបាទអជាតសត្តុ . | ២១១ |
| | ការទ្រង់អនុមោទនាបស់ព្រះបាទអជាតសត្តុ . . | ២១៣ |


## អម្ពដ្ឋសូត្រ ទី ៣


| | | |
|---|---|---|
| អម្ពដ្ឋសូត្រ | និទាន រឿងអម្ពដ្ឋមាណព . . . . . | ២១៧ |
| | ការពោលបន្ទុះបង្អាប់ជាតិជាតិកូនជាតិមហាយតី ជាតំរប់២នឹងតំរប់ ៣ | ២២៥ |
| | ពោលអំពីសក្យវង្ស . . . . . | ២២៧ |
| | ការញុះញង់ដោយពាក្យថា កូនទាសី . . . | ២២៩ |
| | ពោលអំពីវង្សរបស់អម្ពដ្ឋមាណព . . . . | ២៣១ |
| | ការបរិបូណ៌ដោយវិជ្ជានឹងចរណៈ . . . . | ២៤១ |
| | ប្រធានៃសេចក្តីសាបសូន្យនៃគុណសម្បទាតិវិជ្ជានឹងចរណៈ | ២៤៣ |
| | ពួកឥសីដែលជាបុព្វបុរស . . . . . | ២៤៩ |

# មាតិកាបត្តាធិ


| | | អង្កៀ |
|---|---|---|
| អម្ពដ្ឋសុត្តេ | ទ្វេ មហាបុរិសលក្ខណានិ , . . . | ២៥៣ |
| | ឱបាក្ខវសោតិព្រាហ្មណវត្ថុ. . . . . | ២៥៥ |
| | អនុបុព្វីកថា ធម្មចក្ខុ . . . . . | ២៦១ |
| | ឱបាក្ខវសោតិសទ្ទ អជ្ឈាសយំ . . . . | ២៦៣ |
| | **សោណទណ្ឌសុត្តំ ចតុត្ថំ** | |
| សោណទណ្ឌសុត្តេ | ពុទ្ធគុណកថា . . . . . | ២៦៥ |
| | កតវរោ កិត្តិសទ្ទោ. . . . . | ២៦៧ |
| | សោណទណ្ឌព្រាហ្មណគុណកថា . . | ២៦៨ |
| | ពុទ្ធគុណកថា . . . . . | ២៧៣ |
| | សោណទណ្ឌព្រាហ្មណបរិតក្កោ. . . | ២៧៨ |
| | សោណទណ្ឌសទ្ទ កតវន្តូបសង្កមនំ . . | ២៨១ |
| | សោណទណ្ឌព្រាហ្មណបរិតក្កោ. . . | ២៨៣ |
| | ព្រាហ្មណបញ្ញត្តិយា បញ្ចង្គានិ . . . | ២៨៥ |
| | ព្រាហ្មណបញ្ញត្តិយា តីណង្គានិ . . . | ២៨៧ |
| | ព្រាហ្មណបញ្ញត្តិយា ទ្វេ អង្គានិ . . . | ២៨៩ |

# សន្ទីកថង្កុលមាតិកា


លេខទំព័រ

អដ្ឋង្គិសូត្រ មហាបុរិសលក្ខណៈ ២ ប្រការ . . . . . ២៥៣

រឿងព្រាហ្មណ៍ឈ្មោះជោតិរសាតិ . . . . . ២៥៥

អនុពុព្វីកថា ធម្មចក្ក . . . . . ២៦១

ការអាវាធនារបស់ព្រាហ្មណ៍ឈ្មោះជោតិរសាតិ . . . ២៦៣

## សោណទណ្ឌសូត្រ ទី ៤

សោណទណ្ឌសូត្រ ពុទ្ធគុណកថា . . . . . ២៦៥

កិត្តិសព្ទរបស់ព្រះមានព្រះភាគ . . . . . ២៦៧

គុណកថា របស់សោណទណ្ឌព្រាហ្មណ៍ . . . . ២៦៩

ពុទ្ធគុណកថា . . . . . ; ២៧៣

សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍ . . . ២៧៩

ការជួលទៅគាល់ព្រះមានព្រះភាគនៃសោណទណ្ឌព្រាហ្មណ៍ ២៨១

សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍ . . . ២៨៣

ការបញ្ញត្តិថាជាព្រាហ្មណ៍មានអង្គ ៥ . . . . ២៨៥

ការបញ្ញត្តិថាជាព្រាហ្មណ៍មានអង្គ ៣ . . . . ២៨៧

ការបញ្ញត្តិថាជាព្រាហ្មណ៍មានអង្គ ២ . . . . ២៨៩

# មាតិកាបត្តាំង


| | | អង្គ |
|---|---|---|
| សោណទណ្ឌសុត្តំ | សោណទណ្ឌព្រាហ្មណស្ស បដិវេទនំ . | ២៩១ |
| | អង្គកមាណវកគុណកថា . . . . | ២៩៣ |
| | សីលបញ្ញាកថា . . . . . | ២៩៥ |
| | សោណទណ្ឌស្ស ទុប្បាសកត្តទេសនា . | ២៩៧ |
| | សោណទណ្ឌព្រាហ្មណាធិប្បាយោ . . | ២៩៩ |

# សន្ទីកថង្គុលមាតិកា


| | | លេខទំព័រ |
|---|---|---|
| សោណទណ្ឌសូត្រ | ការពោលតបបន្ទរបស់សោណទណ្ឌព្រាហ្មណ៍ . . . | ២៨១ |
| | ការពោលអំពីគុណរបស់អង្គកមាណព . . . | ២៨៣ |
| | ពោលអំពីសីលនិងបញ្ញា . . . . . | ២៨៥ |
| | សោណទណ្ឌព្រាហ្មណ៍សំដែងខ្លួនជាឧបាសក . . | ២៨៧ |
| | បំណងរបស់សោណទណ្ឌព្រាហ្មណ៍ . . . | ២៨៨ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធចាហៅ | អវិរុទ្ធចាហៅ | អន្លង់ | វជ្ជលេខាយំ |
|---|---|---|---|
| តឹសម្ប | បញ្ចបិ | ៣២ | ៦ |
| បញ្ចបិ | តឹសម្ប | " | ៧ |
| ឯមាហាក | ឯមាហាកេ | ៣៨ | ១១ |
| ចរំ | ចិរំ | ៤៤ | " |
| ឥមហេវ | ឥមេហេវ | ៥៣ | ១៧ |
| ឥម | ឥមេ | ៥៤ | ២ |
| តេសម្ប | តេសម្ប | ៦០ | ៩ |
| សិរិវិជ្ជ | សិរិវិជ្ជ | ១៦៩ | ៥ |
| សមណា | សមណេ | ២៧៧ | ៨ |
| ព្យាកតព្ភោតិ | ព្យាកាតព្ភោតិ | ២៨០ | " |

# សន្លឹកប្រៀបពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ការៈនៃសត្វចំឆ្កួយ | ការៈនៃសត្វចំឆ្កួយ | ៣ | ១០ |
| ដូជា | ដូចជា | ៣៤ | ១២ |
| អមការិក្ខេបទិដ្ឋ | អមការិក្ខេបទិដ្ឋ | ៦៥ | ១ |
| ដោយវត្តុ ៤ យ៉ាង | ដោយវត្តុ ២ យ៉ាង | ៨៥ | ១២ |
| ដោយវត្តុ ១៧ យ៉ាង | ដោយវត្តុ ១៨ យ៉ាង | ៨៦ | ៦ |
| ដោយវត្តុ ៦ យ៉ាង | ដោយវត្តុ ១៦ យ៉ាង | ១០៥ | ១១ |
| ដូជាកំបិតកោរ | ដូចជាកំបិតកោរ | ១២៧ | ១៤ |
| អង្គុយទី | អង្គុយកន្លែងទី | ១៣៨ | ១២ |
| ចូលទៅកាត់ផ្លូវ | ចូលទៅកាន់ផ្លូវ | ១៥៣ | ៩ |
| ស្បែងរាស់ដីខ្សាច់ | ស្បែងរាល់ដីខ្សាច់ | ១៦២ | ១១ |
| ធ្វើទីរាល | ធ្វើទីរាល | ១៨៦ | ៣ |
| ជាគ្រូ | ជាគ្រូ | ២១៨ | ៩ |

INSTITUT BOUDDHIQUE